01185947 F26/12

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Dec-2015, 10:59
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**
**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ:**

---

# សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារ
# សំអាងហេតុពេញលេញ

---

**សហព្រះរាជអាជ្ញា** **សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង

Nicholas KOUMJIAN

**សហព្រះរាជអាជ្ញា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

ខៀវ សំផន

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**") បានទទួលសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារសាក្សី SCW-3, SCW-4 និង SCW-5[1] សេចក្តីជំទាស់របស់ នួន ជា ទៅនឹងបញ្ជីឯកសារដែលត្រូវប្រើប្រាស់ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលសួរសាក្សី SCW-3, SCW-4 និង SCW-5,[2] និងសេចក្តីជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងការប្រើប្រាស់ឯកសារមួយចំនួននៅក្នុងពេលស្តាប់សាក្ខីកម្មសាក្សី SCW-3, SCW-4 *និង* SCW-5[3] ("សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា", "សេចក្តីជំទាស់របស់ នួន ជា" និង"សេចក្តីជំទាស់របស់ ខៀវ សំផន" នីមួយៗ)។

## I. សាវតារ

2. បន្ថែមលើសំណើសុំរបស់ នួន ជា[4] នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបើកសវនាការស្តាប់សាក្សី SCW-3, SCW-4 និង SCW-5 លើបណ្តឹងសាទុក្ខ[5]។ សវនាការស្តាប់សាក្សីទាំងនេះ ធ្វើឡើងនៅថ្ងៃទី ០២ រហូតដល់ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៥ ក្នុងករណីចាំបាច់[6] ("សវនាការខែ កក្កដា ឆ្នាំ ២០១៥")។

3. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីណែនាំស្តីពីកិច្ចដំណើរការនីតិវិធីសវនាការ[7] ("សេចក្តីណែនាំ") *ក្នុងនោះ* បានបង្គាប់ភាគីឱ្យដាក់បញ្ជីឯកសារដែលខ្លួនមានបំណងប្រើប្រាស់ក្នុងពេលសួរសាក្សី "យ៉ាងយូរត្រឹមថ្ងៃ ពុធ ទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ហើយផ្ញើតាមរយៈអ៊ីមែលមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល និងភាគីដទៃទៀតនៅក្នុងសំណុំរឿង

---

[1] ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ F26/7។

[2] ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ F26/8 ។

[3] ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ F26/9។

[4] សំណើទីបីសុំពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ F2/4។

[5] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ឯកសារ F2/5។

[6] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F24។

[7] ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F26។

០០២/០១”[8]។ សម្រាប់ឯកសារដែលច្រើនជាង ៣០ ទំព័រ ភាគីត្រូវបានណែនាំផ្តល់លេខ ERN លើទំព័រឯកសារទាំងនោះដែលខ្លួនរំពឹងថានឹងប្រើប្រាស់[9]។ អង្គជំនុំជម្រះតុលាការកំពូលណែនាំថា ការជំទាស់ណាមួយទៅនឹងឯកសារដែលមានបំណងប្រើប្រាស់ ត្រូវដាក់យ៉ាងយូរត្រឹមថ្ងៃ សុក្រ ទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥[10] បន្ទាប់មក កាលបរិច្ឆេទនេះត្រូវបានពន្យារដល់ថ្ងៃ ច័ន្ទ ទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥[11]។ ជាការឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី នួន ជា ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់តាមអ៊ីមែលមួយដែលបានចម្លងទៅឱ្យភាគីទាំងអស់ថា “បញ្ជីនៃសម្ភារៈ នឹងត្រូវដាក់ឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីពេលវេលានៃការដាក់ឯកសារផ្លូវការ ដូចជា យ៉ាងយូរត្រឹមម៉ោង ៤:00 ល្ងាច”[12]។

4. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តី ខៀវ សំផន មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើអ៊ីមែលមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល[13] ដែលអ៊ីមែលនេះ ត្រូវចម្លងទៅឱ្យភាគីដទៃទៀត ដោយបានភ្ជាប់ជាមួយនូវបញ្ជីឯកសារនីមួយៗដែលមានបំណងប្រើប្រាស់ក្នុងពេលសួរសំណួរសាក្សី (“បញ្ជីឯកសាររបស់ ខៀវ សំផន” “បញ្ជីឯកសាររបស់ នួន ជា” និង“បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី” នីមួយៗ)។ អ៊ីមែលនេះ ត្រូវបានផ្ញើចេញនៅម៉ោង ៣ និង ៥៦ នាទីល្ងាច និងម៉ោង ៤ និង ១៥ នាទីល្ងាច រៀងៗខ្លួន។ នៅថ្ងៃដដែលនោះ បុគ្គលិកម្នាក់នៃការិយាល័យសហព្រះរាជអាជ្ញា បានផ្ញើអ៊ីមែលនៅម៉ោង ៤ និង ៤២ នាទី មកកាន់ក្រឡាបញ្ជីនៃអង្គ

---

[8] សេចក្តីសេចក្តីណែនាំ កថាខណ្ឌដែលមានអានុភាព ៣ ក) ទំព័រ ៤។

[9] សេចក្តីសេចក្តីណែនាំ កថាខណ្ឌដែលមានអានុភាព ៣ ក) ទំព័រ ៤។

[10] សេចក្តីសេចក្តីណែនាំ កថាខណ្ឌដែលមានអានុភាព ៣ ខ) ទំព័រ ៥។

[11] សេចក្តីសេចក្តីលើសំណើសុំបន្ថែមពេលវេលាសម្រាប់ការជំទាស់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F26/1/1។

[12] អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់សម្រាប់ នួន ជា“Re: សំណួរទាក់ទងនឹងបញ្ជីសម្ភារៈសម្រាប់សាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5” ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ ម៉ោង ១៤ និង ៦ នាទី នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[13] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ ខៀវ សំផន មកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល“បញ្ជីឯកសារសម្រាប់សួរសាក្សី SCW-3, SCW-4 និង SCW-5” នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ នួន ជា ទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលនូវ“បញ្ជីឯកសារសម្រាប់សួរសាក្សី SCW-3, SCW-4 and SCW-5”នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ អ៊ីមែលពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល និងភាគី“បញ្ជីឯកសារ/ SCW-3, SCW-4, SCW-5” នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

ជំនុំជម្រះតុលាការកំពូល[14] ដោយបានចម្លងទៅឱ្យភាគីដទៃទៀត និងមានភ្ជាប់មកជាមួយនូវបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ("បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា") និងបានបញ្ជាក់ថា "បញ្ជីឯកសារនេះត្រូវបានដាក់កាលពីរសៀលនេះ [តាមរយៈការដាក់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិក] ប៉ុន្តែ ពុំមានបញ្ជាក់ពីលេខ Khmer ERNs សម្រាប់ឯកសារយោងនៃប្រតិចារឹកនៅក្នុងតារាងឡើយ។ តារាង ដែលត្រូវបានធ្វើបច្ចុប្បន្នភាពលើការបាត់លេខ Khmer ERNs នឹងដាក់ក្នុងពេលឆាប់ៗនេះ"

5. នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ នៅម៉ោង ១០ និង ៥០ នាទី បុគ្គលិកម្នាក់នៃការិយាល័យរបស់សហព្រះរាជអាជ្ញា បានផ្ញើតាមរយៈអ៊ីមែលមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល[15] និងបានចម្លងទៅឱ្យភាគីនូវបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព ("បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលត្រូវបានធ្វើបច្ចុប្បន្ន") ដោយបានបញ្ជាក់លម្អិតនៅក្នុងអ៊ីមែលអំពីការកែប្រែទៅលើបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។ ការកែប្រែនោះមានដូចជា ការកែប្រែទៅលើចំណងជើងនៃបញ្ជី ការបញ្ចូលគ្នានៃឯកសារដែលមានក្នុងបញ្ជីពីរដង ការធ្វើចំណាត់ថ្នាក់ឡើងវិញទៅតាមប្រភេទឯកសារផ្សេងៗគ្នា ការផ្តល់លេខ English ERN សម្រាប់ឯកសារមួយចំនួន ការផ្តល់លេខ Khmer ERN សម្រាប់ឯកសារមួយចំនួន និងការបន្ថែមឯកសារមួយទៀត គឺលេខ E3/1539 ដែលទាំងអស់នេះ យោងតាមអ៊ីមែល"ថាជាកំហុសផ្នែករដ្ឋបាល [...] ពុំត្រូវបានដាក់ចូលនៅក្នុងបញ្ជីកាលពីដំបូង"[16]។

6. នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ នៅម៉ោង ៣ និង ២១ នាទី និងក្រោយពីសំណើរបស់មេធាវីការពារក្តី ខៀវ សំផន[17] បុគ្គលិកម្នាក់នៃការិយាល័យសហព្រះរាជអាជ្ញា បានផ្ញើតាមរយៈអ៊ីមែល[18]នូវបញ្ជី

---

[14] អ៊ីមែលពីជំនួយការសហព្រះរាជអាជ្ញាទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល "បញ្ជីឯកសារពីការិយាល័យសហព្រះរាជអាជ្ញា ដើម្បីប្រើប្រាស់ ក្នុងអំឡុងពេលសួរសំណួរសាក្សី SCW-3, SCW-4 និង SCW-5" នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[15] អ៊ីមែលរបស់ជំនួយការសហព្រះរាជអាជ្ញាមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល "បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាត្រូវបានកែតម្រូវ" នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[16] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលបានធ្វើបច្ចុប្បន្នភាព។

[17] *សូមមើល* អ៊ីមែលរបស់អ្នកប្រឹក្សាច្បាប់សម្រាប់ ខៀវ សំផន ទៅនឹងកាន់ ជំនួយការសហព្រះរាជអាជ្ញា "Re: បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាត្រូវបានកែតម្រូវ" ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ម៉ោង ៩ និង ៥៤ នាទី នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[18] អ៊ីមែលរបស់ជំនួយការសហព្រះរាជអាជ្ញាទៅកាន់អ្នកប្រឹក្សាច្បាប់សម្រាប់ ខៀវ សំផន "Re: បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាត្រូវបានកែតម្រូវ" នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

ឯកសារបន្ថែមដែលបានធ្វើបច្ចុប្បន្នភាព ដែលសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ រួមមានលេខ ERN លើឯកសារជាភាសាបារាំងដែលមានចំនួនលើសពី ៣០ ទំព័រ។

7. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារ[19]។

8. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចលើការជំទាស់ទាំងនេះ ដោយបានចេញសំអាងហេតុសង្ខេប ដោយបញ្ជាក់ថា សំអាងហេតុពេញលេញនឹងត្រូវចេញក្នុងពេលសមស្រប[20]។ ដោយហេតុនេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុដូចតទៅ។

## II. ការដាក់បញ្ជីឯកសារយឺតពេលរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា

9. នួន ជា បានលើកឡើងថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់យឺតពេល និងសម្រាប់ហេតុនេះ សហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំគប្បីត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារណាមួយនៅក្នុងបញ្ជីរបស់ខ្លួន ក្នុងពេលសួរសំណួរសាក្សីឡើយ[21]។ ខៀវ សំផន ក៏បានកត់សម្គាល់ផងដែរថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់យឺតពេល[22]។

---

[19] *សូមមើលខាងលើ* កថាខណ្ឌ ១ *និងការយោងទៅលើ*សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា របស់ នួន ជា និង ខៀវ សំផន *នៅទីនោះ*។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់សេចក្តីជំទាស់របស់ខ្លួន ដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានបដិសេធ ពីព្រោះសេចក្តីជំទាស់នេះ បានតែភាសាអង់គ្លេសប៉ុណ្ណោះ។ អ៊ីមែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលទៅកាន់ Singh Chitrangada "សេចក្តីជូនដំណឹងពីការដាក់ឯកសារមិនគ្រប់លក្ខណៈ" ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៥ ម៉ោង ៤ និង ៣៤ នាទីល្ងាច។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F26/10។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបដិសេធសំណើនេះនៅក្នុងសេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៣៩(៤)(ខ) ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F26/10/1។

[20] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារ, សេចក្តីសង្ខេបចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F26/11។

[21] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ២។

[22] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៧។

10. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើតាមរយៈអ៊ីមែលមកកាន់អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ក្រោយម៉ោង ៤:00 អាស្រ័យហេតុនេះ ជាការដាក់ស្តែង គឺនៅក្រោយកាលបរិច្ឆេទដែលអង្គជំនុំជម្រះបានកំណត់។ ដោយហេតុថា សហព្រះរាជអាជ្ញា បានដាក់បញ្ជីឯកសារតាមប្រព័ន្ធអេឡិចត្រូនិក (អាចនៅមុនម៉ោង ៤:00) ដូចនេះ សហព្រះរាជអាជ្ញា ពុំត្រូវបានចាត់ទុកថា ជាការមិនគោរពតាមសេចក្តីណែនាំច្បាស់លាស់របស់អង្គជំនុំជម្រះតុលាការកំពូល ដែលមានគោលបំណងក្នុងការធានាថា ភាគីដទៃទៀត អាចនឹងបានដឹងអំពីបញ្ជីនៃឯកសារទាំងអស់នេះ ជៀសវាងការរអាក់រអួល ដែលអាចនឹងកើតដោយសារនីតិវិធីតាមប្រព័ន្ធអេឡិចត្រូនិក។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ថា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានបង្ហាញការពន្យល់ណាមួយលើបញ្ហានៃការឯកសារយឺតពេលរបស់ខ្លួនឡើយ។ ទោះជាយ៉ាងណាក្តី ដោយហេតុថា ការមិនគោរពតាមកាលបរិច្ឆេទនោះ គឺខុសគ្នាត្រឹមតែ(៤២ និង ១៥ នាទី រៀងៗខ្លួនប៉ុណ្ណោះ) និងពុំមានប៉ះពាល់ជាក់លាក់ណាមួយដល់កិច្ចដំណើរការនីតិវិធី ឬការរៀបចំរបស់ភាគី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាករណីពិសេស។

## III. ឯកសារបន្ថែមលើបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលបានធ្វើបច្ចុប្បន្នភាព

11. នួន ជា ជំទាស់ទៅនឹងការដាក់បញ្ចូលឯកសារលេខ E3/1539 ទៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលបានធ្វើបច្ចុប្បន្នភាព[23]។

12. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ឯកសារលេខ E3/1539 ពុំមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងការពន្យល់ដែលពុំជាក់លាក់ថា គ្រាន់តែជា"កំហុសផ្នែករដ្ឋបាល"ចេញពីខាងសហព្រះរាជអាជ្ញា។ ក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សហព្រះរាជអាជ្ញា ពុំអាចប្រើប្រាស់ឯកសារលេខ E3/1539 ក្នុងការសួរសំណួរសាក្សីឡើយ។

---

[23] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ៩។

01185954



## IV. ឯកសារដែលច្រើនជាង ៣០ ទំព័រ គ្មានលេខ ERN

13. នួន ជា កត់សម្គាល់ឃើញថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សំដៅលើឯកសារមួយចំនួន ដែលមានច្រើនជាង ៣០ ទំព័រ ប៉ុន្តែពុំត្រូវបានផ្តល់លេខ ERN លើផ្នែកដែលសហព្រះរាជអាជ្ញា មានបំណងចង់ឆ្លើយតប។ នួន ជា រំលឹកថា លេខ ERN សម្រាប់ឯកសារជាភាសាខ្មែរ ត្រូវបានផ្តល់នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលព្រឹកក្នុងថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ និងថា លេខ ERN សម្រាប់ឯកសារភាសាបារាំង ត្រូវបានផ្ញើតាមរយៈអ៊ីមែលនៅពេលរសៀលក្នុងថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ តែប៉ុណ្ណោះ[24]។ នួន ជា កត់សម្គាល់ផងដែរថា នៅមានឯកសារ ១០ ច្បាប់ទៀត ដែលនីមួយៗមានច្រើនជាង ៣០ ទំព័រ ដែលសហព្រះរាជអាជ្ញាពុំត្រូវបានផ្តល់លេខ ERN [25]។ ទាក់ទងនឹងបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ជា កត់សម្គាល់ថា ជំនួសឱ្យការផ្តល់លេខ ERN សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ពេលវេលាប្រហាក់ប្រហែលនៃប្រតិចារឹកដែលចោទជាបញ្ហានេះ[26]។

14. ខៀវ សំផន បានកត់សម្គាល់ថា ទាក់ទងនឹងបញ្ហានេះ តាមបទដ្ឋាននៃការអនុវត្ត សហព្រះរាជអាជ្ញា និងភាគីទាំងអស់ត្រូវផ្តល់លេខ ERN សម្រាប់រាល់ឯកសារ និងគ្រប់ភាសាទាំងអស់រួមទាំងភាសាបារាំង[27]។ ខៀវ សំផន បានលើកឡើងថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា វែងអន្លាយ និងមានឯកសារច្រើនជាងពេលវេលាដែលអនុញ្ញាតឱ្យប្រើប្រាស់ឯកសារទៅទៀតសម្រាប់សួរសំណួរសាក្សីបីរូប និងថា ឯកសារជាច្រើន ទំនងជាពុំមានភាពជាប់ពាក់ព័ន្ធទៅនឹងបញ្ហានៅចំពោះមុខ និងមាននៅក្នុងសំណុំរឿងអស់រយៈពេលជាច្រើនឆ្នាំហើយ ប៉ុន្តែ ពុំត្រូវបានប្រើប្រាស់នៅក្នុងបរិបទនៃសំណុំរឿង ០០២/០១[28]។ ខៀវ សំផនបានលើកឡើងដោយសំអាងលើបញ្ហានេះ ថា សហព្រះរាជអាជ្ញា ពុំគប្បីត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារណាមួយនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ពីព្រោះសហព្រះរាជអាជ្ញា មានបំណងអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធី (សូមមើល វិធាន ៨៧(ង) នៃវិធានផ្ទៃក្នុង) លើក

[24] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ១, ១០។

[25] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ១០។

[26] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ១០។

[27] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៩។

[28] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៨ និង ១០។

លែងតែចម្លើយពីមុនៗរបស់សាក្សីបីរូប ដែលគ្រោងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[29]។

15. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះបានណែនាំឱ្យភាគីផ្តល់លេខ ERN នៅក្នុងបញ្ជីឯកសាររបស់ខ្លួន លើផ្នែកដែលខ្លួនរំពឹងថា ប្រើប្រាស់ក្នុងពេលសួរសាក្សីលើរាល់ឯកសារដែលមានច្រើនជាង ៣០ ទំព័រ[30]។ គោលបំណងនៃការណែនាំនេះ គឺដើម្បីឱ្យភាគីដទៃទៀតរួមទាំងអង្គជំនុំជម្រះផង អាចរៀបចំឱ្យបានសមស្របសម្រាប់សវនាការខាងមុខ។ បន្ថែមលើនេះ ការផ្តល់លេខ ERN នឹងអាចឱ្យភាគីធ្វើការជំទាស់ទៅនឹងបញ្ជីឯកសាររបស់ភាគីដទៃទៀតនៅក្នុងពេលវេលាខ្លីដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់។ សហព្រះរាជអាជ្ញា ពុំបានផ្តល់ការពន្យល់ណាមួយទាក់ទងទៅនឹងមូលហេតុដែលបញ្ជីឯកសាររបស់ខ្លួន ពុំមានលេខ ERN ពេញលេញ ពីមូលហេតុអ្វីបានជាលេខ ERN សម្រាប់ឯកសារភាសាខ្មែរ ត្រូវបានផ្តល់នៅថ្ងៃបន្ទាប់យ៉ាងនេះ និងមូលហេតុអ្វីបានជា លេខ ERN សម្រាប់ឯកសារភាសាខ្មែរ ត្រូវបានផ្តល់ពីរថ្ងៃក្រោយកាលបរិច្ឆេទ និងបន្ទាប់ពីមានសំណើសុំរបស់ ខៀវ សំផន យ៉ាងដូច្នេះ។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា វែងខ្លាំងណាស់ មានឯកសារ ១៥០ ច្បាប់ដែលមានទំព័រច្រើនៗ។ អង្គជំនុំជម្រះតុលាការកំពូលដឹងថា ពុំមែនសហព្រះរាជអាជ្ញាទេដែលជាអ្នកស្នើសុំសក្ខីកម្មរបស់សាក្សីបីរូបនេះ ដូចនេះទើបសហព្រះរាជអាជ្ញាមានការលំបាក ក្នុងការជ្រើសរើសយកឯកសារដែលជាប់ពាក់ព័ន្ធណាខ្លះដែលត្រូវប្រើប្រាស់នៅក្នុងពេលសួរសំណួរនោះ ហើយចំនួនឯកសារយ៉ាងច្រើននៅក្នុងបញ្ជី បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ភាគីដទៃទៀត ដោយសារការបាត់នូវលេខ ERN។ ការផ្តល់លេខ ERN យឺតពេល និងចោះៗនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលបានធ្វើបច្ចុប្បន្នភាពនោះ និងអ៊ីមែលបន្តបន្ទាប់ ពុំអាចព្យាបាលផលប៉ះពាល់នេះបានទេ។

16. ក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចពុំអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាប្រើប្រាស់ឯកសារណាមួយដែលមានក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលមានច្រើនជាង ៣០ ទំព័រ ដោយសារសហព្រះរាជអាជ្ញាពុំបានផ្តល់ ឬផ្តល់ពុំបានពេញលេញនូវលេខ ERN ទៅតាមកាលបរិច្ឆេទដែលបានកំណត់។ អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើការជំទាស់របស់ ខៀវ សំផន ដែលមានលក្ខណៈជារួមថា សហព្រះរាជអាជ្ញា ពុំគប្បីត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារណាមួយនៅក្នុង

---

[29] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១១។

[30] សេចក្តីណែនាំ កថាខណ្ឌដែលមានអានុភាព ៣ ក)។

បញ្ជីឯកសាររបស់ខ្លួន ដោយសារ សហព្រះរាជអាជ្ញាមានបំណងអូសបន្លាយកិច្ចដំណើរការនីតិវិធី[31]។ ជាការពិតគឺថា ចំនួនឯកសារនៅក្នុងបញ្ជីនោះ មានច្រើន ហើយក៏ពុំមានការបញ្ជាក់ថា សហព្រះរាជអាជ្ញាបានព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធីដែរ និងជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានបែងចែកពេលវេលារួចរាល់ហើយសម្រាប់ការសួរសាក្សី។

17. ទាក់ទងទៅនឹងបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានតែប្រតិចារឹកពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជំនួសឱ្យការផ្តល់លេខ ERN បញ្ជីនេះមានការយោងទៅលើពេលវេលានៅក្នុងប្រតិចារឹក។ តាម នួន ជា បានកត់សម្គាល់ថា បើទោះបីជាពុំបានគោរពតាមសេចក្តីណែនាំក៏ដោយ[32] ក៏ការបញ្ជាក់ពីពេលវេលា អាចអនុញ្ញាតឱ្យភាគីទាំងអស់ និងអង្គជំនុំជម្រះ កំណត់ដោយជាក់លាក់នូវចំណុចដកស្រង់ពាក់ព័ន្ធនៃប្រតិចារឹកដែលចោទជាបញ្ហានេះ និងភាសាទាំងអស់នៃប្រតិចារឹកនោះផងដែរ។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចទទួលយកបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាពុំបានគោរពតាមសេចក្តីណែនាំក៏ដោយ។

## V. ឯកសារដែលពុំបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១

18. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា បញ្ជីឯកសារ ដែលបានដាក់ដោយភាគី មានឯកសារមួយចំនួនដែលពុំត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានដាក់ឱ្យពិនិត្យទាក់ទងនឹងវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ក្នុងបរិបទនៃសំណុំរឿង ០០២/០១។ សហព្រះរាជអាជ្ញាលើកឡើងថា ទាក់ទងនឹងបញ្ហានេះ ឯកសារនេះ ពុំគប្បីត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការសួរសំណួរសាក្សីបីរូប ដោយកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលបានអះអាងថា បទដ្ឋានដែលមានបីផ្នែក អនុវត្តទៅលើភាពអាចទទួលយកបាននៃភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ[33]។ សហព្រះរាជអាជ្ញាបានលើកឡើងថា មានតែចម្លើយពីមុនៗរបស់សាក្សីបីរូបនេះប៉ុណ្ណោះដែលអាចត្រូវបានប្រើប្រាស់ ដែលជាករណីលើកលែងចំពោះគោលការណ៍នេះ[34]។ នួន ជា កត់សម្គាល់ឃើញថា មានឯកសារជាច្រើននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ចេញពីសំណុំរឿង ០០២/០២ និងថា សហព្រះរាជអាជ្ញា ពុំបានស្នើសុំការ

---

[31] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១១។

[32] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ១០។

[33] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ ដល់ ៣។

[34] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣ ជើងទំព័រ ៧។

អនុញ្ញាតទទួលយកជាភស្តុតាងលើបណ្ដឹងសាទុក្ខឡើយ[35]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ពុំគប្បីត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារទាំងនោះក្នុងការសួរសំណួរសាក្សី[36]។ នួន ជា បានពន្យល់ថា មានឯកសារបួនច្បាប់នៅក្នុងបញ្ជីឯកសាររបស់ នួន ជា ចេញពីសំណុំរឿង ០០២/០២ ដែលពុំមានសំណើសុំដាក់ភស្តុតាងបន្ថែម ត្រូវបានធ្វើឡើងនៅឡើយ ប៉ុន្តែ ថា ការដាក់សំណើសុំនេះ នឹងធ្វើនៅពេលឆាប់ៗខាងមុខ[37]។ នួន ជា បានកត់សម្គាល់ផងដែរថា មានឯកសារបីច្បាប់នៅក្នុងបញ្ជីដែលពុំមាននៅក្នុងសំណុំរឿង ០០២ ទាល់តែសោះ។ ដោយសារ នួន ជា នឹងដាក់សំណើសុំដាក់ភស្តុតាងបន្ថែមឆាប់ៗខាងមុខ នួន ជា បង្ហាញថា "ដោយស្របទៅតាមការអនុវត្តតាមធម្មតានៅក្នុងតុលាការក្នុងស្រុក វាពុំចាំបាច់តម្រូវឱ្យដាក់សំណើសុំដាក់ភស្តុតាងរបៀបនេះទេ ជាឧ. ឯកសារទាំងនោះ ដែលអាចរកបានជាសាធារណៈ"[38]។ ឯកសារបីដែលចោទជាបញ្ហានេះ គឺជាអត្ថបទដែលបានផ្សាយក្នុងទស្សនាវដ្ដីក្នុងទសវត្សឆ្នាំ ១៩៧០។ ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារបានមកពីសំណុំរឿង ០០២/០២ ០០៣ និង ០០៤ ដោយពុំមានការពន្យល់របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមូលហេតុអ្វីបានជាឯកសារទាំងនេះ គប្បីត្រូវបានអនុញ្ញាត[39]។ ទោះជាយ៉ាងណាក្ដី គប្បីមានករណីលើកលែងសម្រាប់ចម្លើយមុនៗរបស់សាក្សីបីរូបនេះដែលត្រូវបានកោះហៅមកផ្ដល់សក្ខីកម្ម[40]។

19. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា តាមក្របខ័ណ្ឌនៃច្បាប់របស់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង បានផ្អែកសេចក្ដីសម្រេចរបស់ខ្លួន "តែលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវដាក់ឱ្យសួរសំណួរតែប៉ុណ្ណោះ"[41]។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ចែងជានីតិវិធីទាក់ទងនឹងវិធីសាស្ត្រដែល សម្ភារៈនៅក្នុងសំណុំរឿង នៃរឿងក្ដីមួយ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ជាលក្ខណៈវិនិច្ឆ័យដែលផ្អែកតាម លក្ខណៈវិនិច្ឆ័យនេះ អង្គជំនុំជម្រះអាចបដិសេធសំណើសុំដាក់ភស្តុតាងបានផងដែរ។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង បានចែងពីនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយក "ភស្តុតាងថ្មី" ក្នុងពេលជំនុំជម្រះ។ ទាក់ទងនឹងដំណាក់កាលបណ្ដឹងសាទុក្ខ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង

---

[35] សេចក្ដីជំទាស់របស់ នួន ជា កថាខណ្ឌ ៥។

[36] សេចក្ដីជំទាស់របស់ នួន ជា កថាខណ្ឌ ៦។

[37] សេចក្ដីជំទាស់របស់ នួន ជា កថាខណ្ឌ ៧។

[38] សេចក្ដីជំទាស់របស់ នួន ជា កថាខណ្ឌ ៨។

[39] សេចក្ដីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២០ ដល់ ២១។

[40] សេចក្ដីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២០។

[41] វិធាន ៨៧ (២) នៃវិធានផ្ទៃក្នុង។

ចែងជានីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់សំណើរបស់ភាគីសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ។ ជាការចាំបាច់ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងថា ភស្តុតាងបន្ថែមនោះ ប្រាកដជាពុំអាចរកបាននៅពេលជំនុំជម្រះ និង "អាចជាកត្តាកំណត់ឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ"។ បន្ថែមលើនេះ ភស្តុតាងបន្ថែមនេះ ត្រូវតែជាប់ពាក់ព័ន្ធទៅនឹងសម្អាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក[42]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល មានឆន្ទានុសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ក្នុងការកោះហៅ "ភស្តុតាងថ្មី" លើបណ្តឹងសាទុក្ខ ដែលខ្លួនអាចប្រើប្រាស់សិទ្ធិអំណាចនេះក្នុងផលប្រយោជន៍យុត្តិធម៌[43]។

20. ស្របតាមក្របខ័ណ្ឌផ្នែកច្បាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នៅពេលពិចារណាលើកំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការចោទប្រកាន់ តាមវិធាន បានកម្រិតត្រឹមតែភស្តុតាង ដែលត្រូវ"បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ទាក់ទងនឹងវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង។ ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ពុំមានភស្តុតាងណាមួយដែលបានដាក់នៅក្នុងសំណុំរឿងនៃរឿងក្តីមួយ គឺត្រូវតែ"ដាក់នៅចំពោះមុខអង្គជំនុំជម្រះ" ជាស្វ័យប្រវត្តិនោះឡើយ។ ជាងនេះទៅទៀត ដូចបានកត់សម្គាល់ខាងលើ នីតិវិធីជាក់លាក់ទាក់ទងនឹងបញ្ហានេះ ត្រូវតែអនុវត្តតាម។ យោងតាមសំអាងហេតុនេះ ភស្តុតាងដែលពុំត្រូវបានដាក់នៅពេលជំនុំជម្រះ ជាគោលការណ៍គឺពុំអាចត្រូវបានពិនិត្យពិច័យនៅក្នុងបរិបទនៃបណ្តឹងសាទុក្ខឡើយ។

21. ជាករណីលើកលែងទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឱ្យដាក់ភស្តុតាងបន្ថែម ឬថ្មីលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៨(៧) ឬ ១០៤(១) នៃវិធានផ្ទៃក្នុង។ ពិតប្រាកដណាស់ នេះ គឺជាអ្វីដែលបានកើតឡើងទាក់ទងនឹងសាក្សីបីរូបដែលអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចកោះហៅនៅក្នុងសេចក្តីសម្រេចកោះហៅសាក្សីរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី ជាគោលការណ៍ និងស្របទៅតាមក្របខ័ណ្ឌផ្នែកច្បាប់ដែលបានលើកឡើងខាងលើ ភស្តុតាងជាឯកសារណាមួយ ដែលភាគីមានបំណងប្រើប្រាស់ក្នុងពេលសួរសាក្សី ត្រូវតែជាផ្នែកនៃភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលជំនុំជម្រះដែលអាចធ្វើបណ្តឹងសាទុក្ខ ឬត្រូវបានអនុញ្ញាតនៅពេលបណ្តឹងសាទុក្ខ តាមវិធាន ១០៨(៧) ឬ ១០៤(១) នៃវិធានផ្ទៃក្នុង។ ប្រសិនបើផ្ទុយពីនេះ ការស្តាប់សាក្សីបន្ថែមលើបណ្តឹងសាទុក្ខ អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការទទួលយកភស្តុតាងបន្ថែម បើទោះបីជា

---

42 សេចក្តីសម្រេចកោះហៅសាក្សី កថាខណ្ឌ ១៦។

43 សេចក្តីសម្រេចកោះហៅសាក្សី កថាខណ្ឌ ១៧។

ភស្តុតាងនេះ ពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យតឹងរ៉ឹងនៃវិធាន ១០៨(៧) និង ១០៤(១) នៃវិធានផ្ទៃក្នុង។ ចំណុចនេះ ត្រូវបានទទួលយកដោយសហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន[44]។ ទោះជាយ៉ាងណាក្តី ចំណុចនេះ ពុំអាចអនុវត្តបានលើចម្លើយពីមុនៗរបស់សាក្សី ដែលអង្គជំនុំជម្រះតុលាការកំពូលមានបំណងកោះហៅ។ ចម្លើយពីមុនៗនេះ គឺជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសក្ខីកម្មផ្ទាល់របស់សាក្សីដែលត្រូវបានរំពឹងទុក ដោយពុំចាំបាច់ឱ្យមានសេចក្តីសម្រេចដាច់ដោយឡែកពីគ្នា អនុលោមតាមវិធាន ១០៨(៧) និង ១០៤(១) នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះ ចម្លើយរបស់សាក្សី ពុំអាចរកបាន ដរាបណាសាក្សីពុំបានមកផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ។ អាស្រ័យហេតុនេះ បើនិយាយជាទូទៅ ចម្លើយពីមុនៗរបស់សាក្សីដែលទទួលបានក្នុងបរិបទនៃការជំនុំជម្រះ និងស៊ើបអង្កេតរបស់ អ.វ.ត.ក ឬដទៃទៀត អាចត្រូវបានប្រើប្រាស់ក្នុងការសួរសាក្សីនេះ។

22. អង្គជំនុំជម្រះតុលាការកំពូល ពុំបានយល់ស្របជាមួយនឹងអំណះអំណាងរបស់ នួន ជា ដែលថាសម្ភារៈណាមួយដែលអាចរកបានជាសាធារណៈ អាចត្រូវបានប្រើប្រាស់ក្នុងការសួរសាក្សី។ អំណះអំណាងនេះ ពុំបានលើកត្រឹមត្រូវពីមូលហេតុអ្វីបានជាការដែលអាចរកបានជាសាធារណៈនេះ អាចរំលាយលក្ខខណ្ឌតម្រូវស្តីពីភាពថ្មីឬប្លែកៗនៃភស្តុតាងឡើយ។ ដោយហេតុថា រឿងក្តីនៅចំពោះមុខនេះ ពាក់ព័ន្ធនឹងការចោទប្រកាន់នៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំសម្បើម ទើបទំនងជាមានឯកសារយ៉ាងច្រើនបែបនេះ។ ការទទួលយកឯកសារនេះជាភស្តុតាងនៅដំណាក់កាលបណ្តឹងសាទុក្ខ ដោយពុំបានពិចារណាលើលក្ខណៈវិនិច្ឆ័យនៃវិធាន ១០៨(៧) និង ១០៤(១) នៃវិធានផ្ទៃក្នុង ពុំអាចបំពេញតាមភាពសមហេតុផលនៃវិធានផ្ទៃក្នុង និងអាចឈានទៅរកការលំបាកយ៉ាងច្រើនក្នុងការរៀបចំកិច្ចដំណើរការនីតិវិធី។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ទាក់ទងនឹងបញ្ហានេះ ត្រូវបានបដិសេធចោល។

23. ទាក់ទងនឹងកាលៈទេសៈជាក់លាក់នៃរឿងក្តីចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា ឯកសារមួយចំនួននៅក្នុងបញ្ជីឯកសារ គឺជាកម្មវត្ថុនៃសំណើសុំដាក់ភស្តុតាងបន្ថែមរបស់ នួន ជា[45]។ អង្គជំនុំជម្រះតុលាការកំពូល ពុំបានសម្រេចលើសំណើទាំងនេះនៅឡើយ ហើយអង្គជំនុំជម្រះ

---

[44] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។ សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ៤ ដល់ ៦។ សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២០ ដល់ ២១។

[45] សំណើទីបួនរបស់ នួន ជា សុំពិចារណា លើភស្តុតាងបន្ថែម ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹង សាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/6។ សំណើទីប្រាំរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/7។

01185960



ពុំបានទទួលសារណាតបទាក់ទងនឹងសំណើទាំងនេះផងដែរ។ ដោយហេតុថា ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចេញសេចក្តីសម្រេចទាំងមូលលើសំណើទាំងនេះនៅមុនពេលសវនាការស្តាប់សាក្សី អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចអនុញ្ញាតឱ្យភាគីប្រើប្រាស់ឯកសារដែលជាកម្មវត្ថុនៃសំណើសុំដាក់ភស្តុតាងបន្ថែមនេះ ដរាបណាឯកសារទាំងនេះ មាននៅក្នុងបញ្ជីឯកសារនីមួយៗរបស់ខ្លួន។ ការអនុញ្ញាតនេះពុំបានប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើសុំដាក់ភស្តុតាងបន្ថែមឡើយ។

24. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់បន្ថែមទៀតថា នួន ជា បានលើកឡើងថា ឯកសារមួយចំនួននៅក្នុងបញ្ជីឯកសារ នឹងជាកម្មវត្ថុនៃសំណើសុំដាក់ភស្តុតាងបន្ថែម ដែលនឹងត្រូវដាក់នៅពេលអនាគត[46]។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល គ្រាន់តែការបង្ហាញពីចេតនារបស់ភាគីក្នុងការស្នើសុំដាក់ភស្តុតាងបន្ថែមក្នុងពេលអនាគត គឺពុំមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ឱ្យអង្គជំនុំជម្រះអនុញ្ញាតប្រើប្រាស់ឯកសារទាំងនោះក្នុងការសួរសាក្សីឡើយ។ អាស្រ័យហេតុនេះ សារណារបស់ នួន ជា ទាក់ទងនឹងបញ្ហានេះ ត្រូវបានបដិសេធចោល។

25. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពុំអនុញ្ញាតឱ្យភាគីប្រើប្រាស់ នៅក្នុងការសួរសាក្សីបីរូបនេះនៅក្នុងសវនាការខាងមុខនូវរាល់ឯកសារណាសំដៅលើបញ្ជីឯកសារនីមួយៗ ដែលពុំមាននៅក្នុងកំណត់ត្រាភស្តុតាងនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ឬកម្មវត្ថុនៃសំណើសុំដាក់ភស្តុតាងបន្ថែមឡើយ។

## VI. ឯកសារពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

### ក. បរិបទផ្នែកនីតិវិធី និងសារណា

26. ខៀវ សំផន កត់សម្គាល់ឃើញថា នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និង នួន ជា មានចម្លើយសារភាពដែលធ្វើឡើងនៅមន្ទីរ ស-២១ ("ចម្លើយសារភាពនៅមន្ទីរ ស-២១") និង ជំទាស់ទៅនឹងការប្រើប្រាស់ឯកសារទាំងនេះ នៅក្នុងសវនាការ ខែ កក្កដា ឆ្នាំ ២០១៥ ទាំងមូល[47] ដោយបានអះអាងថា

---

[46] សេចក្តីជំទាស់របស់ នួន ជា កថាខណ្ឌ ៧ ដល់ ៨។

[47] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥, ជើងទំព័រ ៨។ សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៤។ ឯកសារជាក់លាក់ដែលរងការជំទាស់ មានដូចជា៖ D312.2.25, D366/7.1.1.8, E3/1682, E3/1855, E3/2792, E3/3857, E3/3989, E3/4202។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ឯកសារលេខ E3/4202 ពុំមែនជាចម្លើយសារភាពទេ លើកលែងតែសៀវភៅដែលបានដកស្រង់ ឬសម្រួលឃ្លាឡើងវិញនូវចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរ ស-២១ រួមមានចម្លើយសារភាពរបស់ វស់ ញឹម។ យោងតាមប្រភពដើមនៃផ្នែកខ្លះរបស់ឯកសារនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកផ្នែកទាំងនេះ ដូចគ្នាទៅនឹងចម្លើយសារភាពដទៃទៀតនៅមន្ទីរ ស-២១។

01185961



ចម្លើយនេះ តាមការសន្មត បានទទួលតាមវិធីសាស្ត្រនៃការធ្វើទារុណកម្ម។ សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ ក្នុងការបញ្ជាក់នូវការពិតនៃបញ្ហាដែលបានសារភាព ប៉ុន្តែ អះអាងថា ចម្លើយទាំងនេះ អាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ពីកាលៈទេសៈផ្សេង ទៀត[48]។

27. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម គឺពុំអាចទទួលយកបាននៅគ្រប់កាលៈទេសៈទាំងអស់សម្រាប់ការស្វែរកការពិតចំពោះខ្លឹមសារនៃភស្តុតាងទាំងនេះ ដែលតាមគោលការណ៍បានផ្អែកលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[49] ដែលជាការលើកឡើងម្តងទៀតអំពីការយល់ឃើញពីដំបូងនៅក្នុងសំណុំរឿង ០០១[50]។ នួន ជា បានជំទាស់ទៅនឹងការសម្រេចនេះ នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[51]។ នៅក្នុងសំណុំរឿង ០០២/០២ ការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម គឺជាបញ្ហាដែលត្រូវពិភាក្សាសាឡើងវិញ[52]។

---

[48] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥ ជើងទំព័រ ៨។ សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៤។ ឯកសារជាក់លាក់ដែលត្រូវបានជំទាស់នោះ មាន៖D312.2.25, D366/7.1.1.8, E3/1682, E3/1855, E3/2792, E3/3857, E3/3989, E3/4202។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ឯកសារ E3/4202 ពុំមែនជាចម្លើយសារភាពដោយខ្លួនឯងផ្ទាល់នោះទេ ប៉ុន្តែគឺជាសៀវភៅដែលបានដកស្រង់ ឬសម្រួលឃ្លាឡើងវិញនូវចម្លើយសារភាពរបស់អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ រួមទាំងចម្លើយរបស់ រួស ញឹម ផងដែរ។ ដោយពិចារណាទៅលើប្រភពដើមនៃផ្នែកពាក់ព័ន្ធរបស់ឯកសារនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកផ្នែកទាំងនេះដូចគ្នាទៅនឹងចម្លើយដទៃទៀតនៅមន្ទីរ ស-២១។

[49] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងទណ្ឌកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកដទៃទៀត មហាសន្និបាតសេចក្តីសម្រេចលេខ 39/46, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/39/51 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧ (“CAT”)។

[50] *សូមមើល* សាលក្រមនៃសំណុំរឿង ០០/០១ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”) កថាខណ្ឌ ៣៥។ ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំ ឯកសារលេខ E67, E57, E56, E58, E23, E59, E20, E33, E71, និង E73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការនៅខែ មេសា ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E74 ទំព័រ ៣។

[51] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F16 កថាខណ្ឌ ៧០៦ ដល់ ៧២២។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/1/1 ទំព័រ ៧។ (ទង្វើករណ៍ ៣៦)។

[52] អង្គជំនុំជម្រះសាលាដំបូង បានទទួលសារណាជាលាយលក្ខណ៍អក្សរ ហើយបានបើកសវនាការផ្ទាល់មាត់លើបញ្ហានោះនៅថ្ងៃទី ២១ និង ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ជាបន្តបន្ទាប់។ *សូមមើល* សារណារបស់ នួន ជា ទាក់ទងនឹងការប្រើប្រាស់

28. ក្នុងសារណារបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងសវនាការនៅខែ កក្កដា ឆ្នាំ ២០១៥ នួន ជា ពុំបានលើកឡើងពីបំណងរបស់ខ្លួន ក្នុងការប្រើប្រាស់ចម្លើយសារភាពពីមន្ទីរ ស-២១ ឡើយ។ ទោះជាយ៉ាងណាក្តី នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន នួន ជា បានអះអាងថា នៅពេលដែលភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ពុំអាចត្រូវបានប្រើប្រាស់*ប្រឆាំងនឹង*ជនជាប់ចោទ ដូចនេះ ជនជាប់ចោទ អាចប្រើប្រាស់ភស្តុតាងនេះ ដើម្បីធ្វើជាមធ្យោបាយការពារខ្លួន ដែលក្នុងរឿងក្តីរបស់ នួន ជា គឺដើម្បីបង្ហាញថា មានការប៉ះទង្គិចផ្ទៃក្នុង កើតឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងបទចោទ[53]។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នួន ជា មានបំណងនឹងប្រើប្រាស់ចម្លើយសារភាពពីមន្ទីរ ស-២១ ក្នុងការសួរសាក្សីនៅក្នុងសវនាការនៅខែ កក្កដា ឆ្នាំ ២០១៥ នេះ ដោយផ្អែកលើយុត្តិកម្មដូចគ្នា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ នឹងធ្វើការពិចារណាទៅលើទឡ្ហីករណ៍របស់ នួន ជា ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ នៅពេលដែលអង្គជំនុំជម្រះ សម្រេចលើការជំទាស់នានាទៅលើការប្រើប្រាស់នូវចម្លើយសារភាពនៅមន្ទីរ ស-២១ នៅក្នុងសវនាការនោះ[54]។

---

"ភស្តុតាងបានមកពីការធ្វើទារុណកម្មក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E350 ("សារណារបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២")។ សារណារបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការអនុវត្តនូវអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មទៅលើចម្លើយសារភាពនៅមន្ទីរ ស-២១ និងកំណត់ហេតុដទៃទៀតពាក់ព័ន្ធនឹងការសួរចម្លើយអ្នកទោស ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E350/1 ("សារណារបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២")។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងភាពអាចទទួលយកបាន និងការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ E350/3 ("សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២")។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E350/4 ("សារណារបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២")។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/304.1 ទំព័រ ៣ ដល់ ៣៤។

[53] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧០៦ ដល់ ៧២២។ *សូមមើលផងដែរ* សារណារបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣ ដល់ ២៨។

[54] នួន ជា បានបញ្ជាក់ថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថា ភស្តុតាងបានមកពីការធ្វើទារុណកម្ម គឺមិនអាចទទួលយកបាននៅគ្រប់កាលៈទេសៈទាំងអស់សម្រាប់ការពិតនៃខ្លឹមសារនោះ ពុំបានមោឃៈសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ប៉ុន្តែបានផ្តល់សារៈសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧០៧។ ចម្លើយបែបនេះ លើកបញ្ហាអំពីភាពទទួលយកបានលើបណ្តឹងសាទុក្ខដែលប្រហាក់ប្រហែលគ្នាទៅនឹងបញ្ហាដែលបានលើកឡើង នៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ F11។ ការបញ្ចូលរបស់អង្គជំនុំជម្រះ

29. ជំហររបស់សហព្រះរាជអាជ្ញា គឺថា ចម្លើយសារភាពនៅមន្ទីរ ស-២១ ពុំអាចត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់ការពិតលើបញ្ហា ដែលត្រូវបានធ្វើឡើងតាមរយៈការធ្វើទារុណកម្ម[55] និងថា នួន ជា ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយនេះ ដើម្បីធ្វើយុត្តិកម្មលើឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមឡើយ។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាអះអាងថា ចម្លើយនៅមន្ទីរ ស-២១ អាចត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់លើអង្គហេតុពាក់ព័ន្ធដទៃទៀត ដូចជា អ្នកជាប់ឃុំឃាំង ដែលត្រូវបានចោទប្រកាន់ និងត្រូវបានសួរចម្លើយអំពីការលាក់បាំង ឬអំពីការខកខានក្នុងការសម្លាប់អ្នករដ្ឋការ លន់ នល់ ឬដូចជា ការសម្លាប់អ្នករដ្ឋការ លន់ នល់ ដែលស្ថិតក្នុងគោលនយោបាយនៃរបបនេះជាដើម[56]។ សហព្រះរាជអាជ្ញាបានបញ្ចូលទឡ្ហីករណ៍របស់ខ្លួន ដែលបានលើកឡើងពីដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[57] ដោយសង្ខេប ដើម្បីស្នើសុំធ្វើការបង្ហាញថា ករណីពិសេសចំពោះការហាមឃាត់មិនឱ្យប្រើប្រាស់នូវចម្លើយសារភាពពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ដែលមានចែងនៅក្នុងប្រយោគទីពីរនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនោះ ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដើម្បីជួយសម្រួលដល់ការបញ្ជាក់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដោយអ្នកធ្វើទារុណកម្ម ដែលត្រូវបានចោទប្រកាន់[58]។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ផ្អែកលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចម្លើយសារភាព គប្បីត្រូវបានដកចេញតែក្នុងករណីដែលចម្លើយនេះ ត្រូវបានរកឃើញថា ជាក់ស្តែង ពិតជាបានមកពីការធ្វើទារុណកម្មតែប៉ុណ្ណោះ[59]។

30. ផ្អែកលើការលើកឡើងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូល បានកំណត់ជាសំណួរសំខាន់ជាបីផ្នែកក្នុងការពិចារណាលើបញ្ហានៅចំពោះមុខដូចតទៅ៖ (១)ថាតើ ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ចម្លើយនៅមន្ទីរ ស-២១ បានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម ដែរ ឬយ៉ាងណា (២)ថាតើ នួន ជា អាចប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ ដើម្បីជួយដល់ការការពារខ្លួនបាន ដែរ ឬយ៉ាងណា និង (3)ថាតើ សហព្រះរាជអាជ្ញា អាចប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ ធ្វើជាភស្តុតាងបញ្ជាក់ពីអង្គហេតុដែលពុំជាប់ពាក់ព័ន្ធនឹងការពិតនៃខ្លឹមសាររបស់ចម្លើយនេះបាន ដែរ ឬយ៉ាងណា។ ទោះជាយ៉ាងណាក៏ដោយជាដំបូង អង្គជំនុំជម្រះតុលាការកំពូល នឹងចាប់ផ្តើមពិភាក្សាលើច្បាប់ជាធរមាន។

---

តុលាការកំពូលនូវសេចក្តីយោងនៃទឡ្ហីករណ៍របស់ នួន ជា លើបណ្តឹងសាទុក្ខទាក់ទងទៅនឹងភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ពុំគប្បីត្រូវបានបកស្រាយថាជាការសម្រេចទុកជាមុនស្តីពីភាពអាចទទួលយកបាននៃភស្តុតាងនេះ។

[55] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[56] ការជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥ ដល់ ៦, ជើងទំព័រ ១១។

[57] ការជំទាស់របស់សហព្រះរាជអាជ្ញា ជើងទំព័រ ៩ ដល់ ១០។

[58] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៧។

[59] ការជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

## ខ. ច្បាប់ជាធរមាន

31. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[60] ("រដ្ឋធម្មនុញ្ញកម្ពុជា") និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[61] មានចែងអំពីការហាមឃាត់ទាក់ទងនឹងការប្រើប្រាស់នូវភស្តុតាង ដែលបានមកតាមរយៈការបង្ខិតបង្ខំលើរូបរាងកាយ ឬលើផ្លូវចិត្ត។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី ឬផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ"។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបញ្ជាក់ថា "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី" និងបានចែងបន្តទៀតថា "ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង"។ យោងតាមវិធានបដិសេធភស្តុតាង មាត្រា ៣២១ ចែងថា "ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ និងខាងផ្លូវចិត្ត នេះគ្មានតម្លៃជាភស្តុតាងទេ"។ ការដាក់បញ្ចូលនូវវិធានបដិសេធភស្តុតាងទៅក្នុងបទប្បញ្ញត្តិ ដែលដោះស្រាយជាទូទៅជាមួយនឹងភាពអាចទទួលយកបាននៃភស្តុតាង និងការប្រើពាក្យ"ចម្លើយ" បើប្រៀបជាមួយនឹងពាក្យ"ការសារភាព" (ពាក្យនេះត្រូវបានប្រើក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា) បង្ហាញថា ការហាមឃាត់ក្នុងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺគ្របដណ្តប់លើព័ត៌មានណាដែលទទួលបាន ក្រោមការបង្ខិតបង្ខំ មិនត្រឹមតែចម្លើយរបស់ជនជាប់ចោទប៉ុណ្ណោះទេ។

32. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដូចគ្នានឹងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថាជាវិធាន "រាល់ភស្តុតាងទាំងអស់ អាចជូនបានដោយសេរី" លើកលែងតែ *ក្នុងចំណោមនោះ* ភស្តុតាងនេះ "ពុំមានច្បាប់ណាអនុញ្ញាតឡើយ"[62]។ ជាពិសេស ទាក់ទងនឹងចំណុចនេះ វិធាន ២១(៣) នៃវិធានផ្ទៃក្នុងដែលត្រូវបានបញ្ចូលនៅក្រោមចំណងជើងថា "**គោការណ៍ជាសារវ័ន្ត**" បានចែងថាៈ

> គ្មានទម្រង់ណាមួយនៃការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬការគំរាមកំហែងណា ត្រូវបានយកទៅអនុវត្តក្នុងពេលធ្វើសម្ភាសន៍ ចំពោះអ្នកដែលត្រូវបានសួរយកចម្លើយ ឬអ្នកដទៃទៀតឡើយ។ ប្រសិនបើទម្រង់ណាមួយនៃស្ថានភាពទាំងនេះ ត្រូវបានប្រើប្រាស់នោះ ចម្លើយ ឬកំណត់ហេតុ មិនត្រូវបាន

---

[60] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ដែលត្រូវបានអនុម័តដោយសម័យប្រជុំរដ្ឋធម្មនុញ្ញនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានផ្សព្វផ្សាយឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

[62] វិធាន ៨៧(៣)(ខ) នៃវិធានផ្ទៃក្នុង។

ចាត់ទុកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ ហើយអ្នកទទួលខុសត្រូវចំពោះករណីនេះ ត្រូវទទួលការដាក់វិន័យសមស្របទៅនឹងកំហុសដោយអនុលោមតាមវិធាន ៣៥ ដល់ វិធាន ៣៨។

អាស្រ័យហេតុនេះ អនុលោមតាមវិធាន ២១(៣) នៃវិធានផ្ទៃក្នុង ព័ត៌មានដែលទទួលបានក្រោមការបង្ខិតបង្ខំ ពុំអាចទទួលយកបានជាភស្តុតាងឡើយ ដោយមិនគិតថា ភស្តុតាងនេះ បានមកពីជនជាប់ចោទ ឬជនដទៃផ្សេងទៀតឡើយ។ ទោះជាយ៉ាងណាក្តី វិសាលភាពនៃបទប្បញ្ញត្តិនេះ ទំនងជាកម្រិតត្រឹមតែព័ត៌មានដែលប្រមូលបានដោយស្ថាប័នរបស់ អ.វ.ត.ក តែប៉ុណ្ណោះ។ ហេតុនេះ វិធានផ្ទៃក្នុង ពុំបានចែងឱ្យបានទូលំទូលាយស្តីពីវិធានបដិសេធភស្តុតាង ដែលស្ទើរតែដូចគ្នាទៅនឹងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលជាទូទៅ បានហាមឃាត់ការទទួលយកភស្តុតាងដែលអាចធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[63]។

---

[63] *សូមមើល* លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ A/CONF.183/9 អនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ មាត្រា ៦៩(៧) ("ភស្តុតាងដែលទទួលបានតាមមធ្យោបាយបំពានលើច្បាប់លក្ខន្តិកៈនេះ ឬបំពានលើសិទ្ធិមនុស្សទាំងឡាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ មិនត្រូវអាចទទួលយកបានឡើយ ប្រសិនបើៈ (ក) ការបំពាននាំឱ្យមានវិមតិសង្ស័យយ៉ាងច្រើនលើការជឿទុកចិត្តបាន ឬ (ខ) ការទទួលយកភស្តុតាងទំនងជាផ្ទុយនឹង និងទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុចរិតភាពនៃដំណើរការជម្រះរឿងក្តី")។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) វិធានស្តីពីនីតិវិធី និងភស្តុតាង, IT/32/ វិសោធនកម្មលើកទី ៥០ ត្រូវបានអនុម័តកាលពីថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤, វិសោធនកម្មនៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥ ("វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICTY"), វិធាន ៩៥ ("ភស្តុតាង នឹងមិនត្រូវបានទទួលយកឡើយ ប្រសិនបើបានទទួលតាមមធ្យោបាយដែលបង្កវិមតិសង្ស័យទៅលើភាពអាចជឿបាននៃភស្តុតាង ឬប្រសិនបើការទទួលយកភស្តុតាងនោះមិនស៊ីសង្វាក់ និងប៉ះពាល់ធ្ងន់ធ្ងរដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី")។ តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន (SCSL), វិធានស្តីពីនីតិវិធី និងភស្តុតាង, អនុម័តថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០២, វិសោធនកម្មថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២, វិធាន ៩៥ ("ភស្តុតាងមិនត្រូវបានទទួលយក ប្រសិនបើនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការយុត្តិធម៌")។ ការគ្រប់គ្រងផ្នែករដ្ឋបាលអន្តរកាលរបស់អង្គការសហប្រជាជាតិនៅក្នុងអ៊ីសទីម័រ(UNTAET), បទបញ្ជាលេខ ២០០០/៣០ ស្តីពីវិធានអន្តរកាលនៃក្រមនីតិវិធីព្រហ្មទណ្ឌ, UNTAET/REG/2000/30, អនុម័តនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០០ វិសោធនកម្មនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១ វិធាន ៣៤(២) ("តុលាការ អាចដកភស្តុតាងណាមួយ ប្រសិនបើតម្លៃនៃភស្តុតាងពុំសូវសំខាន់ជាងអានុភាពនៃការប៉ះពាល់ ឬដោយសារគ្រួតគ្នាជាមួយនឹងភស្តុតាងដទៃទៀត។ ពុំមានភស្តុតាងត្រូវបានទទួលយក ប្រសិនភស្តុតាងនេះបានធ្វើឡើងតាមវិធីសាស្ត្រដែលធ្វើឱ្យមានភាពសង្ស័យយ៉ាងខ្លាំងទៅលើភាពអាចទុកចិត្តបាន ឬប្រសិនបើ ការទទួលយកភស្តុតាងនេះ អាចនឹងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ និងមានលក្ខណៈផ្ទុយទៅនឹងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី រួមទាំងលក្ខខណ្ឌស្តីពីភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្ម ការបង្ខំ ឬការគំរាមកំហែង ដល់បូរណភាពនៃរូបកាយ")។ តុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) វិធានស្តីពីនីតិវិធី និងភស្តុតាងអនុម័តនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩ វិសោធនកម្មនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ វិធាន ១៦២ (ការដកចេញនូវភស្តុតាងមួយចំនួនៈ ("(ក) ពុំមានភស្តុតាងណាត្រូវបានទទួលយកឡើយ ប្រសិនបើ ភស្តុតាងនោះ បានមកតាមវិធីដែលធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងទៅលើភាពអាចទុកចិត្តបាននៃភស្តុតាងនេះ ឬ

33. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចែងអំពីវិធានបដិសេធភស្តុតាងពាក់ព័ន្ធនឹងចម្លើយដែលបានទទួលតាមរយៈការធ្វើទារុណកម្មថា៖

> រដ្ឋភាគីនីមួយៗត្រូវធានាថា ចម្លើយណាមួយដែលបានបង្ហាញថា បានធ្វើឡើងដោយសារការធ្វើទារុណកម្ម ពុំត្រូវបានអនុញ្ញាតឱ្យយកមកប្រើប្រាស់ជាភស្តុតាងនៅក្នុងរាល់កិច្ចដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែប្រើប្រាស់ប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងបញ្ជាក់ថាចម្លើយនេះពិតជាបានធ្វើឡើងប៉ុណ្ណោះ។

34. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខ្លឹមសារដែលមានលក្ខណៈជាបទដ្ឋានក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺមានភាពច្បាស់លាស់គ្រប់គ្រាន់ ដោយពុំចាំបាច់ផ្អែកលើការធ្វើនីតិកម្ម ដើម្បីអាចអនុវត្តបាននោះឡើយ[64]។ បន្ថែមលើនេះទៀត ដោយយោងទៅលើរដ្ឋធម្មនុញ្ញកម្ពុជា មាត្រានេះ អាចអនុវត្តបានដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជា ដោយហេតុថា កម្ពុជា បានផ្តល់សច្ចាបន៍លើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ និងថា មាត្រា ៣១(១) នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិការសញ្ញា

---

ប្រសិនបើទទួលយក គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងផ្ទុយទៅនឹងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី (ខ) ជាពិសេស ភស្តុតាងនេះត្រូវបានដកចេញប្រសិនបើបានទទួលមកពីការរំលោភបំពានលើបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស រួមមានការហាមឃាត់ការធ្វើទារុណកម្ម")។

[64] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចន្លោះប្រហោងពាក្យពេចន៍នៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ពុំមានន័យថា ចាំបាច់ត្រូវមាននីតិកម្មឡើយ ប៉ុន្តែ ពាក្យពេចន៍នេះ បង្ហាញពីការគោរពទៅតាមនីតិកម្មថ្មី ឬមានស្រាប់ដែលថា ប្រព័ន្ធច្បាប់របស់រដ្ឋភាគីនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម អាចអនុម័តដើម្បីអនុវត្តនូវកាតព្វកិច្ចដែលកើតចេញពីបញ្ញត្តិនោះ (គោលការណ៍ណែនាំស្តីពីទម្រង់ និងខ្លឹមសារនៃរបាយការណ៍ដំបូងតាមមាត្រា ១៩ ដែលត្រូវបានលើកឡើងដោយរដ្ឋភាគីចំពោះសន្ធិសញ្ញាប្រឆាំងនឹងការធ្វើទារុណ CAT/C/4/វិ. លើកទី ៣១៨ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៤)។ ត្រង់ប្រការនេះ គួរកត់សម្គាល់ថានៅពេលផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មក្នុងឆ្នាំ ១៩៨៧ ប្រទេសអូទ្រីសបានប្រកាសថា ខ្លួន "ចាត់ទុកមាត្រា ១៥ ជាមូលដ្ឋានផ្នែកច្បាប់សម្រាប់ភាពមិនអាចឲ្យទទួលយកបាននៃភស្តុតាងដែលមានចែងនៅទីនោះស្តីពីការប្រើប្រាស់ចម្លើយ ដែលត្រូវបានបង្ហាញថា បានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម" ផ្ទុយទៅវិញសហរដ្ឋអាមេរិកបានប្រកាសថា បន្ទាប់ពីការធ្វើសច្ចាប័នលើសន្ធិសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម "មាត្រា ១ ដល់ ១៦ នៃសន្ធិសញ្ញា ពុំអាចអនុវត្តបានដោយខ្លួនឯងឡើយ" (សន្ធិសញ្ញាពហុភាគីបានតម្កល់នៅអគ្គលេខាធិការស្តីពីឋានៈ កាលពី ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ ច្បាប់ទី I ផ្នែកទី I ST/LEG/SER.E/26, ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិឆ្នាំ ២០០៩ ទំព័រ ៣៦០ និង ៣៦៣ ដល់ ៣៦៤)។

ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"[65]។ ការយល់ឃើញនេះមានលក្ខណៈស្របគ្នាជាមួយនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដែលបានសម្រេចថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺជាផ្នែកមួយនៃ"ច្បាប់" ដោយបានយោងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង[66]។ អង្គជំនុំជម្រះសាលាដំបូង ទំនងជាមានគោលជំហរដូចគ្នា ដោយបានយល់ឃើញថា អង្គជំនុំជម្រះ "ត្រូវបានចងកាតព្វកិច្ចដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម" ដែលបាន"ឆ្លុះបញ្ចាំង" នៅក្នុងវិធាន ២១(៣) នៃវិធានផ្ទៃក្នុង និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា[67]។

---

[65] ទាក់ទងការអនុវត្តថ្នាក់ជាតិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ឯកសារលេខ 131/003/2007 សេចក្តីសម្រេចលេខ 092/003/2007 ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧។ សេចក្តីសម្រេចនេះ ត្រូវបានឯកភាពដោយគណកម្មាធិការអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលយើងយល់ន័យរបស់វាថា "សន្ធិសញ្ញាអន្តរជាតិជាផ្នែកមួយនៃច្បាប់ជាតិ ហើយតុលាការគប្បីពិចារណាអំពីនិយាមសន្ធិសញ្ញា នៅពេលបកស្រាយច្បាប់ និងសម្រេចរឿងក្តី" (សេចក្តីសង្កេតបញ្ចប់របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម(កម្ពុជា), CAT/C/KHM/CO/2 ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ១០)។

[66] សាលដីកាសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D130/9/21 ("សាលដីកាសម្រេចរបស់ អ.ប.ជ ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងដែលបានពីការធ្វើទារុណកម្ម" កថាខណ្ឌ ២៧។ សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម, ទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D130/7/3/5 ("សាលដីកាសម្រេចលើកទីពីររបស់ អ.ប.ជ ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងដែលបានពីការធ្វើទារុណកម្ម") កថាខណ្ឌ ៣៥។

[67] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៥ ដកស្រង់ប្រតិចារឹកថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E1/2.1 ទំព័រ ៧៨ និង ៧៩។ ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើ ឯកសារលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 បន្ទាប់កិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E74 ទំព័រ ៣។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកនៅក្នុងឯកសារលេខ E114, E114/1, E131/1/9, E131/6, E136 និង E158" ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E162 កថាខណ្ឌ ៩។ សេចក្តីសម្រេចស្តីពីសេចក្តីជំទាស់ទៅនឹងឯកសារដែលបានស្នើឡើងឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលនៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញាចំណុច AI-A5 និងទៅនឹងឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងពីរផ្នែកនៃការជំនុំជម្រះលើកដំបូង នៃសំណុំរឿង០០២/០១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E185 កថាខណ្ឌ ២១។ ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២

35. ចំពោះទំនាក់ទំនងរវាងវិធានបដិសេធភស្តុតាងដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងវិធានបដិសេធភស្តុតាងនៅក្នុងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលវិធានទាំងពីរនេះ អាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក មានចំណុចគួរកត់សម្គាល់មួយបានឱ្យដឹងថា បទប្បញ្ញត្តិច្បាប់ទាំងពីនេះ ពុំមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ។ វិធានបដិសេធភស្តុតាងនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានរួមបញ្ចូលនូវពាក្យ "គ្រប់កិច្ចដំណើរការនីតិវិធី" ដូចនេះ បានគ្របដណ្តប់លើសពីដំណើរការនីតិវិធីព្រហ្មទណ្ឌទៅទៀត។ ដូចគ្នាដែរ វិធាននេះ គ្របដណ្តប់តែលើព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្មតែប៉ុណ្ណោះ ដែលវិធាននេះត្រូវបានកំណត់អត្ថន័យយ៉ាងចង្អៀតដូចខាងក្រោម៖

> សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ការធ្វើទារុណកម្ម" គឺជាអំពើណាមួយដែលបង្កឱ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរខាងផ្លូវចិត្ត ឬផ្លូវកាយដោយចេតនាទៅលើបុគ្គលម្នាក់ក្នុងគោលបំណងដើម្បីទទួលបានពីបុគ្គលនោះ ឬតតីយជន នូវព័ត៌មាន ឬចម្លើយសារភាព និងក្នុងគោលបំណងដាក់ទោសលើបុគ្គលនោះ ពីអំពើមួយដែលបុគ្គលនោះ ឬតតីយជនបានប្រព្រឹត្ត ឬត្រូវបានសង្ស័យថាបានប្រព្រឹត្ត ឬក្នុងគោលបំណងដើម្បីបំភិតបំភ័យ ឬគំរាមកំហែងបុគ្គលនោះ ឬតតីយជន ឬដោយសារហេតុផលនៃការរើសអើងណាមួយ ដែលបង្កឱ្យមានការឈឺចាប់ ឬការរងទុក្ខដោយសារការញុះញង់ ឬដោយមានការយល់ព្រម ឬស្រុះស្រួលពីមន្ត្រីសាធារណៈ ឬបុគ្គលដទៃទៀត ដែលបានបំពេញភារកិច្ចក្នុងសមត្ថកិច្ចជាផ្លូវការ។ ការធ្វើទារុណកម្មនេះ ពុំរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខដែលកើតចេញពី ឬមានជាប់ជាមួយនឹង ឬជាការបន្ទាប់បន្សំទៅនឹងការដាក់ទណ្ឌកម្មស្របច្បាប់ឡើយ[68]។

36. ម្យ៉ាងវិញទៀត វិធានបដិសេធភស្តុតាងនៅក្នុងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងយ៉ាងទូលំទូលាយជាងទៅលើពាក្យ "ការបង្ខិតបង្ខំខាងរូបកាយ និងខាងផ្លូវចិត្ត"។ លើសពីនេះទៀត មាត្រានេះពុំបានចែងអំពីករណីលើកលែងណាមួយឡើយ ដែលខុសប្លែកពីមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

---

ឯកសារលេខ E1/129.1 ទំព័រ ៥៩ ("អង្គជំនុំជម្រះយល់ស្របជាឯកច្ឆន្ទថា ចម្លើយបានមកពីការធ្វើទារុណកម្មដែល ផ្ទុយទៅនឹងបទប្បញ្ញត្តិនៃសន្ធិសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនអាចធ្វើជាមូលដ្ឋាននៃការចោទសួរ ឬភស្តុតាងបានឡើយ")។ *សូមមើលផងដែរ*ប្រតិចារឹកថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ E1/27.1, ទំព័រ ៣១។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់ភាគីសុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E176 កថាខណ្ឌ ៨។

[68] មាត្រា ១ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

37. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមុខនាទីពីរ។ ទីមួយ មាត្រានេះ អនុវត្តតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនៅក្នុងបរិបទនៃនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះ មាត្រានេះ ចាំបាច់ត្រូវបកស្រាយឱ្យស្របជាមួយនឹងខ្លឹមសារដែលមានលក្ខណៈបទដ្ឋាននៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[69]។ អាស្រ័យហេតុនេះ ករណីលើកលែង ដែលអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មាន ដែលបានមកពីការធ្វើទារុណកម្មនៅក្រោមលក្ខខណ្ឌដែលបានកំណត់នៅក្នុងប្រយោគទីពីរនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺពុំត្រូវបានលុបបំបាត់ចោល នៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ដោយហេតុថា មាត្រា ៣២១ ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីករណីលើកលែងនេះឡើយ។ ទីពីរ មាត្រានេះ បានពង្រីកវិធានបដិសេធភស្តុតាងហួសពីលក្ខខណ្ឌយ៉ាងតឹងរ៉ឹងនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដោយគ្របដណ្តប់ព័ត៌មាន"ដែលបានទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ និងផ្លូវចិត្ត" បើទោះបីជាពុំមានលក្ខណៈដូចគ្នាទៅនឹងការធ្វើទារុណកម្មនៅក្នុងលក្ខខណ្ឌនៃមាត្រា ១ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មយ៉ាងណាក៏ដោយ។ ដូច្នេះ មានន័យថា នៅពេលដែលភស្តុតាង ពុំអាចទទួលយកបានតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម វារិតតែពុំអាចទទួលយកបានតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ។ ប៉ុន្តែផ្ទុយមកវិញ ភស្តុតាងដែលអាចទទួលយកបានតាមមាត្រា ១៥ នៅតែពុំអាចទទួលយកបានតាមមាត្រា ៣២១ ទាំងស្រុងឡើយ។

38. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា នួន ជា និងសហព្រះរាជអាជ្ញា ពុំបានជំទាស់ទៅនឹងការអនុវត្តនៃវិធានបដិសេធភស្តុតាង ដែលមាននៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មទៅលើកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឡើយ។ ផ្ទុយទៅវិញ ពួកគេ បានស្នើសុំឱ្យមានការកម្រិតលើវិសាលភាពនៃការហាមឃាត់ចំពោះការប្រើប្រាស់ភស្តុតាង ដែលបានមកពីការធ្វើទារុណកម្មសម្រាប់ហេតុក្នុងការប្រើប្រាស់ ឬភាពចាំបាច់នៅក្នុងកាលៈទេសៈដែល តាមទស្សនៈរបស់ខ្លួន ពុំស្ថិតក្នុង

---

[69] របាយការណ៍ដំបូងរបស់រដ្ឋភាគីចេញក្នុងឆ្នាំ ១៩៩០ (ចក្រភពអង់គ្លេស) CAT/C/9/Add.6, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩១ កថាខណ្ឌ ១២១ ដល់ ១២៣។ *រឿងក្តី Xuncax ទល់នឹង Gramajo*, សំណុំរឿងលេខ 886 F សេចក្តីបំពេញបន្ថែមលេខ 162 (D. Mass. 1995) ទំព័រ ១៩៣ (មូលដ្ឋាននៃគោលការណ៍ដែលមានចែងអំពីច្បាប់ទម្លាប់អន្តរជាតិ ត្រូវបានស្រូបបញ្ចូល និងរួមបញ្ចូលដោយប្រព័ន្ធច្បាប់អង់គ្លូសាក់សុងនៃសហព័ន្ធ)។ របាយការណ៍ដំបូងរបស់រដ្ឋភាគីចេញក្នុងឆ្នាំ ១៩៩៩ (សហរដ្ឋអាមេរិក) CAT/C/28/Add.5, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០០ កថាខណ្ឌ ១១, ៤៩ និង៥៨។ របាយការណ៍ប្រចាំលើកទី ៦ របស់រដ្ឋភាគីចេញក្នុងឆ្នាំ ២០០៨ (ប្រទេសកាណាដា), CAT/C/CAN/6, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៣។ របាយការណ៍ប្រចាំលើកទីប្រាំរបស់រដ្ឋភាគីចេញក្នុងឆ្នាំ ២០០៨ (ចក្រភពអង់គ្លេស និង Northern Ireland), CAT/C/GBR/5, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៤, ១១០ និង ៥០៤។

វិសាលភាពនៃមាត្រា ១៥ របស់អនុសញ្ញានៃការធ្វើទារុណកម្ម។ អំណះអំណាងរបស់ភាគី បានផ្ដោតលើបទប្បញ្ញត្តិនេះ និងដូច្នេះបញ្ញត្តិនេះនៅតែជាមូលដ្ឋានសំខាន់ ក្នុងការយោងសម្រាប់ការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូល។ លក្ខខណ្ឌតម្រូវបានកំណត់ថា បើទោះបីជាអំណះអំណាងនោះ មានលក្ខណៈគួរឱ្យជឿជាក់បាន ដោយអនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មក៏ដោយ ក៏អំណះអំណាងរបស់ភាគីនេះ ពុំអាចនឹងទទួលបានជោគជ័យដែរ ទាក់ទងនឹងវិធានបដិសេធភស្តុតាង ផ្អែកតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

39. យោងតាមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញា (“VCLT”)[70] សន្ធិសញ្ញាអន្តរជាតិ ត្រូវតែបកស្រាយ“តាមអត្ថន័យសាមញ្ញដើម្បីឱ្យសមស្របទៅតាមលក្ខខណ្ឌនៃសន្ធិសញ្ញា តាមបរិបទ និងស្របតាមកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះ”។ លើសពីនេះទៀត កិច្ចព្រមព្រៀងណាមួយរវាងភាគីទាក់ទងនឹងការបកស្រាយសន្ធិសញ្ញា ការអនុវត្តដែលធ្វើឡើងតាមក្រោយដើម្បីបង្កើតកិច្ចព្រមព្រៀងរវាងភាគីទាក់ទងនឹងការបកស្រាយ និងវិធានពាក់ព័ន្ធនានានៃច្បាប់អន្តរជាតិដែលអាចអនុវត្តបានចំពោះភាគី ត្រូវបានយកមកពិចារណា[71]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងការបកស្រាយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គប្បីផ្ដល់ទម្ងន់ទៅលើការអនុវត្តរបស់គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលការបកស្រាយរបស់ពួកគេលើសន្ធិសញ្ញា ត្រូវបានចាត់ទុកថាមាន“អំណាចផ្លូវច្បាប់”[72]។ ម្យ៉ាងវិញទៀត ការបកស្រាយអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ត្រូវបានធ្វើឡើងតាមរយៈការវិភាគប្រៀបធៀបជាមួយសន្ធិសញ្ញាអន្តរជាតិ ឬក្នុងតំបន់ដែលប្រហាក់ប្រហែលស្ដីពីសិទ្ធិមនុស្ស និងច្បាប់យុត្តិសាស្ត្រ និងការអនុវត្តរបស់ស្ថាប័នដែលត្រួតពិនិត្យសិទ្ធិមនុស្សនានា[73]។ ទាក់ទងនឹងបញ្ហានេះ ច្បាប់យុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់គណៈកម្មាធិការនៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (“គណៈកម្មាធិការនៃសិទ្ធិមនុស្ស”) និងរបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (“ECtHR”) បានផ្ដល់ជាសេចក្ដីណែនាំជាពិសេសទៅលើចំណុចស្ដីពីនីតិវិធីនៃមាត្រា ១៥ នៅក្នុងផ្នែកទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងការពិចារណាទៅលើនីតិវិធីនៃមាត្រា

---

70 អង្គការសហប្រជាជាតិ *អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញា* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៦៩ អង្គការសហប្រជាជាតិ ស៊េរីនៃសន្ធិសញ្ញាភាគ ១១៥៥ ទំព័រ ៣៤០។

71 *សូមមើល*មាត្រា ៣១(៣) នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា។

72 សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur, ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម៖ សេចក្ដីអធិប្បាយ* ទំព័រ ១២។

73 សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur, ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម៖ សេចក្ដីអធិប្បាយ* ទំព័រ ១២។

១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ លើសពីនេះទៀត មាត្រា ៣២ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា បានអនុញ្ញាតឱ្យស្វែងរកមធ្យោបាយបំពេញបន្ថែមដើម្បីបកស្រាយ មានដូចជា *ឯកសារព្រាង* ដើម្បីបញ្ជាក់ពីអត្ថន័យនៃការអនុវត្តលើមាត្រា ៣១ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា ឬដើម្បីកំណត់នូវអត្ថន័យ នៅពេលដែលការបកស្រាយអនុលោមមាត្រា ៣១ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា មានអត្ថន័យមិនច្បាស់លាស់ ឬស្រពេចស្រពិល ឬបណ្តាលឱ្យមានភាពមិនសមហេតុសមផលច្បាស់ក្រឡែតនោះ។

40. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា លក្ខខណ្ឌក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មានលក្ខណៈជាក់ច្បាស់ឥតព្រលាំដោយហេតុថា៖ ពេលអានផ្ទួបគ្នាជាមួយនឹងមាត្រា ១ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលបានកំណត់ការធ្វើទារុណកម្មថា ក្នុងចំណោមនោះ ជាគោលបំណងដើម្បីកំហែងយកការសារភាព ឬព័ត៌មាន មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានហាមឃាត់ការប្រើប្រាស់ព័ត៌មានបានមកដោយសារការធ្វើទារុណ ដែលគ្មានគុណវុឌ្ឍិអ្វីសោះឡើយ ក្រៅតែពីករណីលើកលែងចំពោះការហាមឃាត់នេះ ដូចដែលមានចែងក្នុងប្រយោគទីពីរនៃមាត្រានេះ។ ការអះអាងរបស់ភាគីដែលថា ការហាមឃាត់នេះ បានកម្រិតយ៉ាងខ្លាំង និងជាគោលការណ៍ពុំបានពង្រីកឱ្យហួសពីព័ត៌មាន ដែលមានប្រយោជន៍សម្រាប់ភាគីការពារក្តីនោះ ពុំអាចលើកយកមកការពារបានដោយគ្រាន់តែផ្អែកទៅលើភាសានៃបទប្បញ្ញត្តិនេះតែឯងប៉ុណ្ណោះបានឡើយ ដូច្នេះ ត្រូវតែយកមកពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃវិធានបដិសេធភស្តុតាង។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានកំណត់ពីកម្មវត្ថុ និងគោលបំណងរបស់ខ្លួនក្នុងការទទួលស្គាល់សិទ្ធិមនុស្សដែលមិនអាចដកហូតបាន និងសេចក្តីថ្លៃថ្នូរ ដែលមានជាប់ជាមួយនឹងបុគ្គលម្នាក់ៗ និងបានបញ្ជាក់ពីគោលបំណងក្នុងការជម្រុញឱ្យមានការខិតខំតស៊ូប្រឆាំងនឹងការធ្វើទារុណកម្ម"ឱ្យកាន់តែមានប្រសិទ្ធិភាព"ទូទាំងពិភពលោក[74] ហើយបានសង្កត់ធ្ងន់ទៅលើការហាមឃាត់ប្រឆាំងនឹងការធ្វើទារុណកម្ម ដែលមានលក្ខណៈដាច់ខាត និងពុំអាចធ្វើបដិប្បញ្ញត្តិបានឡើយ[75]។ ហេតុនេះ ការបកស្រាយណាមួយលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬលើផ្នែកសំខាន់ណាមួយក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលនាំឱ្យការហាមឃាត់ និងការរារាំងប្រឆាំងនឹងការធ្វើទារុណកម្ម ចុះខ្សោយនោះ ត្រូវតែបដិសេធចោល។ ម្យ៉ាងទៀត ក្នុងការជម្រុញដល់កម្មវត្ថុ និងគោលបំណងដែលជាការរារាំងការធ្វើទារុណកម្ម គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានសង្កត់ធ្ងន់ថា កាតព្វ

[74] *សូមមើល* បុព្វកថានៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

[75] *សូមមើល* បុព្វកថា*និង* មាត្រា ២(២) នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

កិច្ចរបស់រដ្ឋក្នុងការចាត់វិធានការរារាំងយ៉ាងមានប្រសិទ្ធភាព គឺសំខាន់ជាងកម្មវត្ថុដែលបានរៀបរាប់យ៉ាងពិសេសនៅក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មទៅទៀត[76]។ អាស្រ័យហេតុនេះ កម្មវត្ថុ និងគោលបំណងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ជាចម្បង គឺដើម្បីរារាំងការធ្វើទារុណកម្ម និងជាការបង្អាក់ទឹកចិត្តមិនឱ្យប្រើប្រាស់អំពើនេះ ដែលជៀសវាងនូវលទ្ធភាពក្នុងការលើកយកព័ត៌មានដែលបានមកពីការធ្វើទារុណកម្មនោះមកបញ្ចូលនៅក្នុងកិច្ចដំណើរការនីតិវិធីជាផ្លូវការណាមួយជាដើម[77]។

41. ហេតុផលសមស្របមួយផ្សេងទៀតសម្រាប់វិធានបដិសេធភស្តុតាង គឺកាតព្វកិច្ចក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទឱ្យទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ដូចនេះ ការអនុវត្តដែលជាមូលដ្ឋានសំខាន់បំផុតលើវិធានបដិសេធភស្តុតាង បានបដិសេធចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្មមិនឱ្យប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងបុគ្គលដែលជាជនរងគ្រោះនៃការធ្វើទារុណកម្មឡើយ បើទទួលយកភស្តុតាងនេះ គឺជាការរំលោភបំពានលើសិទ្ធិនៅស្ងៀមមិនឆ្លើយតប និងមិនឆ្លើយដាក់បន្ទុកខ្លួនឯង ដែលសិទ្ធិទាំងនេះត្រូវបានទទួលស្គាល់យ៉ាងច្បាស់ក្រឡែតក្នុងមាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពី

---

[76] សេចក្តីអធិប្បាយទូទៅ លេខ ២ កថាខណ្ឌ ២៥, CAT/C/GC/2, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ ("សេចក្តីអធិប្បាយទូទៅ លេខ ២"), កថាខណ្ឌ ២៥។

[77] *សូមមើល*គណៈកម្មាធិការនៃសិទ្ធិមនុស្ស សេចក្តីអធិប្បាយទូទៅ លេខ ២៖ មាត្រា ៧ (ការហាមឃាត់ការធ្វើទារុណកម្ម ឬការដាក់ទោសទណ្ឌ ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតម្លៃមនុស្សដទៃទៀត), HRI/GEN/1/Rev.9 (Vol. I), ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ១២ "វាមានសារៈសំខាន់សម្រាប់បញ្ឈប់នូវអំពើហិង្សាតាមមាត្រា ៧ ដែលចែងថា ច្បាប់ត្រូវតែហាមឃាត់ការប្រើប្រាស់ដោយទទួលយកជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការនូវចម្លើយឬការសារភាពដែលបានមកពីការធ្វើទារុណកម្ម [...]"។ *សូមមើលផងដែរ* របាយការណ៍ប្រចាំទីពីររបស់ Paraguay របាយការណ៍ប្រចាំទីបីរបស់ Mexico, CAT/C/SR.289, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣៤។ នៅក្នុងកិច្ចប្រជុំលើកទី ២៨៩ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្តែងនូវសេចក្តីសោកស្តាយថា "អសមត្ថភាពក្នុងការបញ្ឈប់នូវអំពើទារុណកម្ម គឺ *ក្នុងចំណោមនោះ* ជាលទ្ធផលនៃដំណើរគ្មានទោសរបស់អ្នកធ្វើទារុណកម្មដែលនៅតែបន្ត និងការពិតដែលថា រដ្ឋអំណាចដែលទទួលខុសត្រូវលើការគ្រប់គ្រងវិស័យយុត្តិធម៌ បន្តទទួលយកការសារភាព និងចម្លើយដែលបានមកដោយសារការធ្វើទារុណកម្ម ជាភស្តុតាងក្នុងពេលជំនុំជម្រះ បើទោះបីមានបទប្បញ្ញត្តិផ្នែកច្បាប់ចែងជាក់លាក់ថាពុំអាចទទួលយកបានក៏ដោយ" និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការដាក់ទោស ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតម្លៃមនុស្ស ដទៃទៀត ឯកសារអង្គការសហប្រជាជាតិ លេខ A/61/259, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ("របាយការណ៍របស់អ្នករាយការណ៍ពិសេស លេខ A/61/259") កថាខណ្ឌ ៤៥។ សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur, អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម៖ សេចក្តីអធិប្បាយ ទំព័រ ៥០៤ និង ៥៣០។

សិទ្ធិពលរដ្ឋ និងនយោបាយ[78] និងដកចេញពីមាត្រា ៦(៣) របស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[79]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានប្រកាសថា "សិទ្ធិមិនធ្វើសក្ខីកម្មដាក់បន្ទុកលើខ្លួនឯង ជាពិសេស សន្មតទុកជាមុនថា បណ្តឹងអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវតែបង្ហាញភស្តុតាងនៅក្នុងរឿងក្តីនេះ ប្រឆាំងនឹងជនជាប់ចោទ ដោយពុំចាំបាច់ស្វែងរកភស្តុតាងដែលបានមកតាមវិធីបង្ខិតបង្ខំ ឬសង្កត់សង្កិន ដែលផ្ទុយនឹងឆន្ទៈរបស់ជនជាប់ចោទ"[80]។ សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនធ្វើមិនឆ្លើយដាក់បន្ទុកខ្លួនឯង ពិតណាស់ គឺជាសិទ្ធិដែលងាយទទួលរងខ្លាំងបំផុតពីការរំលោភបំពានតាមរយៈការធ្វើទារុណកម្ម។ យោងសំអាងហេតុនេះ ប្រព័ន្ធតុលាការក្នុងស្រុកជាច្រើន បានយកវិធានបដិសេធភស្តុតាងមកអនុវត្តតាម ដើម្បីគ្របដណ្តប់លើស្ថានការណ៍បែបនេះ ដូចមាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ បើទោះជាមានវិធានបែបនេះក៏ដោយ ក៏ការរំលោភបំពានលើការហាមឃាត់ការធ្វើទារុណកម្ម ទំនងជានៅតែរីករាលដាលដូចមានភស្តុតាងបង្ហាញនៅក្នុងយុត្តិសាស្ត្រជាច្រើនស្តីពីសិទ្ធិមនុស្សទាក់ទងនឹងបញ្ហានេះដែរ[81] រួមមានដូចជាយុត្តិសាស្ត្រ

---

[78] មហាសន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ*ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ អង្គការសហប្រជាជាតិ ស៊េរីសន្ធិសញ្ញា វ៉ុល ៩៩៩ ទំព័រ ១៧១។ សូមមើលផងដែរ គណៈកម្មាធិការនៃសិទ្ធិមនុស្ស ការអធិប្បាយទូទៅ លេខ ១៣៖ មាត្រា ១៤ (ការគ្រប់គ្រងវិស័យយុត្តិធម៌), HRI/GEN/1/Rev.9 (Vol. I), ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ១៤។

[79] ក្រុមប្រឹក្សាអឺរ៉ុប*អនុសញ្ញាអឺរ៉ុបសម្រាប់ការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត* ដែលត្រូវបានវិសោធនកម្មដោយពិធីការលេខ ១១ និង ១៤ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០។

[80] *សូមមើល រឿងក្តី Gäfgen ទល់នឹង ប្រទេសអាល្លឺម៉ង់* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(ECtHR), "សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់", សំណើសុំលេខ 22978/05, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ ("*រឿងក្តី Gäfgen ទល់នឹង ប្រទេសអាល្លឺម៉ង់*"), កថាខណ្ឌ ១៦៨។

[81] សេចក្តីសង្កេតបញ្ចប់របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម(កម្ពុជា)លេខ CAT/C/KHM/CO/2, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ២៨ ចំណុចដែលគណៈកម្មាធិការសម្តែងនូវក្តីបារម្ភរបស់ខ្លួនក្នុងរបាយការណ៍ថា ការប្រើប្រាស់ការសារភាពដោយបង្ខំជាភស្តុតាងនៅក្នុងតុលាការ មានលក្ខណៈរាលដាលពាសពេញកម្ពុជា។ ការពិចារណាទៅលើរបាយការណ៍ដែលបានដាក់ដោយរដ្ឋភាគី តាមមាត្រា ១៩ នៃអនុសញ្ញា: របាយការណ៍ប្រទេសអេស្បាញលេខ CAT/C/SR.145, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៨ "កថាខណ្ឌ ២៧ នៃរបាយការណ៍លេខ [CAT/C/17/Add.10] បានបង្កើតឡើងវិញនូវសាលក្រមរបស់តុលាការនៃរដ្ឋធម្មនុញ្ញចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩១ ដែលលើកឡើងថា '... ជនជាប់ចោទនីមួយៗ ត្រូវបានសួរសំណួរស្តីពីខ្លឹមសារជាក់លាក់លម្អិតនៃចម្លើយរបស់ខ្លួន ដែលធ្វើឡើងជាមួយប៉ូលីស។ ជនជាប់ចោទប្រើប្រាស់ឱកាសនេះ បដិសេធចម្លើយពីដំបូងរបស់ខ្លួន និងចោទប្រកាន់ថា ចម្លើយនេះ ត្រូវបានធ្វើឡើងតាមរយៈការសង្កត់សង្កិន និងការធ្វើទារុណកម្ម។ ការចោទប្រកាន់នៃការធ្វើទារុណកម្មនេះ ដែលពុំបានធ្វើឡើងពីមុន ដោយជនជាប់ចោទ ឬមេធាវីការពារក្តីដែលមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ប៉ូលីស មិនអាចត្រូវបានយកមកពិចារណាដោយតុលាការនេះ ដើម្បីមោឃៈចម្លើយនេះបានឡើយ"។ សាលក្រមនេះ ផ្ទុយទាំងស្រុងពីមាត្រា ១៥ នៃអនុសញ្ញាដែលចែងថា ចម្លើយណាមួយដែល

របស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលបានពិចារណាទៅលើការចោទប្រកាន់អំពីការធ្វើទារុណកម្ម ក្នុងការសម្រេចពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី បើទោះបីជាពុំមានការតវ៉ាជាផ្លូវការអំពីការធ្វើទារុណកម្មឡើយ[82]។

42. យុត្តិកម្មជាក់ស្តែងពិតប្រាកដមួយសម្រាប់វិធានបដិសេធភស្តុតាង គឺថា ចម្លើយសារភាព ឬព័ត៌មានដទៃទៀត ដែលបានមកពីការធ្វើទារុណកម្ម ជាមូលដ្ឋាន ពុំអាចជឿទុកចិត្តបានឡើយ ដោយសារ ជនរងគ្រោះនៃការធ្វើទារុណកម្ម ប្រហែលជានិយាយអ្វីៗទាំងអស់ (ទោះពិតក្តី ឬមិនពិតក្តី) ដើម្បីបញ្ចប់ការឈឺចាប់របស់ខ្លួន។ ភាពពុំអាចជឿជាក់ទុកចិត្តបានដែលជាមូលដ្ឋាននៃព័ត៌មាននេះ ត្រូវបានបង្ហាញតាំងពីដំបូង ទាក់ទងទៅនឹងទឡ្ហីករណ៍ស្តីអំពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយហេតុថា ការដាក់ពិរុទ្ធភាពណាមួយដែលផ្អែកលើភស្តុតាងបែបនេះ គឺជាការប្រថុយប្រថាន[83]។ បើនិយាយឱ្យសមហេតុផលទៅ ទោះជាយ៉ាងណាក្តី អំណះអំណាងដែលថា ភស្តុតាងបានមកតាមរយៈការធ្វើទារុណកម្មពុំអាចជឿទុកចិត្តបាន គឺមិនត្រឹមតែជាប់ពាក់ព័ន្ធទៅនឹងចម្លើយសារភាពដោយបង្ខំប៉ុណ្ណោះទេ ជាទូទៅថែមទាំងទៅ នឹងព័ត៌មានណាមួយបានមកពីការបុគ្គលដែលទទួលរងការធ្វើទារុណកម្ម បើទោះបីជា

---

បង្ហាញថា បានមកពីការធ្វើទារុណកម្ម ពុំអាចត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ ផ្ទុយទៅវិញ ប្រសិនបើ បទប្បញ្ញត្តិនៃអនុសញ្ញា អាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់របស់អេស្ប៉ាញ មាត្រា ១៥ អាចត្រូវបានប្រើប្រាស់ដើម្បីមោឃៈភស្តុតាងដែលបានផ្តល់ឱ្យនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីបាន”។

[82] *រឿងក្តី Saunders ទល់នឹង ចក្រភពអង់គ្លេស,* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) “សាលក្រមរបស់អង្គជំនុំជម្រះ” សំណើសុំលេខ 19187/91 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ កថាខណ្ឌ ៧១។ *រឿងក្តី Jalloh ទល់នឹង ប្រទេសអាល្លឺម៉ង់* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) “សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់” សំណើសុំលេខ 54810/00, *ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦* (“*រឿងក្តី Jalloh ទល់នឹង អាល្លឺម៉ង់*”) កថាខណ្ឌ ១០០។ *រឿងក្តី Huseyn និងអ្នកដទៃទៀត ទល់នឹង Azerbaijan,* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) “សាលក្រមរបស់អង្គជំនុំជម្រះ”សំណើសុំលេខ 35485/05, 45553/05, 35680/05 និង 36085/05 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១១ (“*រឿងក្តី Huseyn និងអ្នកដទៃទៀត ទល់នឹង Azerbaijan*”) កថាខណ្ឌ ២០២។ ដកស្រង់ *រឿងក្តី mutatis mutandis Örs និងអ្នកដទៃទៀត ទល់នឹង ប្រទេសទួរគី,* ECtHR, “សាលក្រមរបស់អង្គជំនុំជម្រះ” សំណើសុំលេខ 46213/99, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦ (“*Örs និងអ្នកដទៃទៀត ទល់នឹង ប្រទេសទួរគី*”) កថាខណ្ឌ ៥៨ និង *រឿងក្តី Kolu ទល់នឹង ប្រទេសទួរគី,* ECtHR, “សាលក្រមរបស់អង្គជំនុំជម្រះ”, សំណើសុំលេខ 35811/97 ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៥ (“*រឿងក្តី Kolu ទល់នឹង ប្រទេសទួរគី*”) កថាខណ្ឌ ៥៤។

[83] *សូមមើល* សាស្ត្រាចារ្យ Manfred Nowak និង Elizabeth McArthur, *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្មៈ សេចក្តីអធិប្បាយ ទំព័រ ៥៣០។ រឿងក្តី Söylemez ទល់នឹង ប្រទេសទួរគី,* ECtHR, “សាលក្រមរបស់អង្គជំនុំជម្រះ”, សំណើសុំលេខ 46661/99, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១២២។ *រឿងក្តី Örs និងអ្នកដទៃទៀត ទល់នឹង ប្រទេសទួរគី កថាខណ្ឌ ៦០។ រឿងក្តី Kolu ទល់នឹង ប្រទេសទួរគី* កថាខណ្ឌ ៥១ ដល់ ៥៤។

បុគ្គលនោះ ពុំមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលចាំបាច់ត្រូវការប្រើប្រាស់ព័ត៌នោះឡើយ[84]។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ការសិក្សាស្រាវជ្រាវថ្មីៗដែលផ្អែកលើការពិសោធន៍ ពុំបានផ្ដល់តម្លៃដល់ការប្រើប្រាស់នូវ "វិធីសាស្ត្រក្នុងការសួរចម្លើយបែបជឿនលឿនមួយ"របស់ភ្នាក់ងារស៊ើបការណ៍មជ្ឈិម (CIA) នៃសហរដ្ឋអាមេរិក សម្រាប់គោលបំណងដែលអនុវត្តនោះ ដែលជួយគាំទ្រដល់ទឡ្ហីករណ៍ដែលបានលើកឡើងថា ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម ជាមូលដ្ឋាន ពុំអាចជឿទុកចិត្តបាន[85] ដោយសារគេរកឃើញថា វិធីសាស្ត្រនេះ ពុំមែនជាមធ្យោបាយប្រសិទ្ធិភាពក្នុងការទទួលបានព័ត៌មានសម្ងាត់ឡើយ។

43. ដូចបរិបទខាងលើដែរ ការបង្កើតឡើងថ្មីៗនៃយុត្តិសាស្ត្រ បានលំអៀងទៅរកការពុំទទួលយកព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាននៃក្រមសីលធម៌ដែលផ្អែកលើសិទ្ធិ។ តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ដែល តាមធម្មតា ផ្ដោតទៅលើការវាយតម្លៃអំពីភាពយុត្តិធម៌ជាទូទៅនៃកិច្ចដំណើរការនីតិវិធី និងពុំធ្វើការកំណត់ប្រភេទនៃភស្តុតាងជាក់លាក់ណាមួយនោះ[86] បានបង្កើតករណីលើកលែងទាក់ទងនឹងការប្រើប្រាស់ភស្តុតាង ដែលទទួលបានដោយសារបំពានលើការហាមឃាត់នៃការធ្វើទារុណកម្ម។ អង្គជំនុំជម្រះជាន់ខ្ពស់របស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្សបានសម្រេចថា ការប្រើប្រាស់ភស្តុតាងដែលបាន "មកដោយសារការរំលោភបំពានលើសិទ្ធិដាច់ខាត និងសំខាន់មួយដែលត្រូវបានធានាដោយអនុសញ្ញា" ដើម្បីបញ្ជាក់ភស្តុតាងលើអង្គហេតុពាក់ព័ន្ធ ធ្វើឱ្យកិច្ចដំណើរការនីតិវិធីទាំងមូលពុំមានភាពយុត្តិធម៌ ដោយពុំចាំបាច់ពិចារណាលើតម្លៃនៃភស្តុតាង និង ពុំចាំបាច់គិតថា ភស្តុតាងនេះ គឺជាកត្តាជួយដល់ការសម្រេចពីពិរុទ្ធភាពរបស់ជនជាប់ចោទ ដែរ ឬយ៉ាងណានោះឡើយ[87]។ ក្នុងករណីផ្សេងមួយទៀត

---

[84] *រឿងក្ដី Huseyn និងអ្នកដទៃទៀត ទល់នឹង Azerbaijan,* កថាខណ្ឌ ២០២។ *រឿងក្ដី El Haski ទល់នឹង Belgium* តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 649/08 ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ("*រឿងក្ដី El Haski ទល់នឹង Belgium*") កថាខណ្ឌ ៨៥។

[85] គណៈកម្មាធិការទទួលបន្ទុកស៊ើបការសហរដ្ឋអាមេរិក *ការសិក្សារបស់គណៈកម្មាធិការអំពីកម្មវិធីសួរចម្លើយ និងការឃុំឃាំងរបស់ទីភ្នាក់ងារស៊ើបការមជ្ឈិម (CIA)* ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ (ការកែប្រែលើចំណាត់ថ្នាក់ឯកសារ) ទំព័រ ២ ត្រង់ចំណុចដែលរបាយការណ៍បានរកឃើញថា បុគ្គលដែលទទួលរងការធ្វើបាបបែបនេះ ពុំបានផ្ដល់"ព័ត៌មានសម្ងាត់" ឬ"បានផ្ដល់ព័ត៌មានដែលនាំឱ្យព័ត៌មានសម្ងាត់ក្លាយជាព័ត៌មានមិនពិត"។

[86] *រឿងក្ដី Khan ទល់នឹង ចក្រភពអង់គ្លេស* តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 35394/97, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០០ ("*រឿងក្ដី Khan ទល់នឹង ចក្រភពអង់គ្លេស*"), កថាខណ្ឌ ៣៤។

[87] *រឿងក្ដី See Gäfgen ទល់នឹង ប្រទេសអាល្លឺម៉ង់,* កថាខណ្ឌ ១៦៥ ដល់ ១៦៦។ *សូមមើលផងដែរ រឿងក្ដី Desde ទល់នឹង ប្រទេសទួរគី* តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 23909/03 ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១២៥ ដល់ ១២៦ និង ១៣២។ *រឿងក្ដី Othman (Aby Qatada) ទល់នឹង ចក្រភពអង់គ្លេស*

អង្គជំនុំជម្រះជាន់ខ្ពស់រកឃើញថា ការទទួលយកឱ្យប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាភស្តុតាងដាក់បន្ទុក ដែលបានមក"ដោយសារអំពើហឹង្សា ឬអំពើឃោរឃៅ ឬទម្រង់នៃអំពើផ្សេងៗទៀតដែលអាចត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើទារុណកម្ម [...] គឺគ្រាន់តែបំពេញតាមគោលបំណងក្នុងការបង្ហាញដោយប្រយោលនូវអំពើដែលគួរដាក់ទោសតាមសីលធម៌ មានលក្ខណៈស្របច្បាប់ ដែលអំពើនេះអ្នកតាក់តែងមាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានស្វះស្វែងឱ្យចែងក្នុងច្បាប់" ឬ"ស្នើសុំបិទបាំងអំពើឃោរឃៅនេះក្រោមសំណាញ់ច្បាប់"[88]។

44. ទាក់ទងនឹងរឿងក្តីដែលពុំមែនរឿងព្រហ្មទណ្ឌ *រឿងក្តី A របស់ប្រទេសអង់គ្លេស អ្នកដទៃទៀត ទល់នឹងរដ្ឋលេខាធិការនៃក្រសួងកិច្ចការរដ្ឋបាល (លេខ ២)*[89] គឺជាចំណុចសំខាន់នៃការចាប់ផ្តើម។ ក្នុងរឿងក្តីនេះសភាជាន់ខ្ពស់បានពិចារណាលើបញ្ហាថាតើ ស្ថាប័នរដ្ឋបាលដែលសម្រេចលើការនិរទេស អាចទទួលយកភស្តុតាងស្របច្បាប់ដែលជា ឬប្រហែលជាបានមកពីការធ្វើទារុណកម្មលើបុគ្គលនានា ក្រៅពីអ្នកដែលជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីលើការនិរទេសដែរ ឬយ៉ាងណា នៅក្នុងរដ្ឋដទៃទៀត ហើយពុំមានការផ្សំគំនិតពីប្រទេសអង់គ្លេសនោះ។ យោងតាមគោលការណ៍នៃច្បាប់អង់គ្លូសាក់សុង យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងច្បាប់សាធារណៈអន្តរជាតិ រួមទាំងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម សភាជាន់ខ្ពស់បានសន្និដ្ឋានថា ស្ថាប័នរដ្ឋបាលពុំអាចធ្វើដូច្នោះបានឡើយ ដោយសារភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ធ្វើឱ្យ"ប៉ះពាល់ដល់បទដ្ឋានសាមញ្ញស្តីពីមនុស្សជាតិ និងសេចក្តីថ្លៃថ្នូរ ហើយពុំស្របជាមួយនឹងគោលការណ៍ ដែលគប្បីជម្រុញឱ្យតុលាការព្រហ្មទណ្ឌស្វះស្វែងក្នុងការផ្តល់យុត្តិធម៌"[90]។ ការសម្រេចនេះ និងសំអាងហេតុដែលជាមូលដ្ឋាន ត្រូវបានតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សយកទៅអនុវត្តក្នុង *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស*[91]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានរំលឹកពីការយល់ឃើញ

---

តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 8139/09, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ ("*រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស*") កថាខណ្ឌ ២៦៣ ដល់ ២៦៧។

[88] *រឿងក្តី Jalloh ទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១០៥ យោងទៅលើសាលដីការបស់តុលាការកំពូលរបស់សហរដ្ឋអាមេរិក ក្នុង*រឿងក្តី Rochin ទល់នឹង California*, សំណុំរឿងលេខ 342 U.S. 165 (1952) កថាខណ្ឌ ១០ ដល់ ១២។ *រឿងក្តី Harutyunyan ទល់នឹង Armenia*, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 36549/03 ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៦៣។

[89] *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការប្រចាំនាយកដ្ឋានកិច្ចរដ្ឋបាល (លេខ ២)*, [2005] UKHL 71 ("*រឿងក្តី A.និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការប្រចាំនាយកដ្ឋានកិច្ចរដ្ឋបាល (លេខ ២)*") កថាខណ្ឌ ១១៦ ដល់ ១១៨។

[90] ចៅក្រម Lord Bingham ក្នុង*រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ៣៥ ដល់ ៥២។

[91] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៤។

របស់សភាជាន់ខ្ពស់ដែលថា "ការហាមឃាត់លើការទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ជាចម្បងពុំមែនដោយសារតែ ភស្តុតាងនេះ ពុំអាចជឿទុកចិត្តបាននោះទេ ឬពុំមែនដោយសារតែការទទួលយកភស្តុតាង នឹងធ្វើឱ្យការជំនុំជម្រះពុំមានភាពយុត្តិធម៌នោះឡើយ។ ផ្ទុយទៅវិញ គឺដោយសារ 'រដ្ឋត្រូវតែប្រកាន់ជំហររឹងមាំប្រឆាំងនឹងអំពើដែលបង្កើតភស្តុតាងនោះ'"[92]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សអះអាងបន្ថែមទៀតថា៖

> ពុំមានប្រព័ន្ធច្បាប់ដែលផ្អែកលើនីតិរដ្ឋ អាចអនុញ្ញាតឱ្យទទួលយកភស្តុតាង បើទោះជាអាចជឿទុកចិត្តបានក៏ដោយ ដែលបានទទួលមកពីអំពើឃោរឃៅដូចជាការធ្វើទារុណកម្មឡើយ។ ដំណើរការជំនុំជម្រះក្តី មូលដ្ឋាននៃនីតិរដ្ឋ។ ភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្ម បានធ្វើឱ្យខូចខាតដល់ដំណើរការនោះដោយពុំអាចជួសជុលឡើងវិញបាន។ ភស្តុតាងនេះ បានទៅជំនួសកន្លែង និងកម្លាំងរបស់នីតិរដ្ឋ ហើយបានធ្វើឱ្យខូចដល់ប្រជាប្រិយភាពរបស់តុលាការណាដែលទទួលយកភស្តុតាងនេះ។ ភស្តុតាងនេះ ពុំត្រូវបានរាប់បញ្ចូល ក្នុងគោលបំណងដើម្បីការពារសុចរិតភាពនៃដំណើរការជំនុំជម្រះក្តី និងចុងក្រោយគឺនីតិរដ្ឋខ្លួនតែម្តង[93]។

45. តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសន្និដ្ឋានថា ការផ្អែកលើភស្តុតាងបែបនេះ ធ្វើឱ្យការជំនុំជម្រះទាំងមូលពុំទទួលបានលទ្ធផលសមស្របតាមសីលធម៌ ស្របច្បាប់ និងមានកំហុសទាំងស្រុង[94]។ គោលការណ៍ដែលបានបង្ហាញក្នុង*រឿងក្តី Othman* ត្រូវបានយកមកអនុវត្តតាមក្នុង*រឿងក្តី El Haski ទល់នឹង ប្រទេស Belgium*[95] *និង រឿងក្តី El Nashri ទល់នឹង ប្រទេស ប៉ូលឡូញ*[96]។ *យុត្តិសាស្ត្ររបស់*តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានសង្កត់ធ្ងន់លើភាពប្រទាក់ក្រឡាគ្នាជាហូរហែជាមួយនឹងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[97]។ ក៏មានការកត់សម្គាល់ផងដែរចំពោះការយោងទៅលើ"សុចរិតភាពនៃដំណើរការ"

---

[92] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៤ ដកស្រង់ចៅក្រម Lord Philips ក្នុង*រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* ។

[93] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៤។

[94] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៧។

[95] *រឿងក្តី El Haski ទល់នឹង Belgium* កថាខណ្ឌ ៨៥។

[96] *រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 28761/11 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ("*រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ*") កថាខណ្ឌ ៥៦៤។

[97] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៥៣, ២៦៦។ *រឿងក្តី Jalloh ទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១០៥។

និង"ប្រជាប្រិយភាពរបស់តុលាការ" ក្នុងការយកលក្ខខណ្ឌមកប្រើប្រាស់តាមរយៈវិធានបដិសេធភស្តុតាងរបស់តុលាការព្រហ្មទណ្ឌ និងឧក្រិដ្ឋកម្មអន្តរជាតិ[98]។

46. សរុបសេចក្តីមក ស្ថាប័នស្តីពីសិទ្ធិមនុស្សបានយល់ឃើញថា ការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងព័ត៌មានបានមកពីការធ្វើទារុណកម្ម គឺពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីផ្លូវការទាំងអស់ បើទោះបីជាផ្នែកតុលាការក្តី ឬផ្នែករដ្ឋបាលក្តី[99]។ ស្ថាប័ននេះបានបញ្ជាក់បន្ថែមទៀតថា បញ្ហាថាតើ ការធ្វើទារុណកម្ម ត្រូវបានប្រព្រឹត្តឡើងដោយរដ្ឋដែលមានយុត្តាធិការ ឬក៏រដ្ឋដទៃទៀត[100] និងថាតើ ជនរងគ្រោះនៃអំពើធ្វើទារុណកម្មនេះ គឺជាភាគី ឬក៏ជាអ្នកចូលរួម ឬក៏អ្វីផ្សេងដែរ ឬយ៉ាងណា នៅក្នុងកិច្ចដំណើរការនីតិវិធីនោះ[101] ពុំមែនជាបញ្ហាសំខាន់ឡើយ។ ដរាបណា តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស នៅតែសង្កត់ធ្ងន់ទៅលើមូលដ្ឋានជាសារវ័ន្តនៃការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាង ដែលទទួលបានមកពីការធ្វើទារុណ

---

[98] *សូមមើលខាងលើ* ជើងទំព័រ ៦៣។ *រឿងក្តី Gäfgen ទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១៧៥។ *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៥៣, ២៦៤, ២៦៦។ *សូមមើលផងដែរ រឿងក្តី Olmstead ទល់នឹង សហរដ្ឋអាមេរិក សំណុំរឿងលេខ* 277 US 438 (1928) កថាខណ្ឌ ៤៨៤ (ចៅក្រម Brandeis មតិជំទាស់) *រឿងក្តី Elkins ទល់នឹង សហរដ្ឋអាមេរិក សំណុំរឿងលេខ* 364 US 206 (ឆ្នាំ ១៩៦០) កថាខណ្ឌ ២២២ ដល់ ២២៣។ *រឿងក្តី Herring ទល់នឹង សហរដ្ឋអាមេរិក, សំណុំរឿងលេខ* 172 L Ed 2d 496 (ឆ្នាំ ២០០៩) កថាខណ្ឌ ៥១២ (ចៅក្រម Ginsburg, មតិជំទាស់)។

[99] *សូមមើលផងដែរ* គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម("គណៈកម្មាធិការ CAT") *រឿងក្តី G.K. ទល់នឹង Switzerland* លិខិតទំនាក់ទំនងលេខ 219/2002, សំណុំរឿងលេខ CAT/C/30/D/219/2002 ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៣ ("*រឿងក្តី G.K. ទល់នឹង Switzerland*") កថាខណ្ឌ ៦.១០ ដែលប្រកាសថា "វិសាលភាពទូលំទូលាយ"នៃការហាមឃាត់ក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានបញ្ជាក់ពី"កាតព្វកិច្ចរបស់រដ្ឋភាគីនីមួយៗតម្រូវឱ្យធ្វើការអះអាងថាតើចម្លើយដែលបានទទួលយកជាភស្តុតាងក្នុង*កិច្ចដំណើរការនីតិវិធីទាំងឡាយក្រោមយុត្តាធិការរបស់ខ្លួន* រួមទាំងកិច្ចនីតិវិធីបត្យាប័នបានមកពីការធ្វើទារុណកម្ម ដែរ ឬ យ៉ាងណា"(សេចក្តីបញ្ជាក់បន្ថែម)។ សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ស្តីពីរបាយការណ៍ជាប្រចាំលើកទីបួន(ចក្រភពអង់គ្លេស និង Northern Ireland) ឯកសារលេខ CAT/C/CR/33/3, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤(ក)(ឈ) កថាខណ្ឌ ៥(ឃ)។ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការធ្វើបាប ឬការដាក់ទោស ឃោរឃៅ ដោយអមនុស្សធម៌ បន្ទាបបន្ថោកតម្លៃមនុស្សដទៃទៀត, ឯកសារ អ.ស.ប លេខ A/59/324, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ២៣។ *សូមមើលផងដែរ សៀវភៅរបស់សាស្ត្រាចារ្យ* Manfred Nowak & Elizabeth McArthur, ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្មៈ សេចក្តីអធិប្បាយ* ទំព័រ ៥៣០។ ចៅក្រម Lord Bingham នៅចំពោះសភាជាន់ខ្ពស់ក្នុង*រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ៤២ ដល់ ៤៤។

[100] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៣ និង ២៦៧។ *រឿងក្តី El Haski ទល់នឹង Belgium,* កថាខណ្ឌ ៨៥, ៨៦, ៨៨ និង ៩៨។

[101] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦២។ *រឿងក្តី El Haski ទល់នឹង Belgium* កថាខណ្ឌ ៨៥។

កម្ម[102] ដំហររបស់គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺថា វិធានបដិសេធភស្តុតាង ដែលជាមុខងារមួយនៃការហាមឃាត់ដាច់ខាតចំពោះការធ្វើទារុណកម្ម នៅតែមានលក្ខណៈដាច់ខាត និងពុំអាចធ្វើបដិប្បញ្ញត្តិបានឡើយ[103]។

47. យោងតាមកម្មវត្ថុ និងគោលបំណង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដើម្បីផ្តល់អានុភាពឱ្យបានពេញលេញដល់វិធានបដិសេធភស្តុតាង ចាំបាច់ត្រូវតែអានត្រង់ចំណុចស្តីពីលក្ខខណ្ឌនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ អាស្រ័យហេតុនេះ អនុលោមតាមករណីលើកលែងដែលបានកំណត់នៅក្នុងប្រយោគទីពីរនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ព័ត៌មានដែលបានទទួលពីការធ្វើទារុណកម្ម គឺពុំអាចទទួលយកបានជាភស្តុតាងឡើយ បើទោះបីជាព័ត៌មាននោះមានការជាប់ពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធី និងអាចមានតម្លៃជាភស្តុតាងយ៉ាងណាក៏ដោយ។ វិធានបដិសេធភស្តុតាង គ្របដណ្តប់លើការទទួលយកដោយផ្ទាល់នូវព័ត៌មានបានមកពីការធ្វើទារុណកម្មធ្វើជាភស្តុតាង ដូចជាការប្រើប្រាស់នូវការថតចម្លង មិនថាតាមទម្រង់ណានោះទេ រួមទាំងការផលិតឡើងវិញនូវខ្លឹមសារតាមរយៈសាក្សីក៏ដោយ។ បន្ថែមលើនេះ អានុភាពនៃវិធានបដិសេធភស្តុតាង ចែងថា ចម្លើយដែលស្ថិតក្រោមវិធាននេះ ពុំអាចត្រូវបានប្រើប្រាស់ក្នុងការបញ្ជាក់ពីការពិតនៃខ្លឹមសារ ឬក៏សូម្បីតែធ្វើសេចក្តីសន្និដ្ឋានដោយប្រយោលថា ខ្លឹមសារនោះអាចជាការពិត ដើម្បីដេញដោលសាក្សីឡើយ។

## គ. តើចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ចម្លើយនៅមន្ទីរ ស-២១ ត្រូវបានធ្វើឡើង ដោយសារការធ្វើទារុណកម្មដែរ ឬទេ?

48. ដូចបានរំលឹកខាងលើ មាត្រា ១៥ នៃ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម តម្រូវឱ្យដកចេញពីភស្តុតាងនូវ"ចម្លើយណាមួយដែល*បានបង្ហាញថា* ជាលទ្ធផលនៃការធ្វើទារុណកម្ម"[104]។ ទាក់ទងបញ្ហានេះ

---

[102] *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៥៣ ដល់ ២៥៥។ *រឿងក្តី El Haski ទល់នឹង Belgium* កថាខណ្ឌ ៧០។

[103] *សូមមើល*ការអធិប្បាយទូទៅ លេខ ២ កថាខណ្ឌ ៦ ស្តីពីការអនុវត្តន៍មាត្រា ២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដោយសំណាក់រដ្ឋភាគីដែលបានបញ្ជាក់ថា "ទោះបីមានកាលៈទេសៈពិសេសអ្វីឡើយក៏ដោយ...ក៏មិនអាចធ្វើយុត្តិកម្មទៅលើការធ្វើទារុណកម្មបានឡើយ" វិធានបដិសេធភស្តុតាង ដែលមាននៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការហាមឃាត់ការធ្វើបាប ឬការដាក់ទោសទណ្ឌ ឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតម្លៃមនុស្សមានចែងក្នុងមាត្រា ១៦ នោះ គឺជាបទប្បញ្ញត្តិចំនួន ៣ នៃអនុសញ្ញានេះដែល "ត្រូវតែគោរពទោះក្នុងកាលៈទេសៈណាក៏ដោយ"។ *ស្រដៀងគ្នានេះដែរ* របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការដាក់ទោសទណ្ឌ ឬអំពើអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬឃោរឃៅដទៃទៀត, លោក Juan E. Méndez, ឯកសារ អ.ស.ប លេខ A/HRC/25/60 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៤ ("របាយការណ៍របស់អ្នករាយការណ៍ពិសេសលេខ A/HRC/25/60") កថាខណ្ឌ ១៧។

សហព្រះរាជអាជ្ញាលើកឡើងថា ដំបូង តុលាការអង្គហេតុត្រូវកំណត់ថា ភស្តុតាងនេះ ពិតជាបានមកពីការធ្វើទារុណកម្ម មុនពេលដែលភស្តុតាងនេះ អាចត្រូវបានដកចេញយ៉ាងដូច្នោះ[105]។ សហព្រះរាជអាជ្ញាជំទាស់ថា ភស្តុតាងទាំងនេះ មាន"ច្រើនលើសលប់"នៅក្នុងសំណុំរឿង ០០២/០២ ដែលរាល់អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស-២១ ត្រូវបានធ្វើទារុណកម្ម ប៉ុន្តែ បានកត់សម្គាល់ថា ភស្តុតាងទាំងនេះ មានតិចតួចណាស់នៅក្នុងសំណុំរឿង ០០២/០១[106]។ ហេតុនេះ សម្រាប់គោលបំណងក្នុងការសម្រេចលើបញ្ហាថាតើចម្លើយនៅមន្ទីរ ស-២១ ទាំងនេះ អាចត្រូវបានប្រើប្រាស់ បានដែរ ឬយ៉ាងណា ក្នុងអំឡុងពេលសវនាការនៅក្នុងខែ កក្កដា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល "ធ្វើការសម្រេចថាតើ អង្គហេតុនេះ បានចោទជាបញ្ហានៅក្នុងចំណោមភាគីនានា ឬអាចត្រូវបានដោះស្រាយទៅតាមបទប្បញ្ញត្តិណាមួយដែរ ឬយ៉ាងណា"[107]។ ចំពោះ ខៀវ សំផន អះអាងថា ភស្តុតាងត្រូវតែបានដកចេញនៅពេលមានហានិភ័យពិតប្រាកដកើតឡើង ដោយសារភស្តុតាងនេះ បានមកពីការធ្វើទារុណកម្ម ឬការបង្ខិតបង្ខំ។ ដោយសំអាងលើមូលដ្ឋាននេះ ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ នៅក្នុងសវនាការក្នុងខែ កក្កដា ឆ្នាំ ២០១៥[108]។ ផ្ទុយទៅវិញ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន នួន ជា "បានបញ្ជាក់ថា ភស្តុតាងនេះ ពុំបានបង្ហាញថា មានចម្លើយសារភាពជាក់លាក់ណាមួយ ត្រូវបានធ្វើឡើង តាមរយៈការធ្វើទារុណកម្មឡើយ ហើយ នួន ជា មានបំណងលើកពិភាក្សាលើចំណុចនេះនៅក្នុងសំណុំរឿង ០០២/០២"[109]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា បញ្ហាដែលថា អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ទទួលរងការធ្វើទារុណកម្ម និងថា ជាលទ្ធផលចម្លើយសារភាពរបស់អ្នកជាប់ឃុំឃាំងទាំងនេះ បានមកដោយសារការធ្វើទារុណកម្មនោះ គឺជាកម្មវត្ថុនៃការជំទាស់ក្នុងចំណោមភាគី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២[110]។

---

104 សេចក្តីបញ្ជាក់បន្ថែម។

105 សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

106 សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

107 សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

108 សេចក្តីជំទាស់របស់ជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៣ ដល់ ១៤។

109 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ១៩០២។

110 ប្រតិចារឹកថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ឯកសារលេខ E1/292.1 ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/304.1 ទំព័រ ៣ ដល់ ៤៧។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E1/319.1 ទំព័រ ២០ និង ២៦។ *សូមមើលផងដែរ* សារណារបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២។ សារណារបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

49. មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំមានចែងអំពីបទដ្ឋានស្តីពីភស្តុតាងដែលអាចអនុវត្តបាន និងការបែងចែកការទទួលខុសត្រូវស្វែងរកភស្តុតាងដើម្បីបង្ហាញពីការធ្វើទារុណកម្ម ឬការបង្ខិតបង្ខំតាមគោលបំណងរបស់វិធានបដិសេធភស្តុតាង។ បន្ទាប់ពីបានស្វះស្វែងរកការណែនាំនៅកម្រិតអន្តរជាតិ[111] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បទដ្ឋាន និងបន្ទុកក្នុងការបង្ហាញភស្តុតាង ពុំត្រូវបានដោះស្រាយនៅកម្រិតអន្តរជាតិឡើយ គឺអាស្រ័យលើចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធី និងកាលៈទេសៈនៃរឿងក្តី ហើយនៅគ្រប់កាលៈទេសៈទាំងអស់ ត្រូវបានពិភាក្សានៅក្នុងរឿងក្តីនីមួយៗ នៅពេលបុគ្គលដែលពាក់ព័ន្ធនោះ ស្នើសុំ*ដកចេញ*ភស្តុតាងដែលប្រឆាំងនឹងខ្លួន និងសុំមិនឱ្យប្រើប្រាស់ភស្តុតាងនេះជាមធ្យោបាយក្នុងការការពារខ្លួន។ ទោះបីជាយ៉ាងណាក្តី មានគោលការណ៍ទូទៅមួយចំនួន ត្រូវបានដកស្រង់ចេញពីយុត្តិសាស្ត្រអន្តរជាតិនេះ ដែលនឹងត្រូវពិភាក្សានៅខាងក្រោម។

50. គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានសម្រេចជាទូទៅថា នៅពេលមានលទ្ធផលកើតចេញពីការហាមឃាត់យ៉ាងដាច់ខាតចំពោះការធ្វើទារុណកម្ម ដែលអ្នកតវ៉ាបានធ្វើការចោទប្រកាន់ថា ភស្តុតាង បានមកដោយសារការធ្វើទារុណកម្ម បើទោះបីជាចម្លើយសារភាពរបស់ខ្លួនក្តី ឬជាចម្លើយរបស់សាក្សីដទៃក្តីនោះ រដ្ឋដែលពាក់ព័ន្ធមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតបន្ទាន់ និងឥតលម្អៀងទៅលើភាពត្រឹមត្រូវនៃការអះអាងនេះ[112]។ ទោះជាយ៉ាងណាក្តី សេចក្តីប្រកាសជាសាធារណៈរបស់គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មស្តីពីបទដ្ឋានតម្រូវនៃភស្តុតាង ពុំមានលក្ខណៈស៊ីសង្វាក់គ្នាឡើយ[113]។ នៅក្នុងរឿងក្តីមួយចំនួន គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គោរព

---

សារណារបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២។ សារណារបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ព័ត៌មានបានមកពីការធ្វើទារុណកម្ម ឯកសារចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E350/4.2។

[111] ដូចមានចែងក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[112] គណៈកម្មាធិការស្តីពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម, *រឿងក្តី P. E. ទល់នឹង ប្រទេសបារាំង* លិខិតទំនាក់ទំនងលេខ 193/2001, CAT/C/29/D/193/2001, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០២ (“*រឿងក្តី P. E. ទល់នឹង ប្រទេសបារាំង*”), កថាខណ្ឌ ៦.៣។

[113] *រឿងក្តី P. E. ទល់នឹង ប្រទេសបារាំង* កថាខណ្ឌ (សម្រេចថា សម្រាប់ការនុវត្តនូវការហាមឃាត់មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ការចោទប្រកាន់ ត្រូវតែបង្ហាញថា “មានមូលដ្ឋានត្រឹមត្រូវ”។ ការប្រើប្រាស់នៃបទដ្ឋាននេះ ទទួលបានការរិះគន់)។ *សូមមើល* សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur, ចំណងជើង *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម: សេចក្តីអធិប្បាយ* ទំព័រ ៥១៧។ *រឿងក្តី G. K. ទល់នឹង Switzerland*, កថាខណ្ឌ ៦.១១ (តម្រូវថា ការចោទប្រកាន់ ត្រូវតែមាន“មូលដ្ឋានត្រឹមត្រូវ”) *សូមមើលផងដែរ* គណៈកម្មាធិការស្តីពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម, *រឿងក្តី Ali ទល់នឹង Tunisia*, លិខិតទំនាក់ទំនងលេខ 291/2006, CAT/C/41/D/291/2006, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ១៥.៤ (យល់ឃើញថា ការធ្វើទារុណកម្មត្រូវបានបង្ហាញដោយផ្អែកលើការចោទ

តាមការវាយតម្លៃរបស់រដ្ឋអំណាចក្នុងស្រុក ដរាបណា រដ្ឋអំណាចនេះ ពុំមានភាពលម្អៀង ឬធ្វើតាមអំពើចិត្ត[114] ចំណែកឯនៅក្នុងករណីដែលការចោទប្រកាន់របស់អ្នកតវ៉ា ពុំត្រូវបានពិចារណាដោយយកចិត្តទុកដាក់ពីសំណាក់រដ្ឋអំណាចនោះ ឬក៏ក្នុងករណីដែលរដ្ឋ ខកខានក្នុងការបដិសេធលើការចោទប្រកាន់នេះ គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានរកឃើញថា តាមវិធាន គឺជាការរំលោភលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ ជាពិសេស បញ្ហានេះ កើតមាននៅពេលណាដែលការធ្វើទារុណកម្ម ត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងប្រទេសដែលមានរបាយការណ៍ជាប្រចាំបញ្ជាក់ថា មានការរីករាលដាលនូវការប្រើប្រាស់ចម្លើយសារភាពដែលធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់ ឬការប្រើប្រាស់ចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំ ដើម្បីធានាដល់ការដាក់ពិរុទ្ធភាពឱ្យបាន[115]។

51. ប្រហាក់ប្រហែលគ្នាដែរ គណៈកម្មាធិការនៃសិទ្ធិមនុស្សបានអះអាងថា នៅពេលដែលមានការចោទប្រកាន់អំពីការធ្វើទារុណកម្មនៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ"បន្ទុកក្នុងការបង្ហាញភស្តុតាងពុំមែនស្ថិតលើអ្នកចោទប្រកាន់តែម្នាក់ឯងនោះទេ ជាពិសេស ដោយសារតែអ្នកចោទប្រកាន់ និងរដ្ឋភាគីពុំអាចចូលមើលភស្តុតាងបានស្មើគ្នា និងជារឿយៗ វាជារឿងក្តីដែលរដ្ឋភាគីតែម្នាក់ឯង ជាអ្នកមានព័ត៌មានពាក់ព័ន្ធនោះ"[116]។ អាស្រ័យដូចនេះ "នៅពេលដែល ការចោទប្រកាន់ មានភស្តុតាងបញ្ជាក់អះអាងត្រឹមត្រូវគួរឱ្យជឿជាក់បាន ដោយអ្នកចោទប្រកាន់ និងនៅពេលដែលការបញ្ជាក់អះអាងបន្ថែម បានផ្អែកលើព័ត៌មានដែលស្ថិតនៅក្នុងដៃរបស់រដ្ឋភាគីតែម្នាក់គត់" ដែលរដ្ឋនេះ ពុំបានបដិសេធទៅនឹងការចោទប្រកាន់នេះ ដូច្នេះ

---

ប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខប្រឆាំងទៅនឹងការខកខានរបស់រដ្ឋភាគី ក្នុងការផ្តល់ទឡ្ហីករណ៍តបត"ដែលមានភស្តុតាងគាំទ្រគ្រប់គ្រាន់")។ *រឿងក្តី Aarrass ទល់នឹង Morocco* លិខិតទំនាក់ទំនងលេខ 477/2011, CAT/C/52/D/477/2011, ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៤ ("*រឿងក្តី Aarrass ទល់នឹង Morocco*") កថាខណ្ឌ ១០.៥, ១០.៦, ១០.៨ (យល់ឃើញថា កាតព្វកិច្ចក្នុងការស៊ើបអង្កេតការចោទប្រកាន់នៃការធ្វើទារុណកម្ម មាន"នៅពេលណាដែល មានមូលដ្ឋានសមហេតុផលដែលគួរឱ្យជឿជាក់បានថា អំពើនៃការធ្វើទារុណកម្ម ត្រូវបានប្រព្រឹត្តឡើង")។

[114] *រឿងក្តី P. E. ទល់នឹង ប្រទេសបារាំង* កថាខណ្ឌ ៦.៤, ៦.៥។ *រឿងក្តី G. K. ទល់នឹង Switzerland*, កថាខណ្ឌ ៦.១១, ៦.១២ ។

[115] *រឿងក្តី Aarrass ទល់នឹង Morocco*, កថាខណ្ឌ ១០.៨, ១១។ *រឿងក្តី Yousri Ktiti ទល់នឹង Morocco*, លិខិតទំនាក់ទំនងលេខ 419/2010, CAT/C/46/D/419/2010, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៨.៦ ដល់ ៨.៨។

[116] គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស, *រឿងក្តី Maharjan ទល់នឹង ប្រទេសណេប៉ាល់* លិខិតទំនាក់ទំនងលេខ 1863/2009, CCPR/C/105/D/1863/2009, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ("*រឿងក្តី Maharjan ទល់នឹង ប្រទេសណេប៉ាល់*") កថាខណ្ឌ ៨.៣ និងសេចក្តីយោងត្រូវបានដកស្រង់ទៅទីនោះ។ *រឿងក្តី Womah Mukong ទល់នឹង Cameroon*, លិខិតទំនាក់ទំនងលេខ 458/1991, CCPR/C/51/D/458/1991, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៩.២។

ការចោទប្រកាន់នេះ ត្រូវតែទទួលបានតម្លៃត្រឹមត្រូវ និងអាចត្រូវបានទទួលយកថាមានភស្តុតាងគាំទ្រត្រឹមត្រូវ[117]។

52. នៅតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បទដ្ឋាន និងការបែងចែកបន្ទុកបង្ហាញភស្តុតាង ត្រូវបានរកឃើញថា ជាការផ្អែកលើភាពជាក់លាក់នៃអង្គហេតុរបស់រឿងក្តីនីមួយៗ លើលក្ខខណ្ឌនៃការចោទប្រកាន់ និងសិទ្ធិមនុស្សដែលចោទជាបញ្ហា[118]។ យោងតាមយុត្តិសាស្ត្រខាងលើ "ភស្តុតាង អាចកើតតាមក្រោយបន្ទាប់ពីមានការធ្វើសេចក្តីសន្និដ្ឋានប្រកបដោយភាពស៊ីសង្វាក់គ្នា ច្បាស់លាស់ និងស្របគ្នាយ៉ាងគ្រប់គ្រាន់ ឬមានការសន្មតយ៉ាងស្របគ្នានៃអង្គហេតុដែលពុំបានជំទាស់"[119]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានរកឃើញផងដែរថា ទាក់ទងនឹងការចោទប្រកាន់នៃការធ្វើទារុណកម្ម ជាពិសេសដែលថា "កិច្ចដំណើរការនីតិវិធី ពុំបានគាំទ្រទៅលើការអនុវត្តយ៉ាងតឹងរ៉ឹងនូវគោលការណ៍ស្តីពី *បន្ទុកក្នុងការបង្ហាញភស្តុតាងគឺ ជារបស់អ្នកអះអាង' គួរកត់សម្គាល់នៅពេល* "ព្រឹត្តិការណ៍ដែលចោទជាបញ្ហានេះ គឺរដ្ឋអំណាចតែម្នាក់ឯងបានដឹងទាំងស្រុង ឬមួយផ្នែកធំថាកើតមាន ដូចជាករណីដែលបុគ្គលម្នាក់ ស្ថិតក្នុងការឃុំឃាំងរបស់រដ្ឋអំណាច"[120]។ ការចោទប្រកាន់អំពីការធ្វើទារុណកម្ម គឺអាចជឿជាក់បាន ប្រសិនបើមានភស្តុតាងគាំទ្រស្តីអំពីលំនាំនៃការរំលោភសិទ្ធិមនុស្សប្រហាក់ប្រហែលគ្នា ជាឧទាហរណ៍ មានការតវ៉ាយ៉ាងច្រើនអំពីអំពើប្រហាក់ប្រហែលគ្នា ដែលមានភស្តុតាងគាំទ្រយ៉ាងស៊ីសង្វាក់គ្នា[121]។ ផ្ទុយទៅវិញ នៅពេលដែលប្រព័ន្ធតុលាការ ឯករាជ្យ និងឥតលម្អៀង ហើយ "ការចោទប្រកាន់អំពីការធ្វើទារុណកម្ម ត្រូវបានស៊ើបអង្កេតដោយសម្បជញ្ញៈ" វិញនោះ គឺអាចប្រមើលដឹងថា ប្រាកដជាតម្រូវឱ្យមានបទដ្ឋានភស្តុតាងខ្ពស់ហើយ[122]។ ក្នុង*រឿងក្តី El Haski*

[117] *រឿងក្តី Maharjan ទល់នឹង ប្រទេសណេប៉ាល់* កថាខណ្ឌ ៨.៣។ គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស *រឿងក្តី Shukurova ទល់នឹង Tajikistan*, លិខិតទំនាក់ទំនងលេខ 1044/2002, CCPR/C/86/D/1044/2002, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៨.២។

[118] *រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ* កថាខណ្ឌ ៣៩៤ និងសេចក្តីយោងដែលបានដកស្រង់នៅទីនោះ។

[119] *រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ* កថាខណ្ឌ ៣៩៤។

[120] *រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ* កថាខណ្ឌ ៣៩៦។

[121] *រឿងក្តី ប្រទេស Denmark ទល់នឹង ប្រទេសក្រិច* សំណើសុំលេខ 3321/67។ *រឿងក្តីប្រទេស Norway ទល់នឹង ប្រទេសក្រិច* សំណើសុំលេខ 3322/67។ *រឿងក្តីប្រទេស Sweden ទល់នឹង ប្រទេសក្រិច* សំណើសុំលេខ 3323/67។ *រឿងក្តីប្រទេសហូឡង់ ទល់នឹង ប្រទេសក្រិច* សំណើសុំលេខ 3344/67 *នៅក្នុងសៀវភៅប្រចាំឆ្នាំនៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* ភាគ ១២ ឆ្នាំ ១៩៦៩ ទំព័រ ៥០២ កថាខណ្ឌ ១៤។

[122] *រឿងក្តី El Haski ទល់នឹង Belgium* កថាខណ្ឌ ៨៦ និង ៨៨។ *រឿងក្តី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៧២ ដល់ ២៨០ និង ២៨២។

*ទល់នឹង ប្រទេស Belgium ក៏ដូចជាក្នុងរឿងក្ដី Othman* វិធានបដិសេធភស្តុតាង ត្រូវបានយកមកអនុវត្ត នៅពេលមាន "ហានិភ័យពិតប្រាកដ"កើតឡើងដែលចម្លើយសារភាពនេះ បានមកពីការធ្វើទារុណកម្ម ឬ អំពើអមនុស្សធម៌ ឬការបន្ទាបបន្ថោកតម្លៃមនុស្ស ដោយសារ"ការលំបាកយ៉ាងពិសេស ក្នុងការបង្ហាញ ភស្តុតាងលើការចោទប្រកាន់អំពីការធ្វើទារុណកម្ម ... នៅក្នុងប្រព័ន្ធព្រហ្មទណ្ឌដែលជាប់ពាក់ព័ន្ធនៅក្នុង ការអនុវត្តន៍នានា ដែលប្រព័ន្ធនេះបង្កើតឡើងដើម្បីទប់ស្កាត់"[123]។

53. ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុង*រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Martić* បានអនុវត្តតាមសេចក្ដីណែនាំស្ដីពីបទដ្ឋានដែលចែងអំពីការ ទទួលយកភស្តុតាង[124] ដែលបានចែងលម្អិតអំពីលក្ខខណ្ឌរបស់វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ហាមឃាត់ភស្តុតាង "ដែលទទួលបានតាមវិធីសាស្ត្រដែលគួរឱ្យសង្ស័យយ៉ាងខ្លាំងលើភាពអាចជឿ ទុកចិត្តបាននៃភស្តុតាង" និងហាមឃាត់ការទទួលយកភស្តុតាងដែល"ផ្ទុយ និងធ្វើឱ្យខូចយ៉ាងធ្ងន់ធ្ងរដល់ សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី"[125]។ សេចក្ដីណែនាំ បានកំណត់យ៉ាងគួរឱ្យកត់សម្គាល់ថា ប្រសិនបើ មាន"*សេចក្ដីបញ្ជាក់ដំបូង*"ថា ចម្លើយនេះ ពុំត្រូវបានផ្ដល់ឱ្យដោយស្ម័គ្រចិត្ត នោះបន្ទុកត្រូវធ្លាក់ទៅលើភាគី ដែលជាអ្នកស្នើសុំឱ្យទទួលយកភស្តុតាង ក្នុងការបង្ហាញថា ចម្លើយនេះ ពុំមែនបានមកតាមរយៈការបង្ខិត បង្ខំឡើយ[126]។ នៅក្នុងករណីផ្សេងទៀតនៅពេលដែល មេធាវីការពារក្ដីបានលើកឡើងថា ចម្លើយសារភាព របស់ជនជាប់ចោទ បានមកតាមរយៈការបង្ខិតបង្ខំ តុលាការ ICTY បញ្ជាក់ថា នៅក្នុងបរិបទក្នុងការ សម្រេចថាតើ ត្រូវអនុវត្តនីតិវិធីប្រហាក់ប្រហែលគ្នាទៅនឹង*ការធ្វើសម្បថ*ដែលមាននៅក្នុងយុត្តាធិការរបស់ ប្រព័ន្ធអង់គ្លូសាក់សុង ដែរ ឬយ៉ាងណា ជាដំបូង មេធាវីការពារក្ដី ត្រូវតែ"ធ្វើឱ្យតុលាការជឿជាក់" ដោយ

---

[123] *រឿងក្ដី El Haski ទល់នឹង Belgium* កថាខណ្ឌ ៨៦ និង ៨៨។ *រឿងក្ដី Othman ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៣, ២៧២, ២៧៦ និង ២៨៥។

[124] *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Milan Martić* សំណុំរឿងលេខ IT-95-11-T "សេចក្ដីសម្រេចអនុម័តគោលការណ៍ណែនាំលើ បទដ្ឋានដែលគ្រប់គ្រងការទទួលយកភស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦ ("*រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង* Martic") ឧបសម្ព័ន្ធ ក កថាខណ្ឌ ៩។

[125] វិធាន ៩៥ របស់តុលាការ ICTY ស្ដីពីនីតិវិធី និងភស្តុតាង។

[126] *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Martić* កថាខណ្ឌ ៩ ដែលត្រូវបានអះអាងបញ្ជាក់នៅក្នុង *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, សំណុំរឿងលេខ IT-95-5/18-T "សេចក្ដីសម្រេចស្ដីពីគោលការណ៍ណែនាំសម្រាប់ការទទួលយកភស្តុតាងតាម រយៈសាក្សី", អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១១ យោងទៅលើ*ក្នុងនោះ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Perišić សំណុំរឿងលេខ* IT-04-81-T "ដីកាស្ដីពីគោលការណ៍ណែនាំសម្រាប់ការទទួលយក និងការបង្ហាញភស្តុតាង និងក្រមសីលធម៌របស់មេធាវីនៅក្នុងតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៨។

បង្ហាញថា ចម្លើយសារភាព*ប្រហែល*ជាបានមកតាមមធ្យោបាយដែលធ្វើឱ្យចម្លើយនេះពុំអាចជឿទុកចិត្តបាននៅចំពោះមុខតុលាការ។ នៅពេលដែលលក្ខខណ្ឌនេះបានបំពេញរួចហើយ អយ្យការត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ចម្លើយសារភាពនេះ បានមកដោយស្ម័គ្រចិត្ត[127]។

54. បទដ្ឋានភស្តុតាង គឺជាបញ្ហាគន្លឹះនៅក្នុងយុត្តាធិការក្នុងស្រុក ដែលមួយចំនួន បានលំអៀងទៅរកវិធីសាស្ត្រដែលមានលក្ខណៈដូចគ្នា ទាក់ទងនឹងបន្ទុក និងបទដ្ឋាននៃភស្តុតាង[128]។ រឿងក្តីដែលលេចធ្លោជាងគេ

---

[127] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Zejnil Delalić និង អ្នកដទៃទៀត* សំណុំរឿងលេខ IT-96-21 “សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទសុំដកភស្តុតាងចេញ, ជនជាប់ចោទ Zejnil Delalić” អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣១ ដល់ ៣៣ និង ៤០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Zejnil Delalić និងអ្នកដទៃទៀត* (សំណុំរឿងលេខ IT-96-21) “សេចក្តីសម្រេចលើសំណើរបស់ Zdravko Mucić សុំដកភស្តុតាងចេញ” អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៤២ និង ៤៨ (យល់ឃើញថា រដ្ឋអាជ្ញាមានកាតព្វកិច្ច ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ចម្លើយរបស់ជនជាប់ចោទ ឬជនសង្ស័យ ពុំមែនបានមកពីការបង្ខិតបង្ខំឡើយ)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Sefer Halilović* សំណុំរឿងលេខ IT-01-48-T “សេចក្តីសម្រេចស្តីពីការទទួលយកជាភស្តុតាងនូវការស្តាប់ចម្លើយរបស់ជនជាប់ចោទ” អង្គជំនុំជម្រះសាលាដំបូង I ផ្នែក A ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ១១ និង ១៧ (បដិសេធសំណើរបស់មេធាវីការពារក្តីសុំបើកសវនាការទទួលយកភស្តុតាង ដោយសារមានភស្តុតាងគាំទ្រការចោទប្រកាន់របស់មេធាវីការពារក្តីថា ការស្តាប់ចម្លើយរបស់ជនជាប់ចោទពុំបានធ្វើឡើងដោយស្ម័គ្រចិត្តឡើយ។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Sefer Halilović* សំណុំរឿងលេខ IT-01-48-AR73.2 “សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់ជនជាប់ចោទពីតុអង្គុយក្នុងតុលាការ”អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ៤៦ (ធ្វើការរិះគន់ដល់អង្គជំនុំជម្រះសាលាដំបូងលើ*រឿងក្តី Halilović* ដោយសារពុំបានពិចារណាថា ការសម្រាកក្នុងអំឡុងពេលស្តាប់ចម្លើយរបស់ជនជាប់ចោទ គឺជាធាតុមួយគ្រប់គ្រាន់សម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង“ពិនិត្យមើលបានយ៉ាងពេញលេញលើការស្ម័គ្រចិត្តនៃការស្តាប់យកចម្លើយនោះ” ដោយពុំចាំបាច់បើកសវនាការលើភស្តុតាងឡើយ)។

[128] *សូមមើល រឿងក្តី ប្រទេសឥណ្ឌា ទល់នឹង Singh* (ឆ្នាំ ១៩៩៦) សំណុំរឿងលេខ 108 C.C.C. (3d) 274 (B.C.S.C.) ប្រទេសកាណាដា កថាខណ្ឌ ២១, ៣៣ (កិច្ចដំណើរការនីតិវិធីលើការធ្វើបត្យាប័នដែលបានអនុវត្តតាមបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាព ដោយយល់ឃើញ ការចោទប្រកាន់នៃការធ្វើទារុណកម្ម ត្រូវបានបង្កើតតាមបទដ្ឋានតម្រូវនៅក្នុងសំណុំរឿងដែលក្នុងនោះ “ខ្លឹមសារដែលមានលក្ខណៈគួរឱ្យជឿបាន” ពុំមានលើកឡើងពីការបដិសេធណាមួយរបស់អ្នកធ្វើទារុណកម្មដែលត្រូវបានចោទប្រកាន់ឡើយ)។ *រឿងក្តី Li ទល់នឹង ប្រទេសកាណាដា (រដ្ឋមន្ត្រីនៃក្រសួងអន្តោប្រវេសន៍ និងសញ្ជាតិ)* ឆ្នាំ ២០០៥ FCA 1 (ប្រទេសកាណាដា) កថាខណ្ឌ ២១ ដល់ ២៨ ។ *រឿងក្តី Suresh ទល់នឹង ប្រទេស កាណាដា* [ឆ្នាំ ២០០០] សំណុំរឿងលេខ 2 FCR 592, កថាខណ្ឌ ១៥១ ដល់ ១៥២ (ទាំងការអនុម័តបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាពនៅក្នុងរឿងក្តីនៃការបណ្តេញជនភៀសខ្លួនទៅកាន់ប្រទេសមួយដែលធ្វើឱ្យបុគ្គលនោះទទួលរងនូវហានិភ័យនៃការធ្វើទារុណកម្ម)។ *រឿងក្តី Harkat (ជនភៀសខ្លួន)*, សំណុំរឿងលេខ 2005 FC 393 (កាណាដា), កថាខណ្ឌ ១១៦ (នីតិវិធីស្តីពីអន្តោប្រវេសន៍បានអនុម័តតាមតុល្យភាពនៃបទដ្ឋានស្តីពីភវនីយភាព)។ *សូមមើល* ដោយផ្ទុយគ្នា *រឿងក្តី Mohammad Zeki Mahjoub ទល់នឹង ប្រទេស កាណាដា (រដ្ឋមន្ត្រីក្រសួងអន្តោប្រវេសន៍ និងសញ្ជាតិ)*, សំណុំរឿងលេខ 2006 FC 1503, (កាណាដា), កថាខណ្ឌ ៣០ និង ៣៣

គឺ *រឿងក្តី Mounir El-Motassadeq* នៅចំពោះមុខ Hanseatisches Oberlandesgericht (តុលាការជាន់ខ្ពស់ក្នុងស្រុក) ក្នុងទីក្រុង Hamburg ប្រទេសអាល្លឺម៉ង់[129] ("*រឿងក្តី El-Motassadeq*") និង *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* នៅចំពោះមុខសភាជាន់ខ្ពស់របស់ប្រទេសអង់គ្លេស[130]។ នៅក្នុងរឿងក្តីទីមួយ តុលាការនៃទីក្រុង Hamburg បានរកឃើញថា នៅក្នុងស្ថានភាពដែលមានតែការបញ្ជាក់ខ្លះៗថា ភស្តុតាងបានមកតាមរយៈការធ្វើទារុណកម្ម ភស្តុតាងនេះ អាចត្រូវបានប្រើប្រាស់ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[131]។ មតិភាគច្រើននៃសភាជាន់ខ្ពស់បានយល់ស្របថា អ្នកតវ៉ា ពុំត្រូវបានគេរំពឹងថានឹងបង្ហាញ ភស្តុតាងអ្វីនោះទេ ដោយសារជាធម្មតាទទួលបានព័ត៌មានតិចតួច ដូច្នេះ អ្នកតវ៉ា គ្រាន់តែអាច"លើកបញ្ហា" នៅចំពោះមុខរដ្ឋអំណាចដែលមានសមត្ថកិច្ចប៉ុណ្ណោះ[132]។ ទោះជាយ៉ាងណាក្តី ផ្អែកលើ *រឿងក្តី El-Motassadeq* មតិភាគច្រើនយល់ឃើញថា ភស្តុតាងត្រូវតែដកចេញ តែក្នុងករណីដែលភស្តុតាងនោះបង្ហាញថា "តាមរយៈ [...] ការស៊ើបអង្កេតយ៉ាងហ្មត់ចត់ទៅលើប្រភពដើម តាមដែលអាចធ្វើទៅបាន និងផ្អែកលើបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាព" បានមកពីការធ្វើទារុណកម្ម[133]។ នៅក្នុងករណីដែលមានមន្ទិលសង្ស័យ ភស្តុតាង គឺអាចទទួលយកបាន បើទោះបីកត្តាសង្ស័យនេះ ជិតជាប់នៅក្នុងអារម្មណ៍ពេលធ្វើការវាយតម្លៃភស្តុតាងនេះក៏ដោយ[134]។ ដោយហេតុថា បទដ្ឋាននេះ បានទទួលការរិះគន់ពីបញ្ហាសិទ្ធិមនុស្ស ព្រោះមានបន្ទុកធ្ងន់ធ្ងរពេក ហើយខកខានពុំបានទំលាក់បន្ទុកក្នុងការបង្ហាញភស្តុតាងឱ្យ

---

(ថាតើ ម្ចាស់បណ្តឹង មានឱកាសជាក់ស្តែងទៅតាមកាលៈទេសៈ ដើម្បីផ្តល់ព័ត៌មានលម្អិតគាំទ្រការចោទប្រកាន់ អំពីការធ្វើទារុណកម្ម គឺមានសារៈសំខាន់ចំពោះការយល់ឃើញទាំងនោះ ដែរ ឬយ៉ាងណា)។ សូមមើលផងដែរ *រឿងក្តី អ្នកជាប់ឃុំនៅ Re Guantánamo Detainee Cases*, សំណុំរឿងលេខ 355 F. Supp. 2d 443 (D.D.C. 2005),ទំព័រ ៤៧៤ (អ្នកជាប់ឃុំឃាំងដែលបានដាក់ពាក្យបណ្តឹង ត្រូវបានតម្រូវឱ្យលើក"ការចោទប្រកាន់ឱ្យបានគ្រប់គ្រាន់")។

[129] តុលាការជាន់ខ្ពស់ក្នុងតំបន់ Hamburg នៅអាល្លឺម៉ង់ សេចក្តីសម្រេចចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥ សំណុំរឿងលេខ 2 BJs 85/01 – 2 StE 4/02 - 5 IV – 1/04, (មានជាភាសាអាល្លឺម៉ង់នៅគេហទំព័រ៖ http://openjur.de/u/86173.html [គេហទំព័រនេះ ត្រូវបានចូលក្នុងនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥])។

[130] *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* [ឆ្នាំ ២០០៥] UKHL 71 ("*រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ(លេខ ២)*") កថាខណ្ឌ ១១៦ ដល់ ១១៨ (កិច្ចដំណើរការនីតិវិធីលើការនិរទេសដែលបានអនុម័តតុល្យភាពនៃបទដ្ឋានស្តីពីភវនីយភាព)។

[131] *រឿងក្តី El-Motassadeq* កថាខណ្ឌ ១២ និង ២៤។

[132] *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ១១៦។

[133] *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ១២៥។ *ចៅក្រម* Lord Hope ត្រូវបានដកស្រង់ថា ស្របជាមួយនឹង *រឿងក្តី Mounir El-Motassadeq*។

[134] *រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ១១៨។

ទៅរដ្ឋ[135] ដូច្នេះ គេពុំត្រូវមើលរំលងករណីដែលថា នៅពេលដែលរដ្ឋ ពុំបានប្រមូលភស្តុតាង ដែលជាអ្នកចោទប្រកាន់ទេនោះ រដ្ឋពុំស្ថិតក្នុងតួនាទីល្អប្រសើរជាងជនជាប់ចោទឡើយ ក្នុងការបង្ហាញថាតើព័ត៌មាននេះ បានមកពីការធ្វើទារុណកម្មដែរ ឬយ៉ាងណា[136]។

55. ជាការសន្និដ្ឋាន ក្នុងការដោះស្រាយលើបញ្ហាស្តីពីភស្តុតាងដែលអាចនុវត្តបានចំពោះវិធានបដិសេធភស្តុតាង ហាក់បីដូចជាមានយោបល់ស្របគ្នាមួយថា ដោយសារតែការបានទទួលព័ត៌មានតិចតួច និងពុំសមាមាត្រជាមួយនឹងរដ្ឋអំណាចសាធារណៈ បុគ្គលនីមួយៗ ពុំអាចត្រូវបានរំពឹងថាជាអ្នកទទួលបន្ទុកទាំងមូលក្នុងការបង្ហាញថា ចម្លើយសារភាពមួយ ត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្មឡើយ។ ដំណោះស្រាយ ជារឿយៗ គឺផ្អែកលើភាពចាំបាច់ដែលបុគ្គលគឺជាអ្នកដំបូងគេ ត្រូវលើកទឡ្ហីករណ៍គួរឱ្យជឿជាក់បាន*ជាសេចក្តីបញ្ជាក់ដំបូង*ថា ភស្តុតាងនេះបានទទួល ដោយពុំត្រឹមត្រូវនោះឡើយ ដើម្បីទម្លាក់បន្ទុកក្នុងការស្វែងរកភស្តុតាងនេះឱ្យតុលាការ និងជម្រុញឱ្យតុលាការស៊ើបអង្កេត ឬចោទប្រកាន់។ បទដ្ឋាននៃភស្តុតាងដែលត្រូវអនុវត្តក្នុងជំហានបន្ត ដើម្បី“បង្ហាញ”ថា ចម្លើយសារភាពស្ថិតក្រោមវិធានបដិសេធភស្តុតាង ពុំបានបញ្ជាក់ច្បាស់លាស់អំពីមូលហេតុឡើយ។ ស្ថាប័នស្តីពីសិទ្ធិមនុស្សជ្រើសរើសមិនដាក់បញ្ចូលភស្តុតាងបន្ទាប់ពីរកឃើញនូវ“ហានិភ័យពិតប្រាកដ”នៃការធ្វើទារុណកម្ម ដែលបានប្រព្រឹត្តឡើងទាក់ទងនឹងប្រព័ន្ធតុលាការដែល “ពុំបានផ្តល់ការធានាដ៏មានអត្ថន័យនៃការពិនិត្យមើលប្រកបដោយឯករាជ្យ ឥតលម្អៀង និងពិតប្រាកដ”លើការចោទប្រកាន់នៃការធ្វើទារុណកម្ម[137]។ ពាក់ព័ន្ធនឹងបញ្ហានេះ ដូចបានពិភាក្សាខាងលើ[138] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងគណៈកម្មាធិការសិទ្ធិមនុស្ស បានត្រៀមខ្លួនជាស្រេច ក្នុងការស្វែងរកឱ្យឃើញថា ចម្លើយ ពិតជាបានមកពីការធ្វើទារុណកម្ម នៅពេលដែលការចោទប្រកាន់នេះ ពុំត្រូវបានបដិសេធដោយរដ្ឋដែលពាក់ព័ន្ធនោះ ដោយហេតុថា អ្នកតវ៉ា បានចោទប្រកាន់ថា ខ្លួនបានទទួលរងការធ្វើទារុណកម្ម និងថា ការធ្វើទារុណកម្មមានលក្ខណៈរីករាលដាល។

---

[135] របាយការណ៍របស់អ្នករាយការណ៍ពិសេសលេខ A/61/259 កថាខណ្ឌ ៦៥។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សនៅក្នុង*រឿងក្តី El Haski* កថាខណ្ឌ ៨៦ *និងរឿងក្តី Othman* កថាខណ្ឌ ២៧៤ និង២៧៦។ មតិភាគតិចរបស់ចៅក្រម Lord Bingham ក្នុង*រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ៦០។

[136] *សូមមើល រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ១១៩ និង ១២៥។ សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម: សេចក្តីអធិប្បាយ* ទំព័រ ៥៣៣។

[137] *រឿងក្តី El Haski ទល់នឹង Belgium*, កថាខណ្ឌ ៨៨។

[138] កថាខណ្ឌ ៥០ ដល់ ៥២ *ខាងលើ*។

01185988



56. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងបរិបទនៃសំណុំរឿងនៅចំពោះមុខ អង្គជំនុំជម្រះអាចទទួលយកការអះអាងដែលថា មាន"ហានិភ័យពិតប្រាកដ" ដែលចម្លើយសារភាពនៅមន្ទីរ ស-២១ បានមកតាមរយៈការធ្វើទារុណកម្ម។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះបានគាំទ្រសេចក្ដីសន្និដ្ឋានរបស់សាលាដំបូងដែលថា៖

> "នៅមន្ទីរ ស-២១ 'មានវិធីសាស្ត្រធ្វើទារុណកម្មច្រើនប្រភេទ'សម្រាប់គោលបំណងសួរយកចម្លើយ 'ត្រូវបានអនុវត្តនៅក្នុង*ស្ថានភាពដែលពោរពេញទៅដោយការភ័យខ្លាចយ៉ាងខ្លាំង* ដោយហេតុថា មានការគំរាមកំហែង ត្រូវបានយកមកប្រើប្រាស់ជាប្រចាំ និងបានធ្វើឱ្យអ្នកជាប់ឃុំឃាំងមានការឈឺចាប់ និងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត'។ វិធីសាស្ត្រនៃការសួរយកចម្លើយនេះ រួមមាន 'ការរំលោភលើផ្លូវភេទមួយករណី'។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា 'អ្នកសួរយកចម្លើយនៅមន្ទីរ ស-២១ [...] ដែលបានប្រព្រឹត្តអំពើធ្វើទារុណកម្ម បានបំពេញភារកិច្ចក្នុងសមត្ថកិច្ចជាផ្លូវការ'។ មន្ត្រីទាំងនេះ បានប្រព្រឹត្តអំពើដែលបង្កើតបានជាបទល្មើសនៃការធ្វើទារុណកម្ម 'សម្រាប់គោលបំណងដើម្បីទទួលបាន នូវចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម'[139]។

57. បន្ថែមលើនេះ កាំង ហ្គេក អ៊ាវ (*ហៅ* ឌុចដែលត្រូវបានចោទប្រកាន់ និងដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០១) ខ្លួនឯងផ្ទាល់ បានទទួលស្គាល់ថា អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ទទួលរងការសួរយកចម្លើយជាប្រព័ន្ធដោយមានការប្រើអំពើហិង្សាជាប្រចាំ[140] ក្នុងគោលបំណងទាញយកចម្លើយសារភាពតាមរយៈការធ្វើទារុណកម្ម ដែលគាត់បានសរសេរហាមប្រាមក្នុងចំណារយ៉ាងលម្អិត។ ចំណារនេះ ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យផងដែរ[141]។ ជាលទ្ធផល អ្នកជាប់ឃុំឃាំងទៅមន្ទីរ ស-២១ រស់នៅក្នុង "បរិយាកាសភ័យខ្លាចជាអចិន្ត្រៃយ៍"[142]។ មានការបង្ហាញ អ្នកជាប់ឃុំឃាំង អាច"ស្ដាប់ឮសម្លេងស្រែកយំ"[143] និងអាចឃើញថា "អ្នកជាប់ឃុំឃាំងដទៃទៀតពេលត្រឡប់មកពីការសួរយកចម្លើយវិញ មានស្នាមវាយធ្ងន់ធ្ងរ ស្នាមដាច់រយះ ស្នាមជាំ និងស្នាមមុត" [144]។ យោងតាមការយល់ឃើញអំពីការធ្វើទារុណកម្ម

[139] សាលដីកាចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 ("សាលដីកាក្នុងសំណុំរឿង ០០១") កថាខណ្ឌ ២០៩ *ដកស្រង់* សាលក្រមក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមក្នុងសំណុំរឿង ០០១") កថាខណ្ឌ ២៤១ និង ៣៥៩ ដល់ ៣៦០ (សេចក្ដីបញ្ជាក់បន្ថែម)។

[140] សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ១៥៣ ជាដើម និងសេចក្ដីយោងទៅទីនោះ។

[141] សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ១៧៦ ដល់ ១៧៧។

[142] សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២៥៨។

[143] សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២៦២។

[144] សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២៦៤។

ក្នុងសំណុំរឿង ០០១ ការធ្វើបាបលើរូបកាយ និងការឈឺចាប់ផ្លូវចិត្ត ដោយពុំមានភស្តុតាងគាំទ្រណាដែលផ្ទុយនោះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា មានហានិភ័យពិតប្រាកដ ដែលចម្លើយនៅមន្ទីរ ស-២១ បានមកពីការធ្វើទារុណកម្ម និងចម្លើយនីមួយៗ អាចត្រូវបានសន្មតយ៉ាងដូច្នោះទាំងអស់។

58. ទាក់ទងទៅនឹងកម្រិតនៃភស្តុតាងដែលតម្រូវសម្រាប់គោលបំណងក្នុងការលើកយកចម្លើយសារភាពនៅមន្ទីរ ស-២១ ធ្វើជាស្តុតាងសម្រាប់ការបង្ហាញការពិតនៃអង្គហេតុ ដែលបានពិពណ៌នានោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការផ្អែកទៅលើតែការសន្មតដែលថា រាល់ចម្លើយនៅមន្ទីរ ស-២១ គឺជាលទ្ធផលនៃការធ្វើទារុណកម្មនោះ ពុំស្របជាមួយនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការបង្ហាញការពិត ពាក់ព័ន្ធនឹងបទចោទឡើយ។ ការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ពុំត្រូវបានចោទប្រកាន់ថាបានកើតឡើង ដោយមានការដឹងឮពីស្ថាប័នដែលជាតំណាងអយ្យការឡើយ។ អាស្រ័យហេតុនេះ ស្ថាប័នដែលជាតំណាងអយ្យការ ពុំស្ថិតក្នុងតួនាទីប្រសើរជាងតួនាទីរបស់ភាគីក្នុងការបញ្ជាក់ ឬបដិសេធការអះអាងដែលថា ព័ត៌មាននេះ គឺបានមកពីការធ្វើទារុណកម្ម។ លើសពីនេះទៀត ការដកព័ត៌មាននេះចេញភ្លាមៗដោយសារមានហានិភ័យពិតប្រាកដដែលថា បានទទួលមកពីការធ្វើទារុណកម្ម ក្នុងកាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ននេះ នឹងអាចធ្វើឱ្យប៉ះពាល់ដល់ នួន ជា ដែលផ្អែកលើចម្លើយនៅមន្ទីរ ស-២១។ អាស្រ័យហេតុនេះ ភាគីណាដែលសុំផ្អែកលើចម្លើយនៅមន្ទីរ ស-២១ គប្បីត្រូវបានអនុញ្ញាតឱ្យជំទាស់ទៅនឹងការសន្មតនេះ ដោយផ្តល់ភស្តុតាងបញ្ជាក់ថា ព័ត៌មានដែលចោទជាបញ្ហានេះ ពុំមែនជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ។ យោងតាមសំអាងហេតុខាងលើ នៅពេលសម្រេចលើបញ្ហានេះ អង្គជំនុំជម្រះចាំបាច់ត្រូវពិចារណាលើព័ត៌មានពាក់ព័ន្ធដែលខ្លួនបានដឹងបន្ថែមលើសារណារបស់ភាគី។ ជាចុងក្រោយ ចម្លើយនៅមន្ទីរ ស-២១ អាចត្រូវបានទទួលយកជាភស្តុតាងតែក្នុងករណីដែល ចម្លើយនេះបានបង្ហាញឱ្យឃើញថា ផ្អែកលើបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាព *ពុំមែន*ជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ។

59. សម្រាប់គោលបំណងនៃសវនាការខែ កក្កដា ឆ្នាំ ២០១៥ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចម្លើយនៅមន្ទីរ ស-២១ ត្រូវបានបង្ហាញថា បានមកពីការធ្វើទារុណកម្ម។ អាស្រ័យហេតុនេះ ចម្លើយនេះ ស្ថិតក្រោមវិធានបដិសេធភស្តុតាងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ខ្លួននឹងធ្វើការវាយតម្លៃក្នុងកាលៈទេសៈដែលភាគីមានបំណងចង់ប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ ក្នុងការសួរសាក្សីក្នុងសវនាការ ខែ កក្កដា ឆ្នាំ ២០១៥។ ហេតុនេះ សារៈសំខាន់នៃចម្លើយនៅមន្ទីរ ស-២១ ចំពោះកិច្ចដំណើរការនីតិវិធី នៅទាបជាងការដែលចម្លើយនេះ ត្រូវបានទទួលយកជាភស្តុតាង។ បន្ថែមលើនេះទៀត ពុំមានភាគីណាមួយដែលស្នើសុំប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ បានអះអាងថា ចម្លើយទាំងនេះ ពុំបានមកពីការធ្វើទារុណកម្មនោះទេ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល ពុំតម្រូវឱ្យធ្វើការពិនិត្យឱ្យបានល្អិតល្អន់លើបញ្ហាថាតើចម្លើយនៅមន្ទីរ ស-២១ បានទទួលមកយ៉ាងដូចម្តេចឡើយ។

**ឃ. តើមាត្រា ១៥ នេះ អាចត្រូវបានធ្វើបដិប្បញ្ញត្តិ ដើម្បីអាចប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ ក្នុងការជួយដល់ការការពារក្តីរបស់ នួន ជា បានដែរ ឬទេ?**

60. នួន ជា អះអាងថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គ្រាន់តែបានហាមឃាត់មិនឱ្យប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មនេះ*ប្រឆាំងនឹង*ជនជាប់ចោទតែប៉ុណ្ណោះ ហេតុនេះមានអានុភាពក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងទាំងនេះបាន*ដោយ*ជនជាប់ចោទ ដូចបានបញ្ជាក់តាមរយៈការអនុវត្តជាបន្តបន្ទាប់របស់រដ្ឋ ឧទាហរណ៍នៃការអនុវត្តនេះ បានកម្រិតវិធានបដិសេធភស្តុតាងទៅលើតែភស្តុតាង ដែលបានផ្តល់ឱ្យដោយអយ្យការតែប៉ុណ្ណោះ[145]។ នួន ជា ជំទាស់ថា កម្មវត្ថុ និងគោលបំណងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺគ្រាន់តែចង់ធ្វើការរារាំងអយ្យការកុំឱ្យទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ព័ត៌មាន ដែលបានមកពីការធ្វើទារុណកម្មតែប៉ុណ្ណោះ ប៉ុន្តែមិនមែនគ្របដណ្តប់លើគ្រប់ស្ថានការណ៍នោះឡើយ ជាពិសេស នៅពេលដែលជនជាប់ចោទមានបំណងចង់ប្រើប្រាស់ភស្តុតាងនេះ ដើម្បីបញ្ជាក់ពីភាពគ្មានទោសរបស់ខ្លួនបាន[146]។

61. ជាចំណុចចាប់ផ្តើម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការពិតដែលថា ប្រព័ន្ធតុលាការក្នុងស្រុកមួយចំនួន មានវិធានបដិសេធភស្តុតាងច្បាស់លាស់ទាក់ទងតែភស្តុតាង ដែលបានបង្ហាញដោយភ្នាក់ងារស៊ើបអង្កេត ឬចោទប្រកាន់លើរឿងក្តីតែប៉ុណ្ណោះ គឺគ្រាន់បង្ហាញថា សេចក្តីសម្រេចផ្នែកនីតិបញ្ញត្តិត្រូវបានកម្រិតត្រឹមតែដោះស្រាយលើលំនាំបញ្ហានៃការរំលោភបំពាន ដែលកើតមានញឹកញាប់តែប៉ុណ្ណោះ ប៉ុន្តែពុំបានបង្ហាញថា ភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម គឺអាចទទួលយកបានដោយស្របច្បាប់នៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកទាំងនោះនៅក្នុងស្ថានការណ៍ដទៃទៀតឡើយ[147]។ ពាក់ព័ន្ធបញ្ហានេះ គប្បី

---

[145] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧១២ ដល់ ៧១៦។

[146] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧១៧ ដល់ ៧២២។

[147] ពាក់ព័ន្ធនឹងឧទាហរណ៍ដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា (*សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧១៤ ដល់ ៧១៥ និង ៧២១ ដល់ ៧២២) អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ប្រភពដែលបានដកស្រង់ដូចជា(បណ្តាញសហគមន៍អឺរ៉ុបនៃអ្នកជំនាញឯករាជ្យស្តីពីសិទ្ធិជាសារវ័ន្ត "មតិយោបល់លើប្រភេទនៃភស្តុតាងដែលបានមកដោយខុសច្បាប់ក្នុងនីតិវិធីព្រហ្មទណ្ឌនៅក្នុងរដ្ឋជាសមាជិករបស់សហគមន៍អឺរ៉ុប" CFR-CDF ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ (មតិយោបល់របស់សហគមន៍អឺរ៉ុប) ទំព័រ ៧), បានផ្តោតលើភាពអនីត្យានុកូលក្នុងការរំលោភបំពាលើសិទ្ធិជីវភាពឯកជន ដោយបានចាត់បញ្ជាក់យ៉ាងច្បាស់ពីការអនុវត្តមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ថាជាការហាមឃាត់មួយដែលពុំ

អាចត្រូវបានពិចារណាធ្វើបដិប្បញ្ញត្តិបានឡើយ។ *សូមមើល* "ក្របខ័ណ្ឌច្បាប់" មតិយោបល់របស់សហគមន៍អឺរ៉ុប ទំព័រ ៦ ជើងទំព័រ ៧ និងទំព័រ ៧។ ឧទាហរណ៍ជាក់លាក់ដែលត្រូវបានដកស្រង់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា ស្តីពីការមិនគោរពតាមវិធានបដិសេធភស្តុតាងដោយលម្អៀងទៅរកជនជាប់ចោទ ដែលត្រូវបានដកស្រង់នៅក្នុងមតិយោបល់របស់សហគមន៍អឺរ៉ុប និងឧទាហរណ៍នៃនីតិប្បញ្ញត្តិរបស់ប្រទេស New Zealand ("ច្បាប់ឆ្នាំ ២០០៦") ដែលត្រូវបានបកស្រាយដោយអនុញ្ញាតឱ្យមានការប្រើប្រាស់ក្នុងការគាំទ្រដល់ភាគីការពារក្តីនូវការសារភាពក្រៅតុលាការរបស់សហជនជាប់ចោទ ទំនងជាពុំជាប់ពាក់ព័ន្ធ បើផ្អែកលើអង្គហេតុ ទៅនឹងចម្លើយដែលបានមកពីការធ្វើទារុណកម្មឡើយ។ ទាក់ទងនឹងប្រព័ន្ធច្បាប់ជាក់លាក់ដែលបានផ្អែកទៅលើជាឧទាហរណ៍: នៅចក្រភពអង់គ្លេស *សូមមើល រឿងក្តី A និងអ្នកដទៃ ទល់នឹង រដ្ឋលេខាធិការ (លេខ ២)* កថាខណ្ឌ ៩១ ដល់ ៩៧។ នៅប្រទេសអាល្លឺម៉ង់ មានតែផ្នែក ១៣៦ ក និង ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តលើការធ្វើទារុណកម្មនៅក្នុងបរិបទនៃការស៊ើបអង្កេតក្នុងរឿងក្តីចំពោះមុខ ប៉ុន្តែចំពោះភាពមិនអាចទទួលយកបានលើភស្តុតាងក្នុងកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ គឺអនុវត្តតាមនិយាមដទៃទៀត ដូចជាច្បាប់ជាមូលដ្ឋាន(ឧទាហរណ៍ តុលាការកំពូលសហព័ន្ធអាល្លឺម៉ង់ ព្រឹទ្ធសភាទីពីរ សេចក្តីសម្រេចចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៨៩ សំណុំរឿងលេខ 2 BvR 1062/87, ទាក់ទងនឹងការបដិសេធចោលនូវភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹង ផ្នែកសំខាន់នៃភាពជាឯកជនដែលត្រូវបានការពារ) និងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (*សូមមើល រឿងក្តី El Motassadeq*, កថាខណ្ឌ ៩ ជាដើម)។ ក្នុងប្រទេស Denmark មតិយោបល់ដូចគ្នារបស់សហគមន៍អឺរ៉ុបដែលលើកឡើងថា ភស្តុតាងដែលបានមកដោយពុំស្របនឹងច្បាប់លម្អៀងទៅរកជនជាប់ចោទ ត្រូវតែទទួលយក ដោយសារវិធានទូទៅមួយបានចែងថា "តុលាការកាន់តែទេរទៅរកការបដិសេធចោលនូវភស្តុតាងដែលបានមកដោយខុសច្បាប់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ" (មតិយោបល់របស់សហគមន៍អឺរ៉ុបទំព័រ ១២)។ ពុំមានច្បាប់យុត្តិសាស្ត្រណាមួយ ត្រូវបានដកស្រង់នៅក្នុងមតិយោបល់របស់សហគមន៍អឺរ៉ុបស្តីពីប្រទេស Denmark ដើម្បីបញ្ជាក់ថាតើ ភស្តុតាងខុសច្បាប់នេះបានមកយ៉ាងដូចម្តេច ឧទាហរណ៍ជាច្រើន ត្រូវបានដកស្រង់នៅក្នុងឯកសារនោះ ជាប់ពាក់ព័ន្ធទៅនឹងការរំលោភលើសិទ្ធិនៃជីវភាពឯកជន។ គណៈកម្មាធិការស្តីពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានរិះគន់ទៅលើការដាក់បញ្ចូលរបស់ Denmark នូវអនុសញ្ញាទៅក្នុងច្បាប់ជាតិដោយអនុលោមតាមប្រព័ន្ធទ្វិកនិយមរបស់ខ្លួន, "គណៈកម្មាធិការមានការសោកស្តាយដែលថា រដ្ឋភាគីពុំបានផ្លាស់ប្តូរជំហររបស់ខ្លួនទាក់ទងទៅនឹងការដាក់បញ្ចូលនូវអនុសញ្ញាទៅក្នុងច្បាប់របស់ Danish (សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការស្តីពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (Denmark), ឯកសារលេខ CAT/C/DNK/CO/5, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ៩)។ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ពុំបានធ្វើអធិប្បាយលើមាត្រា ១៥ និងការប្រើប្រាស់ភស្តុតាងដែលបានមកដោយខុសច្បាប់ នៅពេលដែលធ្វើការពិនិត្យលើរបាយការណ៍របស់ប្រទេសក្រិច ប៉ុន្តែគណៈកម្មាធិការមានការពេញចិត្តទៅនឹង"[ការអនុវត្តរបស់ប្រទេសក្រិចតាមអនុសញ្ញា] ហើយសមាជិករបស់ខ្លួនមួយចំនួនបានចាត់ទុកថាជា នីតិកម្មមួយក្នុងចំណោមនីតិកម្មដែល មានលក្ខណៈជឿនលឿនជាងគេបំផុតនៅក្នុងទ្វីបអឺរ៉ុប"(គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, របាយការណ៍ប្រចាំលើកទីពីររបស់រដ្ឋភាគីត្រូវដាក់ក្នុងឆ្នាំ ១៩៩៣ (ឯកសារបន្ថែមរបស់ក្រិច) លេខ CAT/C/20/Add.2, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣)។ រឿងក្តីរបស់កាណាដាដែលបានដកស្រង់ដោយជនជាប់ចោទ ពុំជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងដែលបានមកពីការធ្វើទារុណកម្មឡើយ។ នៅក្នុង*រឿងក្តីទីមួយ* *រឿងក្តី R ទល់នឹង Mills* [1999] សំណុំរឿងលេខ 3 SCR 668 (ប្រទេសកាណាដា) អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តតាមផ្នែក ២៧៨.១ ដល់ ២៧៨.៩១ ដែលមានលក្ខណៈធម្មនុញ្ញនៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កាណាដា ដែលថ្លឹងថ្លែងសិទ្ធិរបស់ជនជាប់ចោទក្នុងការការពារខ្លួនពេញលេញ រវាងសិទ្ធិនៃជីវភាពឯកជននៃកំណត់ហេតុរបស់ជនរងគ្រោះនៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងការរំលោភផ្លូវ

កត់សម្គាល់ថា គណៈកម្មាធិការអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានអំពាវនាវជាញឹកញាប់ដល់រដ្ឋភាគីនឹងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឱ្យតាក់តែងនីតិបញ្ញត្តិ ក្នុងស្រុករបស់ខ្លួនស្របជាមួយនឹងពាក្យពេចន៍ច្បាស់លាស់របស់មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[148]។ គណៈកម្មាធិការនេះ ក៏បានសម្តែងនូវក្តីបារម្ភអំពីការប្រើប្រាស់ភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅក្នុងយុត្តាធិការ

---

ភេទ។ រឿងក្តីទីពីរ *រឿងក្តី* Basaillon *ទល់នឹង* Keable, [1983] សំណុំរឿងលេខ 2 SCR 60 (ប្រទេសកាណាដា) បានថ្លឹងថ្លែងពីវិធានស្តីពីការសម្ងាត់ទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកយកការណ៍ជាប៉ូលីស រវាងករណីពិសេសតែមួយ ក្នុងការបង្ហាញពីភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទនៅក្នុងការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ។ អង្គជំនុំជម្រះតុលាការកំពូលរបស់ប្រទេសកាណាដា បានទទួលស្គាល់តាំងពីដំបូងនៅក្នុង *រឿងក្តី R ទល់នឹង* Seaboyer, [1991] សំណុំរឿងលេខ 2 S.C.R. 577, ទំព័រ ៦១១ នូវភាពខុសគ្នារវាងភស្តុតាងដែលត្រូវបានដកចេញ ហើយត្រូវបានបង្ហាញដោយអយ្យការ និងភស្តុតាងប្រហាក់ប្រហែលគ្នាដែលត្រូវបានបង្ហាញដោយជនជាប់ចោទ។ គោលការណ៍ណែនាំដ៏ប្រុងប្រយ័ត្នស្តីពីភាពអាចទទួលយកបាន នៃភស្តុតាងរបស់ជនជាប់ចោទដែល ត្រូវបានបដិសេធចោលដោយផ្អែកលើវិធានបដិសេធភស្តុតាងនោះ ផ្តល់ប្រយោជន៍ដល់ជនជាប់ចោទក្នុងការទទួលបានសិទ្ធិជំនុំជម្រះត្រឹមត្រូវស្តីពីការសន្មតទុកជាមុនថាគ្មានទោស។ "ការប៉ះពាល់ដល់សិទ្ធិ គឺត្រូវតែសំខាន់យ៉ាងខ្លាំងជាងតម្លៃនៃភស្តុតាង" មុនពេលបដិសេធជនជាប់ចោទមិនឱ្យលើកភស្តុតាង។

[148] *ជាឧទាហរណ៍* "គណៈកម្មាធិការ បានផ្តល់អនុសាសន៍ថាប្រទេស [Finland] គួរអនុម័តនីតិបញ្ញត្តិដែលហាមឃាត់យ៉ាងពិសេសនូវការប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្មមកធ្វើជាភស្តុតាង និងធាតុផ្សំនៃភស្តុតាង ឱ្យស្របតាមមាត្រា ១៥ នៃអនុសញ្ញា" (គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, សេចក្តីសន្និដ្ឋានលើការសង្កេតរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម (Finland), ឯកសារលេខ CAT/C/FIN/CO/5-6 ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ២១)។ "ប្រទេស Israel គប្បីបង្កើតច្បាប់ហាមឃាត់ថា ចម្លើយណាមួយដែលបង្ហាញថាបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ពុំអាចត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនរងគ្រោះឡើយ ដោយស្របតាមមាត្រា ១៥ នោះ" (សេចក្តីសន្និដ្ឋានលើការសង្កេតរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម (Israel), ឯកសារលេខ CAT/C/ISR/CO/4 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥)។ "[Morocco គប្បី]ដាក់បញ្ចូលបទប្បញ្ញត្តិហាមឃាត់ចម្លើយដែលបានមកពីការធ្វើទារុណកម្ម មិនឱ្យប្រើប្រាស់ជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ ស្របតាមមាត្រា ១៥ នៃអនុសញ្ញា" (សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ចំពោះប្រទេស Morocco, ឯកសារលេខ CAT/C/CR/31/2 ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ៦(ជ))។ "ច្បាប់របស់[ចក្រភពអង់គ្លេស] ត្រូវបានបកស្រាយឱ្យដកចេញនូវការប្រើប្រាស់ភស្តុតាងដែលបានមកពីទារុណកម្ម តែពេលណាដែលមន្ត្រីរបស់រដ្ឋភាគី ជាអ្នករួមគំនិត" នៅក្នុងការរំលោភបំពានលើអត្ថន័យយ៉ាងច្បាស់លាស់នៃមាត្រា ១៥។ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ចំពោះប្រទេសអង់គ្លេស និង Northern Ireland, ឯកសារលេខ CAT/C/CR/33/3 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤)។ "[Sweden ត្រូវ]ធានាថា ការហាមឃាត់ការប្រើប្រាស់ចម្លើយបានមកពីការធ្វើទារុណកម្មធ្វើជាភស្តុតាងក្នុងកិច្ចដំណើរការនីតិវិធី គឺត្រូវបានបង្កើតឡើងយ៉ាងជាក់ច្បាស់ក្នុងច្បាប់ជាតិ" (សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម(ប្រទេស Sweden), ឯកសារលេខ CAT/C/CR/28/6 ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៧(ជ))។

ដែលមានវិធានបដិសេធភស្តុតាងយ៉ាងទូលំទូលាយដែលស្របគ្នាទាំងស្រុងទៅនឹងមាត្រា ១៥ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ផងនោះ[149]។ ទោះជាយ៉ាងក្តី អំណះអំណាងរបស់ នួន ជា ដែលលើកឡើងថា ការអនុវត្តរបស់រដ្ឋ គឺបានបង្ហាញពីការបកស្រាយដោយឯកភាពគ្នាមួយស្របតាមខ្លឹមសារនៃមាត្រា ៣១ របស់អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា ក្នុងការរឹតត្បិតមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ទៅលើតែភស្តុតាងដែលត្រូវបានបង្ហាញដើម្បីគាំទ្រអយ្យការនោះ ពុំមានអង្គសេចក្តីគ្រប់គ្រាន់ឡើយ។

62. បញ្ហាពិតប្រាកដនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គ្របដណ្តប់ការប្រើប្រាស់ព័ត៌មាន ដែលបានមកពីការធ្វើទារុណកម្មសម្រាប់គោលបំណងការការពារខ្លួនបាន ដែរ ឬយ៉ាងណា ឧទាហរណ៍ នៅពេលដែល សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង និងហានិភ័យនៃការដាក់ពិរុទ្ធភាព ដែលផ្អែកលើភស្តុតាងដែលពុំអាចជឿទុកចិត្តបាន គឺពុំចោទជាបញ្ហានោះ។ លើសពីនេះទៀត បើទោះបីជាការប្រើប្រាស់នេះ ស្ថិតក្នុងវិសាលភាពនៃវិធានបដិសេធភស្តុតាងក៏ដោយ

---

[149] ឧទាហរណ៍ មាត្រា ២១ នៃរដ្ឋធម្មនុញ្ញរុស្ស៊ី បានចែងអំពីការហាមឃាត់យ៉ាងទំលំទូលាយដែលពុំអាចធ្វើបដិប្បញ្ញត្តិបានប្រឆាំងនឹងការធ្វើទារុណកម្ម និងមាត្រា ៥០(២) បានហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលរំលោភបំពានលើច្បាប់សហព័ន្ធ ចំណែកឯយោងតាមមាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ភស្តុតាងដែលបានមកដោយសាររំលោភបំពានលើក្រមនេះ គឺពុំអាចទទួលយកបាន ពុំមានអានុភាពផ្លូវច្បាប់ និងពុំអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃដីកាចោទប្រកាន់ ឬដើម្បីគាំទ្រអង្គហេតុសត្យានុម័តនៃរឿងក្តីមួយ។ ទោះជាយ៉ាងណាក៏ដោយ "គណៈកម្មាធិការ ព្រួយបារម្ភអំពីការចោទប្រកាន់យ៉ាងច្រើនដែលថា បុគ្គលដែលត្រូវបានដកសិទ្ធិសេរីភាព ទទួលរងការធ្វើទារុណកម្ម ឬការធ្វើបាបសម្រាប់គោលបំណងបង្ខិតបង្ខំឱ្យសារភាព និងថា ការសារភាពនេះ ក្រោយមក ត្រូវបានទទួលយកជាភស្តុតាង នៅក្នុងតុលាការ ដោយពុំមានការស៊ើបអង្កេតឱ្យបានហ្មត់ចត់លើការចោទប្រកាន់នៃការធ្វើទារុណកម្មឡើយ", (ការសង្កេតសរុបលើរបាយការណ៍ដែលចេញជាប្រចាំលើកទី ៥ នៃសហព័ន្ធរុស្ស៊ី ឯកសារលេខ CAT/C/RUS/CO/5, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១០)។ នៅប្រទេសប៉ូឡូញ អនុលោមតាមមាត្រ ១៧១ ក្រមនីតិវិធីហ្មទណ្ឌបានហាមឃាត់មិនឱ្យប្រើឥទ្ធិពលដើម្បីទទួលបានចម្លើយពីបុគ្គលដែលត្រូវបានសាកសួរដោយការបង្ខិតបង្ខំ ឬការគំរាមកំហែងខុសច្បាប់ ឬ"តាមរបៀបបច្ចេកទេស ឬគីមី ឬថ្នាំសណ្តំ ដែលប៉ះពាល់ដំណើរការផ្នែកស្មារតីរបស់បុគ្គលដែលត្រូវបានសាកសួរ ឬក្នុងគោលបំណងឱ្យមានឥទ្ធិពលលើប្រតិកម្មដោយឥតដឹងខ្លួននៃសព៌ាង្គកាយពាក់ព័ន្ធទៅនឹងការសាកសួរនោះ" (ក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៧ វិសោធនកម្ម នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ មាត្រា ១៧១(៤)(២)) និងការពន្យល់ សក្សីកម្ម និងសេចក្តីប្រកាស ដែលពុំទទួលបានក្រោមលក្ខខណ្ឌដោយសេរី ពុំត្រូវចាត់ទុកជាភស្តុតាង (មាត្រា ១៧១ (៦))។ ទាក់ទងបញ្ហានេះ គណៈកម្មាធិការនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានលើកឡើងថា ខ្លួនមានការសោកស្តាយដែលថា បើទោះបីជាមានអនុសាសន៍របស់ខ្លួនពីមុនក្តី [...] រដ្ឋភាគីនៅតែពុំដាក់បញ្ចូលបទប្បញ្ញត្តិនៃអនុសញ្ញានេះ [...] ទៅក្នុងច្បាប់ជាតិឡើយ"( គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, ការសង្កេតសរុបលើរបស់ប្រចាំលើកទី ៥ និង ៦ ដែលរួមគ្នា របស់ប្រទេសប៉ូឡូញ ឯកសារលេខ CAT/C/POL/CO/5-6 ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ៧)។

ក៏សំណួរសួរថាតើ មូលហេតុដែលជាមូលដ្ឋានសម្រាប់ការហាមឃាត់ អាចត្រូវបានធ្វើឱ្យមានតុល្យភាព ចំពោះសិទ្ធិក្នុងការបង្ហាញភស្តុតាងដើម្បីការពារខ្លួនទៅតាមករណីនីមួយៗ ដែរ ឬយ៉ាងណា។

63. ពាក់ព័ន្ធនឹងបញ្ហានេះ ជាការចាំបាច់ត្រូវពិចារណាថា ខុសគ្នាពីសិទ្ធិទទួលបានការជំនុំជម្រះប្រកប ដោយយុត្តិធម៌ទាំងមូល និងសិទ្ធិទទួលបានការជំនុំជម្រះតុលាការឯករាជ្យ និងឥតលម្អៀង សិទ្ធិក្នុងការ បង្ហាញភស្តុតាង ដែលជាសមាសភាគមួយនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នេះ ពុំមាន លក្ខណៈដាច់ខាតនោះឡើយ។ ដោយហេតុថា ជនជាប់ចោទ ត្រូវបានការពារជាចម្បងដោយគោលការណ៍ នៃការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ និងសិទ្ធិសួរបញ្ជាក់ភស្តុតាង ប្រឆាំងនឹងខ្លួន សិទ្ធិក្នុងការបង្ហាញភស្តុតាង អាចដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌ ដែលមានគោលបំណងលើក កម្ពស់តម្លៃ និងផលប្រយោជន៍ផ្សេងៗ ដូចជា ការពន្លឿន និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ គួរ រំលឹកថា វិធាននៃភស្តុតាង និងវិធានបដិសេធភស្តុតាង មិនត្រឹមតែត្រូវបានបង្កើតឡើងឱ្យស្របតាមបទដ្ឋាន ស្តីពីសិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងស្របតាមកម្រិតក្នុងស្រុកផងដែរ។ ជាការកត់សម្គាល់ វិធានបដិសេធភស្តុតាងដែលមាននៅកម្រិតក្នុងស្រុក មិនត្រឹមតែមានគោលបំណងការពារជនជាប់ចោទពី ផលប៉ះពាល់ប៉ុណ្ណោះទេ ថែមទាំង ដោយធ្វើការលុបបំបាត់មធ្យោបាយមួយចំនួនក្នុងការបង្ហាញភាស្តុតាង ឬអង្គហេតុមួយចំនួន ក្នុងចំណោមនោះ ការពារភាពអាចជឿទុកចិត្តបាននៃភស្តុតាង[150] ភាពសម្ងាត់

[150] ឧទាហរណ៍សម្រាប់ករណីនេះ គឺជាការហាមឃាត់នូវភស្តុតាងដែលឮតៗគ្នា ដែលមាននៅក្នុងយុត្តិសាស្ត្រមួយចំនួន។ *សូមមើល* វិធាន ៨០២ នៃវិធានសហព័ន្ធស្តីពីភស្តុតាងរបស់សហរដ្ឋអាមេរិកដែលចែងថា "ការឮតៗគ្នា គឺពុំអាចទទួលយកបាន លើកលែងតែបទប្បញ្ញត្តិខាងក្រោមចែងផ្ទុយពីនេះ៖ លក្ខន្តិកៈសហព័ន្ធ, វិធានទាំងនេះ, ឬវិធានដទៃទៀត ដែលបានកំណត់ដោយតុលាការកំពូល" (Fed. R. Evid. 403)។ ផ្នែក ១១៤(១) នៃច្បាប់ស្តីពីយុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ ២០០៣ (ជំពូក ៤៤) នៅក្នុងចក្រភពអង់គ្លេសចែងថា "នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ចម្លើយដែលពុំមែនជាភស្តុតាងផ្ទាល់មាត់ នៅក្នុងកិច្ចដំណើរការនីតិវិធី គឺអាចទទួលយកបានជាភស្តុតាងនូវបញ្ហាណាមួយដែលលើកឡើងថា ក្នុងករណី ប៉ុន្តែប្រសិនបើ—ក) បទប្បញ្ញត្តិណាមួយនៃជំពូកនេះ ឬបទប្បញ្ញត្តិជាលក្ខន្តិកៈណាមួយដទៃទៀត ទទួលយកចម្លើយនេះ ជាភស្តុតាង [...] ឃ) តុលាការត្រូវជឿជាក់ថា ការព្រមទទួលយកបែបនេះ គឺដើម្បីប្រយោជន៍យុត្តិធម៌" តែប៉ុណ្ណោះ។ នៅក្នុងហុងកុង វិធានស្តីពីការឮតៗគ្នា ត្រូវបានទាញយកមកពីច្បាប់អង់គ្លូសាក់សុងរបស់អង់គ្លេស និងត្រូវបានបញ្ជាក់អះអាងឡើងវិញនៅក្នុង*រឿងក្តី Wong Wai-man អ្នកដទៃទៀត ទល់នឹង HKSAR,* (ឆ្នាំ ២000) សំណុំរឿងលេខ 3 HKCFAR 322, កថាខណ្ឌ ៣២៧ (*របាយការណ៍: ការឮតៗគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ,* គណៈកម្មការកែទម្រង់ច្បាប់របស់ហុងកុង (ខែ វិច្ឆិកា ឆ្នាំ ២០០៩) កថាខណ្ឌ ១.៩, ៣.៣)។ ពុំមានបទប្បញ្ញត្តិជាលក្ខន្តិកៈដែលបានបដិសេធភស្តុតាងឮតៗគ្នានៅក្នុងប្រទេសកាណាដាឡើយ ប៉ុន្តែ វិធានបដិសេធភស្តុតាង ត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងច្បាប់យុត្តិសាស្ត្រ"ករណីពិសេសចំពោះវិធានបដិសេធភស្តុតាង ត្រូវបានស្ថាបនាយ៉ាងទូលំទូលាយជុំវិញកាលៈទេសៈទាំងនោះនៅពេលដែលគ្រោះថ្នាក់ក្នុងការទទួលយកភស្តុតាង ពុំមានលក្ខណៈធ្ងន់ធ្ងរឡើយ" *រឿងក្តី R. ទល់នឹង Khelawon*, សំណុំរឿងលេខ 2006 SCC 57, កថាខណ្ឌ ៣។ មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

01185995



នៃការពិភាក្សាសម្រេចរបស់តុលាការ[151] សិទ្ធិរបស់តតីយជនប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង[152] ទំនាក់ទំនងគ្រួសារ[153] សិទ្ធិនៃជីវភាពឯកជន[154] ការសម្ងាត់របស់រដ្ឋ[155] និងក្រមសីលធម៌វិជ្ជាជីវៈ[156]។

---

រុស្ស៊ី បានហាមឃាត់ការទទួលយក"ភស្តុតាងរបស់ជនរងគ្រោះ និងសាក្សីដែលបានផ្អែកលើការស្មាន ការឧបមា ឬការឮតៗគ្នា រួមទាំងសក្ខីកម្មរបស់សក្សី ដែលពុំបានបញ្ជាក់ពីប្រភពក្នុងការដឹងឮ" (ក្រមនីតិវិធីព្រហ្មទណ្ឌរបស់សហព័ន្ធរុស្ស៊ី លេខ 174-FZ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០១ វិសោធនកម្ម នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ មាត្រា ៧៥ (២)(២))។ *សូមមើលផងដែរ ខាងលើ* មាត្រា ១៩៣ ការបង្ហាញពីភាពមិនអចាទទួលយកបាននៃ"ការកំណត់អត្តសញ្ញាណច្រំដែរទៅលើបុគ្គល ឬវត្ថុដោយសារបុគ្គលនោះមានអត្តសញ្ញាណដូចគ្នា និងដោយសារមានលក្ខណៈពិសេសដូចគ្នា"។

[151] យោងតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុង គោលការណ៍ទូទៅចែងថា អ្វីៗដែលបានលើកឡើងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ទទួលបានឯកសិទ្ធិពិសេស (គណៈកម្មការកែទម្រង់ច្បាប់ Irish, ច្បាប់ស៊ីវិលស្តីពីការបរិហារកេរ្តិ៍, ឯកសារពិគ្រោះពិភាក្សាស្តីពី (LRC CP 3-1991) [1991] IELRC 2 (ខែ មីនា ឆ្នាំ ១៩៩១) ទំព័រ ៧៧)។ នៅសហរដ្ឋអាមេរិក ទម្លាប់ និងលទ្ធិនៃការបែងចែកអំណាច បានគាំទ្រនូវភាពមានធម្មានុរូបនៃបុព្វសិទ្ធិរបស់តុលាការ។ មូលដ្ឋានជាប្រវត្តិសាស្ត្រសម្រាប់បុព្វសិទ្ធិតុលាការ កើតចេញពីតម្រូវការចាំបាច់ក្នុងការរក្សាការសម្ងាត់នូវដំណើរការក្នុងការធ្វើសេចក្តីសម្រេចរបស់តុលាការ។ *សូមមើល រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Morgan*, សំណុំរឿងលេខ 313 U.S. 409 (ឆ្នាំ ១៩៤១), កថាខណ្ឌ ៤២២ (ដំណើរការផ្នែកបញ្ញាស្មារតីរបស់ចៅក្រម ពុំតម្រូវឱ្យធ្វើការពិនិត្យពិច័យឡើយ "ការពិនិត្យលើចៅក្រម នឹងអាចជាការអន្តរាយដល់ការទទួលខុសត្រូវផ្នែកតុលាការ")។ *រឿងក្តី Soucie ទល់នឹង David*, សំណុំរឿងលេខ 448 F.2d 1067, (D.C. Cir. 1971), ទំព័រ ១០៨០ ដល់ ១០៨១។ *សូមមើលផងដែរ រឿងក្តី Nixon ទល់នឹង Sirica*, សំណុំរឿងលេខ 487 F.2d 700, (D.C.Cir.1973) (ចៅក្រម MacKinnon, មតិស្រប) កថាខណ្ឌ ៧៤៩ ដល់ ៧៥២ (ប្រភពនៃឯកសិទ្ធិតុលាការ"ចាក់ឫសគល់នៅក្នុងប្រវត្តិសាស្ត្រ និង ទទួលបានកម្លាំងបន្ថែមពីការបែងចែកតាមរដ្ឋធម្មនុញ្ញនូវអំណាច")។ *រឿងក្តី Grant ទល់នឹង Shalala*, សំណុំរឿងលេខ 989 F.2d 1332 (3d Cir.1993), ទំព័រ ១៣៤៤ ("មានការទទួលស្គាល់ជាយូរយារមកហើយ ថា ការប៉ុនប៉ងស្វែងរកគំនិត និងដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់ចៅក្រម និងអ្នកគ្រប់គ្រងរដ្ឋបាល ជាទូទៅពុំមានលក្ខណៈសមស្របឡើយ")។ *សូមមើលផងដែរ Canada (Privacy Commissioner) v. Canada (Labour Relatinos Board ) ប្រទេសកាណាដា (គណៈកម្មការនៃកិច្ចការសម្ងាត់) ទល់នឹង ប្រទេសកាណាដា (ក្រុមប្រឹក្សាទំនាក់ទំនងការងារ)* (T.D.) [ឆ្នាំ ១៩៩៦] 3 F.C. 609, ទំព័រ ៦១២ (សេរីភាពពេញលេញរបស់ចៅក្រមនីមួយៗក្នុងការសម្រេចរឿងក្តីដែលនៅចំពោះមុខខ្លួន គឺជាចំណុចសំខាន់នៃគោលការណ៍ស្តីពីឯករាជភាពរបស់តុលាការ។ សេរីភាពពេញលេញក្នុងការសម្រេច អាចកើតមានតែក្នុងករណីដែលចៅក្រមមានសេរីភាពទាំងស្រុងផុតពីការជ្រៀតជ្រែកជាក់ស្តែង ឬដោយប៉ុនបង់ពី"អ្នកខាងក្រៅ"ណាម្នាក់ទៅលើកិច្ចការរបស់ចៅក្រម ក្នុងការធ្វើចំណាត់ការទៅលើសំណុំរឿង និងការធ្វើសេចក្តីសម្រេចរបស់គាត់)។ ក្នុងប្រទេសបារាំង ចៅក្រម ត្រូវធ្វើសម្បថដើម្បីបំពេញកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់នៃការពិភាក្សាសម្រេច នៅក្នុងចំណោមកាតព្វកិច្ចដទៃទៀត (Article 6 de l'ordonnance n°58.1270 of 22 December 1958 contains the oath formula : « *je jure de bien fidèlement remplir mes fonctions, de garder religieusement le secret des délibérations et de me conduire en tout comme un digne et loyal magistrat* »)។ នៅក្នុងប្រទេសរុស្ស៊ី មាត្រា ៥៦(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌ(ជើងទំពារ ១៥២ ខាងលើ) បានលើកលែងការផ្តល់សក្ខីកម្មរបស់ចៅក្រម និងគណៈវិនិច្ឆ័យ"អំពីកាលៈទេសៈនៃរឿងក្តី ដែលពួកគាត់បានដឹងតាមរយៈចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីលើរឿងក្តីព្រហ្មទណ្ឌណាមួយ"។ នៅតុលាការ ICTY អង្គជំនុំជម្រះឧទ្ធរណ៍បានអះអាងនៅក្នុង *រឿងក្តី Delalic និងអ្នកដទៃទៀត.*, អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៩

---

កថាខណ្ឌ ៥: "ការពិភាក្សាសម្រេច និងការសង្កេតរបស់តុលាការទាក់ទងទៅនឹងបញ្ហាដែលចៅក្រមតម្រូវឱ្យវិនិច្ឆ័យ ពុំគប្បីជាកម្មវត្ថុនៃភស្តុតាងដែលគួរឱ្យជឿបាននៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬការបង្ហាញនៅក្នុងកាលៈទេសៈណាផ្សេងក្រៅតែពីក្នុងផ្នែកសមស្របនៃសំអាងហេតុ សម្រាប់សេចក្ដីសម្រេចនៅក្នុងបញ្ហាជាក់លាក់ណាមួយប៉ុណ្ណោះ"។

[152] សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធលើខ្លួន គឺជាគោលការណ៍យូរយារមកហើយនៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងត្រូវបានទទួលស្គាល់នៅក្នុងផ្នែកទី ៣ នៃច្បាប់ស្ដីពីភស្តុតាងរបស់ចក្រភពអង់គ្លេសឆ្នាំ ១៨៥១ c. 99, "គ្មានអ្វី [...] អាចនឹងបង្ខំបុគ្គលណាមួយឱ្យឆ្លើយទៅនឹងសំណួរដែលជាការដាក់ពិរុទ្ធលើខ្លួនឯងនោះឡើយ"។ *សូមមើលរឿងក្ដី* Blunt *ទល់នឹង* Park Lane *Hotel,* [ឆ្នាំ ១៩៤២] សំណុំរឿងលេខ 2KB 253, ទំព័រ ២៥៧ ដែលការអះអាងរបស់ដើមចោទដែលថា ការស៊ើបអង្កេត"នឹងអាចធ្វើឱ្យគាត់ទទួលរងហានិភ័យនៃការដាក់ទណ្ឌកម្មខាងសាសនា"ដោយសារអំពើសហាយស្មន់ ត្រូវបានបដិសេធចោល និងថា "វិធាន [...] ថា ពុំមានបុគ្គលណាម្នាក់ ចងកាតព្វកិច្ចត្រូវតែឆ្លើយសំណួរណាមួយ ប្រសិនបើចម្លើយនោះ តាមការយល់ឃើញរបស់ចៅក្រម នឹងអាចធ្វើឱ្យអ្នកឆ្លើយទទួលរងបទចោទ, ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌណាមួយ [...]" ត្រូវបានអនុវត្តតាម។ ផ្នែក ១៣ នៃធម្មនុញ្ញរបស់កាណាដាស្ដីពីសិទ្ធិ និងសេរីភាព ចែងអំពីការការពារជាលក្ខណៈធម្មនុញ្ញប្រឆាំងនឹងសក្ខីកម្មរបស់សាក្សីដែលឆ្លើយដាក់ពិរុទ្ធលើខ្លួនឯង "សាក្សីដែលផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ មានសិទ្ធិពុំផ្ដល់ភស្តុតាងដាក់បន្ទុកលើខ្លួនណាមួយ ដែលត្រូវប្រើប្រាស់ ដើម្បីដាក់ពិរុទ្ធលើខ្លួនឯង នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ [...]" (ច្បាប់ជាធម្មនុញ្ញ ឆ្នាំ ១៩៨២, កម្មវិធី ខ ទៅកាន់ច្បាប់របស់កាណាដា ឆ្នាំ ១៩៨២ (ចក្រភពអង់គ្លេស), ឆ្នាំ ១៩៨២, c 11)។ នៅក្នុងប្រព័ន្ធរបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស បើទោះបីជាពុំមានការបញ្ជាក់ច្បាស់លាស់នៅក្នុងច្បាប់ជាតិក៏ដោយ បុព្វសិទ្ធិប្រឆាំងនឹងការមិនឆ្លើយដាក់ពិរុទ្ធលើខ្លួនឯង ត្រូវបានអះអាងបញ្ជាក់ដោយតុលាការអឺរ៉ុប, *សូមមើលរឿងក្ដី Serves ប្រឆាំងនឹង ប្រទេសបារាំង* តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECtHR) "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើលេខ 20225/92 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៤៧ ដែលតុលាការអះអាងពាក់ព័ន្ធទៅនឹងបុគ្គលដែលត្រូវបានកោះហៅមកធ្វើជាសាក្សីថា "អាចយល់បានថាម្ចាស់សំណើគប្បីបារម្ភថា ភស្តុតាងមួយចំនួនដែលខ្លួនអាចត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មនៅចំពោះមុខចៅក្រមស៊ើបអង្កេតអាចនឹងជាការដាក់បន្ទុកលើខ្លួនឯង។ ដូច្នេះ គាត់អាចនឹងបដិសេធមិនឆ្លើយសំណួរណាមួយរបស់ចៅក្រមដែលទំនងជារុញច្រានគាត់ចូលក្នុងទិសដៅនោះ"។ *រឿងក្ដី* K. *ទល់នឹង Austria*, តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស "សាលក្រមអង្គជំនុំជម្រះ (បានបដិសេធបញ្ជីឯកសារចោល )" សំណើលេខ 16002/90 ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៣ ដែលញ៉ាំងឱ្យមានការកែទម្រង់លើនីតិវិធីព្រហ្មទណ្ឌរបស់ Austrian ឱ្យមានអានុភាពថា "សាក្សីដែលផ្អែកលើដំណើររឿងនៃអង្គហេតុដូចគ្នាជាច្រើន កំពុងមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន និងអាចឆ្លើយដាក់បន្ទុកលើខ្លួនតាមរយៈចម្លើយផ្ទាល់ដែលបានផ្ដល់ក្នុងនាមជាសាក្សី ដូច្នេះ នឹងត្រូវមានសិទ្ធិដោយឥតលក្ខខណ្ឌក្នុងការបដិសេធមិនផ្ដល់ភស្តុតាង។ បញ្ញត្តិនេះធានាថា លែងឱ្យមានការបំពានលើអនុសញ្ញាប្រភេទនេះតទៅទៀតឡើយ" (កថាខណ្ឌ ១៤)។ *សូមមើលផងដែរ*: ធម្មនុញ្ញភាពស្ដីពីសិទ្ធិជាសារវ័ន្ត និងសេរីភាពរបស់សាធារណៈរដ្ឋ Czech ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩២ មាត្រា ៣៧(១) "អ្នករាល់គ្នា មានសិទ្ធិបដិសេធមិនផ្ដល់សក្ខីកម្ម ប្រសិនបើខ្លួនអាចនឹងឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬបុគ្គលណាមួយដែលជិតស្និទ្ធនឹងខ្លួន" (កម្រង់ច្បាប់ជាធម្មនុញ្ញលេខ ២/១៩៩៣ ត្រូវបានវិសោធនកម្មដោយកម្រង់ច្បាប់ធម្មនុញ្ញលេខ ១៦២/ ឆ្នាំ ១៩៩៨)។

[153] នៅចក្រភពអង់គ្លេស "គ្មានអ្វី [...] អាចបង្ខំ ឬតម្រូវឱ្យប្ដីនៅក្នុងកិច្ចដំណើរការនីតិវិធីផ្ដល់ភស្តុតាងគាំទ្រ ឬប្រឆាំងនឹងប្រពន្ធឡើយ ឬអាចបង្ខំ ឬតម្រូវឱ្យប្រពន្ធផ្ដល់ភស្តុតាងគាំទ្រ ឬប្រឆាំងនឹងប្ដីរបស់ខ្លួនឡើយ" (ផ្នែកទី ៣ នៃច្បាប់ស្ដីពីភស្តុតាងឆ្នាំ ១៨៥១ c. 99)។ នៅប្រទេសកាណាដា ឯកសិទ្ធិរបស់ប្ដីប្រពន្ធ ត្រូវបានបញ្ញត្តិក្នុងមាត្រា ៤(៣) នៃច្បាប់ស្ដីពីភស្តុតាងរបស់

កាណាដា RSC 1985, c. C-5, ដែលត្រូវបានអះអាងបញ្ជាក់នៅក្នុង *រឿងក្តី R. ទល់នឹង Zylstra*, (ឆ្នាំ ១៩៩៥) 99 CCC (3d) (ONCA Canada)។ បទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះ មាននៅក្នុងការប្រមូលផ្តុំចងក្រងជាក្រមរបស់អឺរ៉ុបភាគច្រើន, *សូមមើល* មាត្រា ៤១៦.១ នៃក្រមនីតិវិធីព្រហ្មទណ្ឌអេស្ប៉ាញឆ្នាំ ១៨៨២ (Ley de Enjuiciamiento Criminal) លើកលែងប្តី ឬប្រពន្ធ និងសាច់ញាតិឱ្យរួចផុតកាតព្វកិច្ចក្នុងការផ្តល់សក្ខីកម្មជាសាក្សី (Núm. 260, de 17 de septiembre de 1882, ត្រូវបានវិសោធនកម្មចុងក្រោយ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥)។ មាត្រា ៥៦(៤) នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់រុស្ស៊ី (ជើងទំព័រ ១៥២ ខាងលើ)។

[154] នៅក្នុងសហរដ្ឋអាមេរិក *លក្ខន្តិកៈសហព័ន្ធគ្រប់គ្រងប្រព័ន្ធទំនាក់ទំនងឯកជន* បានហាមឃាត់នូវការលួចស្តាប់ និងការប្រើប្រាស់ការទំនាក់ទំនងដែលត្រូវបានលួចស្តាប់ដោយខុសច្បាប់(18 U.S.C. §§2510 ជាដើម)។ "នៅពេលណាដែល ការទំនាក់ទំនងផ្ទាល់មាត់ ឬតាមខ្សែលួស ត្រូវបានលួចស្តាប់ ខ្លឹមសារនៃការទំនាក់ទំនងនេះទាំងអស់ និងភស្តុតាងដែលបានទទួលពីនេះ ពុំអាចត្រូវបានទទួលយកជាភស្តុតាងនៅក្នុងការជំនុំជម្រះ, សវនាការ ឬកិច្ចដំណើរការនីតិវិធីដទៃទៀងនៅក្នុង ឬចំពោះមុខតុលាការ, គណៈវិនិច្ឆ័យ, នាយកដ្ឋាន, មន្ត្រី, ភ្នាក់ងារ, ស្ថាប័នចេញបទបញ្ជា, គណៈកម្មាធិការបទប្បញ្ញត្តិ ឬរដ្ឋអំណាចណាមួយនៃសហរដ្ឋអាមេរិក, រដ្ឋ ឬតំបន់នៃនយោបាយឡើយ ប្រសិនបើការបង្ហាញព័ត៌មាននេះ គឺជាការរំលោភបំពានលើជំពូកនេះ" (18 U.S.C. §2515)។ *សូមមើល រឿងក្តី Gelbard ទល់នឹង សហរដ្ឋអាមេរិក* 408 U.S. 41, 51-52 (ឆ្នាំ ១៩៧២) [សាក្សីពុំអាចត្រូវបានបង្ខំឱ្យបង្ហាញសក្ខីកម្មចេញពីការលួចស្តាប់តាមប្រព័ន្ធទំនាក់ទំនងដោយខុសច្បាប់ដល់គណៈវិនិច្ឆ័យឡើយ] *និង រឿងក្តី Lee ទល់នឹង Florida* 392 U.S. 378 (ឆ្នាំ ១៩៦៨) ដែលអង្គជំនុំជម្រះតុលាការកំពូល បានពង្វាតការបកស្រាយរបស់ខ្លួនលើផ្នែក ៦០៥ នៃច្បាប់ស្តីពីការទំនាក់ទំនងនៃរដ្ឋសហព័ន្ធ ដោយពុំបានទទួលយកការសន្ទនាដែលត្រូវបានលួចស្តាប់ និងបង្ហាញព័ត៌ជាសាធារណៈដែលរំលោភលើច្បាប់ មកធ្វើជាភស្តុតាងក្នុងតុលាការរបស់រដ្ឋឡើយ។ *សូមមើលផងដែររឿងក្តី R ទល់នឹង Tse* 2012 SCC 16 ដែលតុលាការកំពូលរបស់ប្រទេសកាណាដា ចាត់ទុកការទំនាក់ទំនងតាមប្រព័ន្ធដែលពុំអាចធានាបាននៅក្នុងស្ថានភាពបន្ទាន់ ថាពុំស្របតាមរដ្ឋធម្មនុញ្ញ ដោយសារកង្វះនូវវិធានការនៃការពិនិត្យ និងការទទួលខុសត្រូវ។ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់អាល្លឺម៉ង់ ហាមឃាត់យ៉ាងពិសេសនូវការប្រើប្រាស់ព័ត៌មានពាក់ព័ន្ធទៅនឹងចំណុចសំខាន់នៃជីវិតឯកជន។ ផ្នែក 100c(5) (5) "ការលួចស្តាប់ និងការថតសំឡេង ត្រូវតែបញ្ឈប់ភ្លាមៗ ប្រសិនបើ ក្នុងអំឡុងពេលនៃការលួចស្តាប់ បង្ហាញថា ចម្លើយពាក់ព័ន្ធទៅនឹងចំណុចសំខាន់នៃជីវិតឯកជន កំពុងកើតមាន។ ការថតសំឡេងនៃចម្លើយនេះ ត្រូវតែលុបចោលភ្លាម។ ព័ត៌មានដែលបានទទួលតាមវិធីសាស្ត្រនេះ ពុំអាចត្រូវបានប្រើប្រាស់ឡើយ" (ក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨។ វិសោធនកម្មដោយមាត្រា ៣ នៃច្បាប់ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤)។ ទាក់ទងទៅនឹងការដកចេញនេះ ដែលបានផ្អែកលើលក្ខណៈពិតនៃអង្គហេតុ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍* និងនៅ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) អំពើទាក់ទងនឹងកេរ្តិ៍កេទពីមុនពេល ឬក្រោយកមទៀតរបស់ជនរងគ្រោះ ពុំអាចត្រូវបានទទួលយកជាភស្តុតាងឡើយ បើទោះជាមានតម្លៃជាភស្តុតាងយ៉ាងណាក៏ដោយ (វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR, វិធាន ៩៦(៤); តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC), វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ, ICC-ASP/1/3 (Part.II-A), វិសោធនកម្មនៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០២ វិធាន ៧១)។

[155] យោងតាមតុលាការកំពូលរបស់ប្រទេសអ៊ីតាលី សាលដីកាលេខ 40 ឆ្នាំ ២០១២ កថាខណ្ឌ ៥ និង ៦.៤ (considerando in diritto) សិទ្ធិក្នុងការបង្ហាញភស្តុកាងដើម្បីការពារខ្លួន គឺពុំសូវសំខាន់ដូច"ផលប្រយោជន៍ដ៏ចាំបាច់ដែលខានពុំបាន"ក្នុងការការពារសន្តិសុខជាតិ ដែលសំខាន់ជាងអ្វីៗទាំងអស់។ ហេតុនេះ ព័ត៌មាន ឬឯកសារ ប្រសិនត្រូវចាត់ថ្នាក់ថាជា"ការសម្ងាត់របស់

ដោយផ្អែកលើគោលបំណងនៃវិធានបដិសេធភស្តុតាងដែលចោទជាបញ្ហា ក្នុងករណីបើអាចមាន សិទ្ធិបដិសេធការហាមឃាត់ អាចជាកម្មសិទ្ធិរបស់ជនជាប់ចោទ ឬជនដទៃដែលត្រូវបានការពារដោយវិធាន ឬអាចត្រូវបានបាត់បង់ទៅវិញដោយសារសេចក្តីសម្រេចផ្នែករដ្ឋបាល ឬតុលាការ។ នៅគ្រប់កាលៈទេសៈទាំងអស់ ពុំមានការគាំទ្រនៅក្នុងលទ្ធិច្បាប់ស្តីពីសិទ្ធិមនុស្ស សម្រាប់ការបកស្រាយសិទ្ធិបង្ហាញភស្តុតាងក្នុងការការពារខ្លួន ឱ្យសំខាន់ជាងវិធានបដិសេធភស្តុតាងដោយស្វ័យប្រវត្តិនោះទេ ឬយល់ថា ផលប្រយោជន៍របស់ជនជាប់ចោទ គ្រប់ពេល ត្រូវតែជាកត្តាកំណត់ក្នុងការសម្រេចបដិសេធវិធាននេះដែរ។ ផ្ទុយទៅវិញ ជនជាប់ចោទ មានសិទ្ធិឱ្យបោះបង់ការហាមឃាត់ដែលបានកំណត់ដោយវិធានបដិសេធភស្តុតាង តែក្នុងករណីដែលសិទ្ធិ និងផលប្រយោជន៍ដែលវិធាននេះការពារ គឺស្ថិតនៅក្នុងអំណាចជាស្វ័យតរបស់ជនជាប់ចោទប៉ុណ្ណោះ[157]។ ក្នុងករណីដទៃទៀត បញ្ហាស្តីពីការបោះបង់វិធានបដិសេធភស្តុតាងចោល ត្រូវតែ

---

រដ្ឋ"ដោយនាយករដ្ឋមន្ត្រី នៅពេលដែលការផ្សព្វផ្សាយទៅអាចជាការគំរាមកំហែងដល់សន្តិសុខជាតិ ពុំអាចត្រូវបានបង្ហាញ ឬប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ បើទោះបីជាព័ត៌មាននោះ ត្រូវបានចោទប្រកាន់ថា មានភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកយ៉ាងណាក៏ដោយ។

[156] ស្តីពីបុព្វសិទ្ធិរវាងមេធាវី និងកូនក្តី, *សូមមើលវិ*ធានគំរូនៃគណៈមេធាវីរបស់អាមេរិកស្តីពីក្រមសីលធម៌វិជ្ជាជីវៈ វិធាន ១.៦ អំពីការរក្សាការសម្ងាត់នៃព័ត៌មាន [ឆ្នាំ ២០១៥])។ *សូមមើលផងដែរ រដ្ឋ ទល់នឹង Macumber*, សំណុំរឿងលេខ 544 P.2d 1084 (Ariz. 1976), ទំព័រ ១០៨៦ ដែលពិពណ៌នាអំពីថាតើតុលាការកំពូលនៃ Arizona បានតំកល់ការសម្រេចរបស់តុលាការជំនុំជម្រះ ដែលបានអះអាងពីឯកសិទ្ធិរបស់មេធាវីនិងកូនក្តីក្រោយពីមរណភាពរបស់កូនក្តីយ៉ាងដូចម្តេច និង*រឿងក្តី រដ្ឋ ទល់នឹង Hunt*, សំណុំរឿងលេខ 659 S.E.2d 6 (N.C. 2008) នៅពេលមានបុរសពីនាក់ឈ្មោះ Hunt និង Cashwell ត្រូវបានដាក់ពិរុទ្ធភាពពីបទមនុស្សឃាត ដែលមានតែ Cashwell ម្នាក់ឯងតែប៉ុណ្ណោះដែលបានសារភាពទៅមេធាវីការពាររបស់ខ្លួនថាជាជនដែលដល់តែម្នាក់ឯង ដែលមេធាវីពុំបានបង្ហាញរហូតទាល់តែ ក្រោយពីមរណភាពរបស់ Cashwell (Colin Miller, "បទពិសោធន៍ដូរចត់ដោយគ្មានពិរុទ្ធ៖ មូលហេតុអ្វីបានជាមានករណីលើកលែងនៃការដាក់ពន្ធនាគារ/ការប្រហារជីវិតខុស ចំពោះការសម្ងាត់រវាងមេធាវី និងកូនក្តី", *ការពិភាក្សាពិនិត្យច្បាប់របស់សាកលវិទ្យាល័យ Northwestern (Northwestern University Law Review Colloquy)*, ភាគ ១០២ (ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨), ទំព័រ ៣៩១ ដល់ ៣៩២)។ សម្រាប់បុព្វសិទ្ធិនៅក្នុងយុត្តាធិការច្បាប់ស៊ីវិល, *សូមមើល ឧ.* មាត្រា ១៧៨ នៃក្រមព្រហ្មទណ្ឌរបស់ប៉ូឡូញ (ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៧ វិសោធនកម្មនៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥) និងមាត្រា ៥៦(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌរុស្ស៊ី (ជើងទំព័រ ១៥២ ខាងលើ) បញ្ជាក់អះអាងនូវបុព្វសិទ្ធិមិនឱ្យមេធាវីស្របច្បាប់ និងលោកសង្ឃបុជិតដែលជាអ្នកស្តាប់ចម្លើយសារភាព មកផ្តល់សក្ខីកម្មទាក់ទងទៅនឹងព័ត៌មានទទួលបានក្នុងការបំពេញនូវកាតព្វកិច្ចតាមតួនាទីរបស់ពួកគេ។

[157] ចម្លើយបែបនេះ បានមកតាមរយៈការរំលោភលើសិទ្ធិមិនឆ្លើយនឹងសំណួរ ឬចម្លើយបានមកដោយគ្មានមេធាវីដែលជួយប្រឹក្សាអំពីសិទ្ធិរបស់ជនជាប់ចោទ។

ដោះស្រាយដោយថ្លឹងថ្លែងឱ្យមានតុល្យភាពលើអត្ថប្រយោជន៍សំខាន់ៗ ដោយផ្អែកលើការពិចារណាលើភាពចាំបាច់ និងភាពសមមាត្រ[158]។

64. យោងតាមទស្សនៈរបស់អង្គជំនុំជម្រះ ការណ៍ដែលថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ពុំបានរៀបរាប់ពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលជាក្តីបារម្ភមួយនោះ ពុំមែនបង្ហាញថា សិទ្ធិនេះ ត្រូវបានទុកចោលដោយឥតពិចារណាទៅលើផលប្រយោជន៍ពាក់ព័ន្ធនោះទេ នៅពេលធ្វើការអនុម័តបទប្បញ្ញត្តិនេះ។ ផ្ទុយទៅវិញ ជម្រើសក្នុងការមិនកម្រិតភាសាហាមប្រាមរបស់ខ្លួនលើភស្តុតាង*ប្រឆាំងនឹង*បុគ្គលណាម្នាក់[159] និងប្រវត្តិនៃការធ្វើសេចក្តីព្រាងរបស់ខ្លួន[160] បានឱ្យដឹងថា វិធានបដិសេធភស្តុតាង ពុំមែនក្នុងន័យដើម្បីបន្ធូរបន្ថយ ជាទូទៅ លើសិទ្ធិបង្ហាញភស្តុតាងដើម្បីការពារខ្លួននោះទេ។ នៅក្នុងការសាកល្បងសេចក្តីអះអាងទល់នឹងកម្មវត្ថុ និងគោលបំណងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដូចបានបំភ្លឺខាងលើ បានកត់សម្គាល់ឱ្យឃើញថា គោលដៅសំខាន់បំផុតនៃការរារាំងការធ្វើទារុណកម្ម គឺពុំអនុញ្ញាតឱ្យមានការប្រើប្រាស់ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម នៅគ្រប់កាលៈទេសៈទាំងអស់ ក្រៅពីកាលៈទេសៈទាំងនោះ ដែលមានចែងនៅក្នុងប្រយោគទីពីរនៃបទប្បញ្ញត្តិនេះ ដោយសារតែការបង្ហាញថាព័ត៌មាននេះមានលក្ខណៈស្របច្បាប់សម្រាប់ធ្វើជាភស្តុតាង បានធ្វើឱ្យមាន

---

[158] *សូមមើល រឿងក្តី Al Nashiri ទល់នឹង ប្រទេសប៉ូឡូញ* កថាខណ្ឌ ៥៨៤ “គួររំលឹកថា បើទោះបីជាមានអត្ថប្រយោជន៍សាធារណៈយ៉ាងច្រើនយ៉ាងណាក៏ដោយ ក្នុងការរក្សាការសម្ងាត់នៃប្រភពព័ត៌មាន ឬសម្ភារៈ ជាពិសេសក្នុងរឿងក្តីពាក់ព័ន្ធនឹងភេរវកម្ម ក៏ជាការចាំបាច់ដែលថា ព័ត៌មានដែលជាប់ពាក់ព័ន្ធយ៉ាងច្រើនទៅនឹងការចោទប្រកាន់ និងភស្តុតាង គប្បីត្រូវបានបង្ហាញដល់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយពុំចាំបាច់សម្របសម្រួលទៅតាមគោលការណ៍សន្តិសុខជាតិឡើយ។ នៅពេលដែលការបង្ហាញព័ត៌មានពេញលេញពុំអាចធ្វើទៅបាន ដោយសារតែការលំបាកដែលកើតមាននោះ គប្បីត្រូវតែថ្លឹងថ្លែងនៅក្នុងវិធីសាស្ត្រមួយដែល ភាគីអាចការពារផលប្រយោជន៍របស់ខ្លួនបានដោយប្រសិទ្ធភាព”។ *សូមមើលផងដែរ រឿងក្តី A. និងអ្នកដទៃទៀត ទល់នឹង ចក្រភពអង់គ្លេស, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* (ECtHR), “សាលដីការបស់អង្គជំនុំជម្រះជាន់ខ្ពស់” សំណើលេខ 3455/05, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ២១៦ ដល់ ២១៨។

[159] ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមរបស់អង្គការសហប្រជាជាតិ គណៈកម្មការនៃសិទ្ធិមនុស្ស ‘បញ្ហានៃសិទ្ធិមនុស្សចំពោះបុគ្គលទាំងអស់ដែលទទួលរងនូវការឃុំខ្លួន ឬការដាក់ក្នុងមន្ទីរឃុំឃាំងគ្រប់ប្រភេទ ជាពិសេសការធ្វើទារុណកម្ម និង ការទណ្ឌកម្ម ឬ អំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតម្លៃមនុស្ស ឬអំពើឃោរឃៅដទៃទៀត’, សម័យប្រជុំលើកទី ៣៥ ឯកសាររបស់ អ.ស.ប លេខ E/CN.4/1314, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៨ ទំព័រ ១៨។ *សូមមើលផងដែរ* របាយការណ៍របស់អ្នករាយការណ៍ពិសេសលេខ A/61/259, កថាខណ្ឌ ៤៥ ដល់ ៤៨ របាយការណ៍របស់អ្នករាយការណ៍ពិសេសលេខ A/HRC/25/60, កថាខណ្ឌ ៣០។

[160] សៀវភៅរបស់សាស្ត្រាចារ្យ Manfred Nowak & Elizabeth McArthur, ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្មៈ សេចក្តីអធិប្បាយ* ទំព័រ ៥០៦ ដល់ ៥០៧។

ការថយចុះនូវកម្លាំងនៃការហាមឃាត់ និងអាចធ្វើឱ្យមនុស្សមួយក្រុមទទួលបានផលប្រយោជន៍តាមរយៈការចែកចាយព័ត៌មាន ដែលបានមកតាមរយៈការធ្វើទារុណកម្មនេះ។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការបង្ហាញពីក្តីបារម្ភចំពោះការធ្វើឱ្យញញើតជាទូទៅ គឺពុំអាចធ្វើឱ្យជឿបាន ដើម្បីបដិសេធចោលនូវការអះអាងដែលផ្អែកលើសិទ្ធិនានានៅក្នុងរឿងក្តីនីមួយៗបានឡើយ លើកលែងតែមានការគិតគូរស៊ីជម្រៅ និងបង្ហាញតាមរយៈសេចក្តីសម្រេចផ្នែកនីតិបញ្ញត្តិច្បាស់លាស់។ អាស្រ័យហេតុនេះ គោលការណ៍បង្ការដ៏ត្រឹមត្រូវនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណ នឹងមានសុពលភាពសម្រាប់ការពិភាក្សាបច្ចុប្បន្ន ទាល់តែបានអានបទប្បញ្ញត្តិនៃមាត្រានេះ ដែលពុំអនុញ្ញាតឱ្យធ្វើបដិបញ្ញត្តិឡើយ។ នៅគ្រប់កាលៈទេសៈទាំងអស់ បើទោះបីជាមានការសន្មតថា តួនាទីបង្ការនៃវិធានបដិសេធភស្តុតាងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ត្រូវតែផ្តល់ជាប្រយោជន៍ដល់សិទ្ធិក្នុងការបង្ហាញភស្តុតាងការពារខ្លួន ដោយផ្អែកលើព័ត៌មានដែលបានមកពីការធ្វើទារុណកម្មយ៉ាងណាក៏ដោយ ក៏សិទ្ធិទទួលបានអត្ថប្រយោជន៍ក្នុងការការពារខ្លួន នៅតែប្រឈមមុខជាមួយលក្ខខណ្ឌបង្គាប់បញ្ជាដែលពុំអនុញ្ញាតឱ្យប្រើដាច់ខាតនូវភស្តុតាង ដែលមានមូលដ្ឋានពុំអាចជឿទុកចិត្តបាន បន្ថែមលើនេះទៀត និងបានកើតចេញពីអំពើដែលមិនត្រឹមតែជាការបន្ទាបបន្ថោកដល់សេចក្តីថ្លៃថ្នូររបស់មនុស្សប៉ុណ្ណោះទេ ថែមទាំងជាអំពើឃោរឃៅទៀតផង និងជាបទឧក្រិដ្ឋប្រឆាំងនឹងបទដ្ឋានអន្តរជាតិដែលមានលក្ខណៈចាប់បង្ខំ (*juris cogentis*)។ បន្ថែមលើនេះទៀត គប្បីធ្វើការកត់សម្គាល់ផងដែរថា ការប្រើប្រាស់ភស្តុតាងបែបនេះ នឹងធ្វើឱ្យមានការប៉ះពាល់ជាថ្មីម្តងទៀតដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះនៃការធ្វើទារុណកម្មនោះ។ ទាំងនេះគឺជាអត្ថប្រយោជន៍ស្របច្បាប់ ដែលទាមទារឱ្យមានការសម្របសម្រួលនូវប្រតិបត្តិការរបស់តុលាការទៅលើភស្តុតាង ដោយពុំគ្រាន់តែពិចារណាលើចម្លើយដែលទាញចេញពីតតិយជនប៉ុណ្ណោះទេ ថែមទាំងចម្លើយផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលបានមកពីការធ្វើទារុណកម្ម បើទោះជាជនជាប់ចោទមានបំណងប្រើប្រាស់ ឬយល់ព្រមទៅនឹងការប្រើប្រាស់នូវចម្លើយនេះក៏ដោយ។ អាស្រ័យហេតុនេះ បទដ្ឋានសមមាត្រដែលប្រើប្រាស់សម្រាប់ថ្លឹងថ្លែងអត្ថប្រយោជន៍ទាំងនេះ ជាធម្មតានឹងបដិសេធភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម បើសូម្បីតែភស្តុតាងនោះ អាចជួយដល់ការការពារក្តីក៏ដោយ។ ប៉ុន្តែករណីលើកលែងអាចកើតមាននៅក្នុងកាលៈទេសៈដែលចាំបាច់បំផុត ដោយផ្អែកលើកត្តាជាច្រើនរួមគ្នា ដូចជាប្រភពនៃភស្តុតាង[161], ភាពអាចជឿទុកចិត្តបាន[162], តម្លៃដោះបន្ទុកច្រើនលើសលប់ និងលក្ខណៈពិសេសរបស់វាជា

[161] បញ្ហាដែលថាភស្តុតាង ត្រូវបានផលិតឡើងដោយអយ្យការ ឬតតិយជននោះ ក្នុងករណី មិនទាក់ទងឡើយ។ វាត្រូវតែមានការសង្កត់ធ្ងន់ថា ការធ្វើទារុណដើម្បីប្រមូលភស្តុតាង ពុំអាចបណ្តោយឱ្យកើតមានឡើយ។ ផ្ទុយទៅវិញ បញ្ហាគឺ ពាក់ព័ន្ធទៅនឹង

ដើម ដោយសារ បើទោះបីជាមានការពិចារណាខាងលើក៏ដោយ ការដកចេញព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការបង្ហាញភស្តុតាងការពារខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីដែលមានការចោទប្រកាន់ តែពុំបានអនុញ្ញាតឱ្យប្រើភស្តុតាងដែលចោទបញ្ហានេះ ដែលនាំឱ្យនីតិវិធីនេះក្លាយជាយុត្តិនិសេធយ៉ាងជាក់ច្បាស់។

65. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អាចមានរឿងក្តីមួយចំនួនដែលមានលក្ខណៈកម្រ និងអាចមានករណីចាំបាច់នានា ដែលត្រូវដកចេញពីវិធានបដិសេធភស្តុតាង ប៉ុន្តែ រឿងក្តីនៅចំពោះមុខនេះពិតណាស់ពុំមែននៅក្នុងចំណោមរឿងក្តីទាំងនោះឡើយ។ បញ្ហានៅទីនេះ គឺថាតើ ចម្លើយនៅមន្ទីរ ស-២១ អាចត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលសវនាការក្នុងខែ កក្កដា ឆ្នាំ ២០១៥ សម្រាប់តែគោលបំណងដែលត្រូវបានកម្រិត ក្នុងការសួរសំណួរសាក្សីទាំងបីរូបលើបណ្តឹងសាទុក្ខដែរ ឬយ៉ាងណា។ ហេតុនេះ យ៉ាងច្រើនបំផុត ចម្លើយនៅមន្ទីរ ស-២១ នឹងត្រូវបានប្រើប្រាស់ដើម្បីសួរសាក្សី និងដើម្បីបំភ្លឺព័ត៌មានបន្ថែមតែប៉ុណ្ណោះ ហើយ ពុំមានការបញ្ជាក់អ្វីផ្សេងទៀតដែលថា ការពុំអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ ក្នុងគោលបំណងនេះ នឹងធ្វើឱ្យប៉ះពាល់យ៉ាងសំខាន់ដល់ជនជាប់ចោទ ឬអាចនាំឱ្យទៅរកយុត្តិនិសេធជាក់ស្តែងឡើយ។

### ង. តើសហព្រះរាជអាជ្ញា អាចប្រើប្រាស់ចម្លើយនៅមន្ទីរ ស-២១ ក្នុងការបញ្ជាក់នូវអង្គហេតុដែលពុំជាប់ពាក់ព័ន្ធទៅនឹងការពិតនៃខ្លឹមសាររបស់ចម្លើយនោះបានដែរ ឬទេ?

66. សហព្រះរាជអាជ្ញាស្នើប្រហាក់ប្រហែលគ្នាដែរសុំការរឹតត្បិតទៅលើការអនុវត្តមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បើទោះបីជាក្នុងទិសដៅផ្សេងក៏ដោយ។ សហព្រះរាជអាជ្ញា បានបញ្ចូលជាសេចក្តីយោងនៅក្នុងសារណារបស់ខ្លួន នៅមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២[163] និងបានជំទាស់ថា វិធានបដិសេធភស្តុតាង ពុំអាចអនុវត្តបាន នៅពេលណាដែលចម្លើយបានមកពីការធ្វើទារុណកម្មនោះ កំពុងត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់នូវអង្គហេតុដែលពុំជាប់ពាក់ព័ន្ធទៅ

---

ព័ត៌មានដែលបានដាក់រួចហើយនៅចំពោះមុខស្ថាប័នអនុវត្តនីតិវិធីព្រហ្មទណ្ឌ ដែលសម្រេចលើការប្រើប្រាស់ ដោយពុំបានចូលរួមនៅក្នុងការប្រមូលភស្តុតាងនោះ និងពាក់ព័ន្ធបញ្ហាដែលព័ត៌មានដោះបន្ទុកនោះ អាចពុំត្រូវបានយកចិត្តទុកដាក់ឡើយ។

[162]ភាពដែលអាចជឿទុកចិត្តបាននៃចម្លើយបានមកពីការធ្វើទារុណកម្ម នៅតែជាបញ្ហាសំខាន់។ ទោះជាយ៉ាងណាក្តី បញ្ហានេះ ពុំបានកើតឡើងទាក់ទងទៅនឹងភស្តុតាងពិតប្រាកដដែលបានមកពីជនរងគ្រោះ ដោយផ្ទាល់ដូចជា(*ត្រូវបានប្រៀបធៀបជាមួយនឹងរឿងក្តី Jalloh ទល់នឹង ប្រទេសអាល្លឺម៉ង់*) ឬដោយផ្អែកទៅលើចម្លើយពាក់ព័ន្ធនឹងទារុណកម្ម (*ត្រូវបានប្រៀបធៀបជាមួយនឹងរឿងក្តី Gäfgen ទល់នឹង ប្រទេសអាល្លឺម៉ង់*)។

[163] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

នឹងការពិតនៃបញ្ហា"ដែលបានសារភាព"នោះទេ ដូចជា អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ត្រូវបានសួរយកចម្លើយអំពីការលាក់បំពួន ឬការខកខានក្នុងការសម្លាប់អ្នករដ្ឋការ លន់ នល់ ឬការបង្ហាញភស្តុតាងបន្ថែមថាការសម្លាប់អ្នករដ្ឋការ លន់ នល់ គឺជាគោលនយោបាយលើខ្នាំងនៃរបបនេះ ជាដើម[164]។ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានអះអាងថា ករណីលើកលែងនៅក្នុងប្រយោគទីពីរនៃមាត្រា ១៥ ដែលអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្ម "ធ្វើជាភស្តុតាងដែលចម្លើយនេះបានធ្វើឡើងប្រាកដមែន" បានបញ្ជាក់ថា ចម្លើយ អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយផ្សេង ក្រៅតែពីការបញ្ជាក់នូវការពិតនៃខ្លឹមសារនៅក្នុងចម្លើយនេះ[165]។ សហព្រះរាជអាជ្ញា បន្ថែមទៀតថា វិធានបដិសេធភស្តុតាង គ្រាន់តែមានគោលបំណងធ្វើឱ្យមានការញញើតចំពោះភាគីដែលស្នើសុំការប្រើប្រាស់ចម្លើយដែលទទួលបានមកពីការធ្វើទារុណកម្ម ដែលជាផ្នែកនៃរបបរបស់ចារីតែប៉ុណ្ណោះ ហើយបានបន្ថែមទៀតថា ការរារាំងតុលាការ ឬសហព្រះរាជអាជ្ញាមិនឱ្យប្រើប្រាស់ចម្លើយនេះ សម្រាប់គោលបំណងដែលពុំមានការជាប់ពាក់ព័ន្ធទៅនឹងខ្លឹមសារ នឹងជះអានុភាពពុំសមហេតុផលដោយបានផ្តល់រង្វាន់ដល់អ្នកធ្វើទារុណកម្មបិទបាំងអំពើរបស់ពួកគេពីការទទួលខុសត្រូវ[166]។

67. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា សំណុំរឿង ០០២/០១ ពុំមានការជាប់ពាក់ព័ន្ធទៅនឹងបទចោទនៃការធ្វើទារុណកម្មឡើយ។ អាស្រ័យហេតុនេះ ករណីលើកលែងតែមួយនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្ម"ប្រឆាំងនឹងបុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មធ្វើជាភស្តុតាងបញ្ជាក់ថាចម្លើយនេះពិតជាបានធ្វើឡើងមែន" ពុំអាចអនុវត្តបានឡើយ។ ការបញ្ចូលអំណះអំណាងរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ មកក្នុងរឿងក្តីបច្ចុប្បន្ន សហព្រះរាជអាជ្ញា បានធ្វើការអះអាងយ៉ាងសំខាន់ទៅលើលទ្ធិច្បាប់ស្តីពីភាពចាំបាច់ដែលគួរឱ្យកត់សម្គាល់ គឺជាតម្រូវការចាំបាច់នៃការចោទប្រកាន់ប្រកបដោយប្រសិទ្ធិភាព ដើម្បីពង្រីកការប្រើប្រាស់ចម្លើយបានមកពីការធ្វើទារុណកម្ម ឱ្យលើសពីពាក្យពេចន៍ជាក់ច្បាស់ក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ យោងតាមសំអាងហេតុដែលបានបញ្ជាក់ក្នុងកថាខណ្ឌ ៤០ ដល់ ៤៧ ខាងលើ វិធានបដិសេធភស្តុតាង ពុំបានគាំទ្រក្នុងការសម្រួលដល់ការបកស្រាយរបស់សហព្រះរាជអាជ្ញាឡើយ។ កម្មវត្ថុ និងគោលបំណងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម តម្រូវឱ្យមានការដកចេញយ៉ាងទូលំទូលាយនូវព័ត៌មានណាមួយដែលបានមកពីការធ្វើទារុណកម្ម។ ហើយ ចំពោះករណីលើក

---

[164] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[165] សារណារបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៧។

[166] សារណារបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៦។

លែងនៃវិធាននេះ តាមខ្លឹមសារ ត្រូវតែបកស្រាយក្នុងន័យចង្អៀត។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងយុត្តិសាស្ត្រដែលបានដកស្រង់ខាងលើ[167] ដែលអះអាងថា ភាពចាំបាច់នៃការចោទប្រកាន់ ពុំអាចធ្វើយុត្តិកម្មលើការប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្មបានឡើយ រួមទាំងភាគីដទៃទៀតដែលស្នើសុំប្រើប្រាស់ចម្លើយនេះ ហើយពុំមែនជាអ្នកទទួលខុសត្រូវចំពោះការធ្វើទារុណកម្មនោះ ផងដែរ។

68. យោងតាមរយៈសញ្ញាណនៃ“ចម្លើយ”ដូចបានបកស្រាយខាងលើ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានដកចេញនូវការទទួលយកព័ត៌មានដែលបានមកពីជនរងគ្រោះនៃការធ្វើទារុណកម្ម បើទោះបីជាបង្ហាញដោយផ្ទាល់ តាមរយៈសាក្សី ឬតាមរយៈកំណត់ត្រាផ្សេងៗក៏ដោយ។ ទោះជាយ៉ាងណាក្តី មាត្រា ១៥ ពុំបានកំណត់ជាទូទៅថាត្រូវដកចេញនូវកំណត់ហេតុទាំងមូលជុំវិញការសួរយកចម្លើយពីជនរងគ្រោះនៃការធ្វើទារុណកម្មឡើយ។ នៅពេលដែលកំណត់ត្រា អំពីការសួរយកចម្លើយ មានព័ត៌មានរបស់បុគ្គលផ្សេងទៀតក្រៅពីជនរងគ្រោះនៃការធ្វើទារុណកម្ម ដូចជាព័ត៌មានៃការសួរយកចម្លើយរបស់អ្នកធ្វើទារុណកម្ម ព័ត៌មាននេះអាចប្រើប្រាស់បាន ដោយសារព័ត៌មាននេះអាចបញ្ជាក់ពីសំណួរដែលបានសួរអំពីបុគ្គលដែលបានចូលរួម ឬព្រឹត្តិការណ៍ និងជាពិសេស អំពើនៃការធ្វើទារុណកម្មតែម្តង[168]។ម្យ៉ាងវិញទៀត បញ្ហាដែលថាតើ ព័ត៌មានដូចទិន្នន័យអំពីជីវប្រវត្តិដែលត្រូវបានកត់ត្រានៅក្នុងចម្លើយសារភាពនៅមន្ទីរ ស-២១ ឬសៀវភៅកំណត់ហេតុពន្ធនាគារបង្ហាញពីអត្តសញ្ញាណរបស់ជនរងគ្រោះ ដូចជា ឈ្មោះ អាយុ ទីលំនៅ មុខរបរពីមុន និងអង្គភាព ឬតួនាទីក្នុងបក្សកុម្មុយនីស្តកម្ពុជា និងព័ត៌មានផ្សេងៗទៀតដែលសហព្រះរាជអាជ្ញាចង់ប្រើប្រាស់[169]បានមកពីការធ្វើទារុណកម្មដែរ ឬយ៉ាងណានោះ គឺជាបញ្ហានៃភស្តុតាង។ សម្រាប់គោលបំណងនៃរឿងក្តីនៅចំពោះមុខ ការពិនិត្យលើចម្លើយនៅមន្ទីរ ស-២១ រួមទាំងបញ្ជីឯកសាររបស់ នួន ជា និងសហព្រះរាជអាជ្ញា បានឱ្យដឹង*ជាសេចក្តីបញ្ជាក់ដំបូង*ថា ខ្លឹមសារទាំងមូលក្នុងនោះ គឺបានមកពីជនរងគ្រោះតែម្ខាងប៉ុណ្ណោះ ហើយសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន បានបង្ហាញថា ជនរងគ្រោះ គឺជាអ្នកទទួលរងទារុណកម្ម។ “អង្គហេតុពាក់ព័ន្ធដទៃទៀត” ត្រូវតែបង្ហាញឡើងតាមរយៈការធ្វើសេចក្តីសន្និដ្ឋាន។ សហព្រះរាជអាជ្ញា ពុំបានបង្ហាញថាតើ ខ្លឹមសារនៃចម្លើយ

---

[167] កថាខណ្ឌ ៤២ ដល់ ៤៦ *ខាងលើ*។

[168] សារណានៃសំណុំរឿង ០០២/០២ របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១ ដល់ ១៥។ *សូមមើលផងដែរ* សៀវភៅរបស់សាស្ត្រាចារ្យ Novak Manfred Nowak & Elizabeth McArthur, ចំណងជើងថា *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្មៈ សេចក្តីអធិប្បាយ* ទំព័រ ៥៣៦ ដល់ ៥៣៧។

[169] សារណារបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៩។

សារភាពនៅមន្ទីរ ស-២១ ពុំមែនបានមកពីជនរងគ្រោះ ឬជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ។ អាស្រ័យហេតុនេះ នៅក្នុងបរិបទនៃសវនាការខែ កក្កដា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូល បដិសេធការប្រើប្រាស់នូវចម្លើយនៅមន្ទីរ ស-២១ ឬការធ្វើសេចក្ដីសន្និដ្ឋានណាមួយចេញពីចម្លើយនេះ។

### ច. សេចក្ដីសន្និដ្ឋាន

69. ភាគីដែលស្នើសុំប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ឬមានបំណងផ្ដល់ជាភស្ដុតាងបែបនេះ ជាដំបូង ត្រូវបង្ហាញថា ភស្តុតាងនេះប្រើប្រាស់ទៅតាមហេតុផលដែលបានអនុញ្ញាតដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ទាំង នួន ជា និងសហព្រះរាជអាជ្ញា ពុំបានបង្ហាញដូច្នោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចថា ចម្លើយនៅមន្ទីរ ស-២១ ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងអំឡុងពេលសវនាការលើសាក្សីរហស្សនាម SCW-3, SCW-4, និង SCW 5 ឡើយ។

## VII. សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

70. ខៀវ សំផន កត់សម្គាល់ឃើញថា ឯកសារលេខ E1/197.1, E1/198.1, E1/199.1 និង E1/200.1, ដែលមាននៅក្នុងបញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសារលេខ E1/287.1 និង E3/4719, ដែលមាននៅក្នុងបញ្ជីឯកសាររបស់ហព្រះរាជអាជ្ញា គឺជាសេចក្ដីប្រកាសដែលដើមបណ្ដឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គល បានធ្វើឡើងទាក់ទងនឹងឧក្រិដ្ឋកម្ម[170]។ ខៀវ សំផន កត់សម្គាល់ថា ការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវសេចក្ដីប្រកាសនេះ គឺជាកម្មវត្ថុនៃទឡ្ហីករណ៍មួយក្នុងចំណោមទឡ្ហីករណ៍ជាច្រើននៃបណ្ដឹងសាទុក្ខរបស់គាត់ និងបានរំលឹកថា អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសេចក្ដីណែនាំបានបញ្ជាក់ថា "សំណួររបស់ភាគី ត្រូវតែមានការជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ដោយរួមទាំងភាពអាចជឿទុកចិត្តបាន និងភាពអាចជឿជាក់បាននៃភស្តុតាង"[171]។

71. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវចម្លើយ និងសេចក្ដីប្រកាសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពិតណាស់ គឺជាទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ

---

[170] សេចក្ដីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៥ និង ១៨។

[171] សេចក្ដីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៧ យោងទៅលើសេចក្ដីណែនាំ និងកថាខណ្ឌ ១ ខ) ដែលមានអនុភាព។

ដែលបានលើកឡើងដោយ ខៀវ សំផន និង នួន ជា[172]។ ទោះជាយ៉ាងណាក្តី នេះគ្រាន់តែជាវិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងផ្អែកលើចម្លើយនេះ ដែលវិធីសាស្ត្រនេះ ត្រូវបានចោទប្រកាន់ថា មានកំហុស ប៉ុន្តែពុំមែនជាសេចក្តីសម្រេច ដែលអនុញ្ញាតការប្រើប្រាស់នេះ ឬការទទួលយកជាភស្តុតាងនោះឡើយ។ អាស្រ័យហេតុនេះ ដោយពុំមានការប៉ះពាល់ដល់សេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះតុលាការកំពូលលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនោះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចអនុញ្ញាតការប្រើប្រាស់នូវឯកសារលេខ E1/197.1, E1/198.1, E1/199.1, E1/200.1, E1/287.1 និង E3/4719 ក្នុងការសួរសាក្សីបីរូបនេះ។

## VIII. ការដាក់បញ្ជីឯកសារនៅក្នុងសំណុំរឿង

72. ស្របតាមសេចក្តីណែនាំ នួន ជា និង ខៀវ សំផន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើបញ្ជីឯកសាររៀងៗខ្លួនជាឯកសារភ្ជាប់តាមអ៊ីមែលមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល។ ដើម្បីបញ្ជាក់ពីភាពពេញលេញ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា បញ្ជីឯកសារទាំងនេះ ត្រូវតែដាក់ចូលទៅក្នុងសំណុំរឿង ០០២/០១[173]។

## IX. ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

១. បដិសេធសំណើរបស់ នួន ជា និង ខៀវ សំផន សុំជំទាស់ទៅនឹងការដាក់បញ្ចូលនូវបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាដោយសំអាងថា ការដាក់ឯកសារនេះយឺតពេល។

២. សហព្រះរាជអាជ្ញាពុំអាចប្រើប្រាស់ឯកសារលេខ E3/1539 ក្នុងពេលសួរសំណួរសាក្សី ដោយសារតែឯកសារនេះ ពុំត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងពុំបានបង្ហាញពីមូលហេតុគួរឱ្យជឿជាក់បានសម្រាប់សេចក្តីសន្និដ្ឋានរបស់ខ្លួនឡើយ។

---

[172] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F17 កថាខណ្ឌ ៣០។ សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៥ ដល់ ២០៦។

[173] បញ្ជីឯកសាររបស់ នួន ជា សម្រាប់ប្រើប្រាស់នៅក្នុងការសួរសំណួរសាក្សី SCW-3, SCW-4 និង SCW-5 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F26/4។ បញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់ប្រើប្រាស់ក្នុងការសួរសាក្សី *SCW-3, SCW-4 និង SCW-5*, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F26/5។ បញ្ជីឯកសារដែលត្រូវប្រើប្រាស់ដោយសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F26/6។

៣. សហព្រះរាជអាជ្ញា ពុំអាចប្រើប្រាស់ឯកសារណាមួយដូចខាងក្រោម ក្នុងការសួរសាក្សី ដែលឯកសារនេះច្រើនជាង ៣០ ទំព័រ ប៉ុន្តែ សហព្រះរាជអាជ្ញា ពុំបានអនុវត្តតាមសេចក្តីណែនាំ និងពុំបានផ្តល់លេខឯកសារពេញលេញណាមួយសម្រាប់ឯកសារទាំងនោះ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដូចខាងក្រោម:

D313.2.25/D366/7.1.108, E3/3989, E3/531, E3/342, E305/13.23.375, E319.1.27, E3/1805, E3/4590, E3/62, E1/14.1, E1/216.1, E1/140.1, E1/144.1, E1/138.1, E1/218.1, E1/191.1, E305/13.23.405, E3/89, E3/387, E319/19.3.125, E3/5649, E319.1.21, E1/278.1, E1/279.1, E3/4627, E1/298.1, E1/299.1, E1/290.1, E1/291.1, E1/215.1, E1/256.1, E1/258.1, E1/255.1, E1/269.1, E3/3232, E3/5637, E1/296.1, E3/2120. D313/1.2.16, E3/1682, E3/2792, E3/3857, E3/3973, E1/249.1, E1/252.1, E1/253.1, E1/263.1, E1/264.1, E1/265.1, E1/281.1, E1/283.1, E1/287.1, E1/289.1, E1/257.1, E1/300.1, E1/222.1, E305/13.23.451។

៤. នួន ជា, ខៀវ សំផន និងសហព្រះរាជអាជ្ញា ពុំអាចប្រើប្រាស់ឯកសារដែលមាននៅក្នុងបញ្ជីឯកសារដូចខាងក្រោម ពីព្រោះឯកសារទាំងនេះ ពុំមាននៅក្នុងកំណត់ហេតុស៊ើបសួរ នៅក្នុងសំណុំរឿង ០០២/០១ និងពុំមែនជាកម្មវត្ថុនៃសំណើសុំភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខដែលពុំទាន់បានសម្រេចឡើយ៖

E319.1.18 (CF004 D118/259), E3/9118 (E305/13.23.405), E3/5838, ប្រតិចារឹកព្រាងនៃសវនាការលើ សែប ហឿន ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥, ប្រតិចារឹកព្រាងនៃសវនាការលើ សែប ហឿន ថ្ងៃ ២៣ ខែ មិថុនា ឆ្នាំ ២០១៥, Nayan Chanda, "កាលវិភាគសម្រាប់ការកាន់កាប់៖ សេចក្តីសម្រេចរបស់ទីក្រុងហាណូយ ក្នុងការកាន់កាប់កម្ពុជា ក្រោយពីការរៀបចំផែនការអស់ជាច្រើនខែ យ៉ាងប្រុងប្រយ័ត្ន", *ការពិនិត្យឡើងវិញលើសេដ្ឋកិច្ចនៅចុងបូព៌ា*, អ្នកនិពន្ធពុំត្រូវបានគេស្គាល់ "នោះ គឺលេខ F-111; នោះ គឺ MiG!", *អាស៊ីប្រចាំសប្តាហ៍*, អ្នកនិពន្ធឈ្មោះ Anthony Paul, "ចំណុចលម្អិតនៃផែនការក្បត់ បានលេចចេញ", *ការពិនិត្យឡើងវិញលើសេដ្ឋកិច្ចនៅចុងបូព៌ា*, D312.1.59-E3/8707, E319/12.3.10, E319/12.3.10/Corr-1, E319/19.3.125, E319/12.3.2, E319.1.21, E1/278.1, E1/279.1, E319.1.2, E319/23.3.42, E319/21.3.51, E1/298.1, E1/299.1, E1/290.1, E1/291.1, E1/256.1, E1/258.1, E1/255.1, E1/269.1, E1/296.1, E1/249.1, E1/252.1, E1/253.1, E1/263.1, E1/264.1, E1/265.1, E1/281.1, E1/283.1, E1/287.1, E1/289.1, E1/257.1, E1/300.1, E319.1.8, E319.1.23, E319/8.2.4, E319/12.3.8, IS 19.161, D312.2.25, D366/7.1.108, E305/13.23.375, D288/6.68.50, D166/173, D25/17, D25/19, D166/174, E319.1.32, D224.90, D313/1.2.16, E305/13.23.451, D40/20, D22/88, D25/24, D40/21។

៥. ភាគីពុំអាចប្រើប្រាស់នូវឯកសារ D312.2.25-D366/7.1.1.8, E3/1682, E3/1855, E3/2792, E3/3857, E3/3989, E3/4202 ពីព្រោះឯកសារទាំងនេះ ទំនងជាចម្លើយសារភាពដែលទទួលបានមកពីការធ្វើទារុណកម្ម ។

៦. សំណើរបស់ ខៀវ សំផន ដែលថា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារលេខ E1/197.1, E1/198.1, E1/199.1, E1/200.1, E1/287.1 និងឯកសារលេខ E3/4719 នៅក្នុងការសួរសាក្សី ពីព្រោះបញ្ហា ថាតើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្អែកលើសម្រាប់ការសម្រេចពិរុទ្ធភាពរបស់ជនជាប់ចោទនោះ ជាបញ្ហាកំពុងកើតឡើងដែរ ឬយ៉ាងណា លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ត្រូវបានបដិសេធចោល[174]។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

[174] សេចក្តីសម្រេចសង្ខេបទំព័រ ៣ ដល់ ៥។